សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# សុំកូននៅព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០២២ ដល់ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ២០២២


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ កញ្ញា **ទ៉ា សូលីស**

កញ្ញា **ស៊ុំ ច័ន្ទនិភា**

សាស្ត្រាចារ្យណែនាំ

លោក **ញឹក ទុធ្ធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២២

ឆ្នាំសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ម៉ា សូលីស** និង **ស៊ុំ ច័ន្ទនិកា** ជានិស្សិតបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្រ្តឆ្នាំទី ៤ ជំនាន់ទី ២២ នៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច** នៅក្នុងឆ្នាំសិក្សា ២០១៨-២០២២។

យើងខ្ញុំសូមលំឱនកាយ វាចា ចិត្ត គោរព និងសម្តែងនូវមហាកតញ្ញូតាធម៌ដឹងគុណយ៉ាងធំធេងជាទីបំផុត ជូនចំពោះអ្នកមានគុណទាំងពីរគឺ **លោកឪពុក និងអ្នកម្តាយ** ដែលលោកទាំងពីរបានផ្តល់កំណើត ព្រមទាំងបានចិញ្ចឹមបីបាច់ថែរក្សារូបកូនចាប់តាំងពីថ្ងៃដែលកូនបានចាប់កំណើត រហូតដល់ពេលដែលកូនបានធំពេញវ័យ។ មិនតែប៉ុណ្ណោះលោកទាំងពីរបានប្រៀនប្រដៅ និងបង្ហាត់បង្រៀនព្រមទាំងឱ្យ ដំបូន្មានល្អៗនៅក្នុងឆាកជីវិត រហូតដល់រូបកូនទទួលបាននូវភាពជោគជ័យជាមួយនឹងលទ្ធផលជាទីគាប់ប្រសើរនៅកម្រិតថ្នាក់ឧត្តមសិក្សាមួយនេះ។ លើសពីនេះទៅទៀតលោកទាំងពីរបានខិតខំពុះពារគ្រប់ឧបសគ្គដោយគ្មានពាក្យត្អូញត្អែរ និងបានបូជាសាច់ស្រស់ ឈាមស្រស់ខិតខំចំណាយទាំងកម្លាំងកាយ និងកម្លាំងចិត្ត ទាំងថ្ងៃ ទាំងយប់ដោយមិនខ្លាចនឿយហត់ ដើម្បីទំនុកបម្រុងកូនទាំងស្មារតី និងសម្ភារៈគ្រប់បែបយ៉ាង គុណរបស់លោកទាំងពីរគ្មានថ្ងៃណាដែលរូបកូនអាចបំភ្លេចបានឡើយ។ ដោយការខិតខំរបស់លោកទាំងពីរនេះហើយដែលធ្វើឱ្យរូបកូនមានថ្ងៃនេះ លោកទាំងពីរបានបញ្ជូនកូនទៅសាលា ដើម្បីទទួលបានចំណេះដឹងចាប់ពីនៅថ្នាក់បឋមសិក្សា ថ្នាក់អនុវិទ្យាល័យ ថ្នាក់វិទ្យាល័យ រហូតដល់ថ្នាក់ឧត្តមសិក្សា និងបានបញ្ចប់ការសិក្សាជាស្ថាពរ។ ប្រសិនបើគ្មានការជួយជ្រោមជ្រែងរបស់លោកទាំងពីរទេរូបកូនក៏គ្មានថ្ងៃនេះដែរ ពីព្រោះតែព្រហ្មវិហារធម៌ដែលគ្មានអ្វីប្រៀបប្រដូចបាននូវគុណរបស់លោកឪពុក និងអ្នកម្តាយនេះហើយដែលធ្វើឱ្យកូនមានការគោរព ចំពោះទង្វើដ៏ល្អដ៏សែនធំធេងគ្មានថ្ងៃណាដែលរូបកូនទាំងពីរនឹងអាចបំភ្លេចបានឡើយ រហូតដល់វិនាទីចុងក្រោយនៃជីវិតរបស់កូន។ សូមលោកទាំងពីរទទួលនូវការគោរព និងការដឹងគុណូបការៈដ៏ធំធេងពីសំណាក់កូនរបស់លោក។

យើងខ្ញុំសុំថ្លែងអំណរអរគុណយ៉ាងអនេកចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្រ្តាចារ្យ និងបុគ្គលិកគ្រប់ជាន់ថ្នាក់ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច** ដែលបានបង្ហាត់បង្រៀន ផ្តល់នូវចំណេះដឹងខ្ពស់នៅក្នុងការជួយតម្រង់ទិសដៅដល់យើងខ្ញុំតាំងពីថ្នាក់មូលដ្ឋាន រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រនេះបានប្រកបដោយក្រមសីលធម៌ និងវិជ្ជាជីវៈខ្ពស់។

លោក **ញឹក ទុទ្ធី** ដែលជាសាស្រ្តាចារ្យដឹកនាំ បានបង្ហាត់បង្ហាញនូវគំនិតក៏ដូចជា វិធីសាស្រ្តទាំងឡាយនៅក្នុងការស្រាវជ្រាវនូវប្រធានបទមួយនេះ។ លោកបានខិតខំចំណាយពេលវេលាដ៏មានតម្លៃរបស់លោកនៅក្នុង

ការជួយជ្រោមជ្រែងតាំងពីដើមរហូតដល់ទីបញ្ចប់។ ស្នាដៃមួយនេះចេញជារូបរាងទៅបានអាស្រ័យដោយលោកជាអ្នកណែនាំដោយផ្ទាល់។ លោកសាស្ត្រាចារ្យដឹកនាំ និស្សិតរៀមច្បង និងនិស្សិតទាំងអស់ដែលបានគាំទ្រជាសម្ភារៈ និងកម្លាំងចិត្ត ព្រមទាំងផ្តល់ជាគំនិតយោបល់ល្អៗនៅក្នុងការជំរុញឱ្យការស្រាវជ្រាវមួយនេះមានលក្ខណៈកាន់តែល្អប្រសើរឡើង ដើម្បីទុកជាឯកសារក្នុងការស្រាវជ្រាវជាមួយនឹងការស្វែងយល់ពីចំណេះដឹងបន្ថែម ដល់មិត្តនិស្សិតជំនាន់ក្រោយទៀត។

ជាចុងបញ្ចប់ យើងខ្ញុំសូមបួងសួង និងប្រសិទ្ធិពរជ័យដល់លោកអ្នកមានគុណទាំងទ្វេ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យទាំងអស់ និងបុគ្គលិកគ្រប់ជាន់ថ្នាក់ទាំងអស់ឱ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** ព្រមទាំងសម្បត្តិសុខទាំងឡាយចូលកើតមានដល់លោកអ្នកដែលមានគុណទាំងអស់កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្នុងនាមយើងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ជំនាន់ទី២២ នៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ក្នុងឆ្នាំសិក្សា ២០១៨-២០២២ ដែលត្រូវបានទទួលការលើកទឹកចិត្តពីសំណាក់សាកលវិទ្យាល័យឱ្យជ្រើសរើសប្រធានបទមួយ ដែលស្របទៅនឹងមុខជំនាញរបស់យើងខ្ញុំដើម្បីសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រនេះ។ ក្នុងឱកាសដ៏វិសេសវិសាលដែលសាកលវិទ្យាល័យបានផ្តល់ឱកាសឱ្យបែបនេះបូករួមទាំងការខិតខំប្រឹងប្រែងស្វែងយល់ក៏ដូចជា ការចុះធ្វើការសិក្សាស្រាវជ្រាវឯកសារកន្លងមក យើងខ្ញុំបានសម្រេចជ្រើសរើសតាក់តែងនូវសារណានេះក្រោមប្រធានបទ « ស្មុំកូននៅព្រះរាជាណាចក្រកម្ពុជា »។

មូលហេតុដែលធ្វើឱ្យយើងខ្ញុំសម្រេចយកប្រធានបទមួយនេះមកធ្វើការតាក់តែង មិនមែនមកពីចំណង់ចំណូលចិត្ត ឬចំណេះវិជ្ជាដែលធ្លាប់សិក្សាក្នុងថ្នាក់ពីមុនមកនោះទេ គឺមកពីយើងខ្ញុំសង្កេតឃើញថាវាជាកម្មវត្ថុចម្បងមួយផ្តោតទៅលើកុមារនៅកម្ពុជាគ្រប់រូបមិនថាកុមារកំព្រា កុមាររងាយរងគ្រោះ ឬជាកូនសុំក្តីត្រូវតែទទួលបាននូវការយកចិត្តទុកដាក់គាំពារយ៉ាងកក់ក្តៅពីសំណាក់គ្រួសារ និងសហគមន៍។ មិនតែប៉ុណ្ណោះស្ថាប័នដែលពាក់ព័ន្ធគួរតែផ្សព្វផ្សាយផ្តល់ពត៌មាន ឬចែករំលែកនូវការយល់ដឹងឱ្យកាន់តែទូលំទូលាយដល់ប្រជាជនអំពីនីតិវិធីនៃការស្មុំកូន ក៏ដូចជាសារៈសំខាន់នៃការស្មុំកូនដែលទទួលស្គាល់ដោយច្បាប់ត្រឹមត្រូវ ជៀសវាងការជួញដូរកុមារ ការរំលោភបំពានដល់សិទ្ធិរបស់កុមារ និងឧត្តមប្រយោជន៍នៃកុមារដែលកំពុងមានភាពលំបាកឱ្យកាន់តែលំបាកជាងមុនថែមទៀត។

យើងពិតជាមានមោទនៈភាពយ៉ាងខ្លាំងចំពោះស្នាដៃមួយនេះ ដោយហេតុថាវាជាការស្រាវជ្រាវថ្មីមួយដែលបានឧប្បត្តិឡើងតាមរយៈការខិតខំប្រឹងប្រែង ព្យាយាមសិក្សាស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់ជាទីបំផុតក្នុងការសម្រិតសម្រាំងចម្រាញ់យកខ្លឹមសារដែលមានគុណភាព និងសំខាន់ដើម្បីយកមកចងក្រងធ្វើជាសៀវភៅនេះឡើង។ ហើយជាងនេះទៅទៀត យើងអាចបង្កើតស្នាដៃនេះឡើងខណៈពេលដែលយើងខ្ញុំមានការលំបាកក្នុងការស្វែងរកឯកសារនានាដែលពាក់ព័ន្ធទៅនឹងស្មុំកូននេះ ដើម្បីយកមកសរសេរឱ្យបានគ្រប់តាមចំនួនកំណត់របស់សាកលវិទ្យាល័យ។ ក្នុងស្នាដៃនេះផងដែរ យើងបានសរសេររៀបរាប់ពីលក្ខខណ្ឌ នីតិវិធី អានុភាព សិទ្ធិ និងការកាត់កាល់ស្មុំកូនដែលមានចែងនៅក្នុងច្បាប់ ហើយយើងក៏បានស្វាត់ស្វែងប្រមូលឯកសារផ្សេងៗជាច្រើនទៀតដែលពាក់ព័ន្ធដើម្បីយកមកធ្វើជាឧបសម្ព័ន្ធ។ យើងពិតជាសង្ឃឹម និងជឿជាក់យ៉ាងមុតមាំក្នុងចិត្តថាស្នាដៃនេះពិតជាអាចរួមចំណែកក្នុងការផ្តល់នូវចំណេះដឹងអំពីនិតិវិធីនៃការស្មុំកូន ទៅដល់បងប្អូនប្រជាពលរដ្ឋ មិត្តអ្នកអាន

សិស្សនិស្សិត អ្នកស្រាវជ្រាវជំនាន់ក្រោយឱ្យបានដឹង ហើយក៏ដើម្បីចូលរួមលើកស្ទួយវិស័យយុត្តិធម៌ និងឧត្តមប្រយោជន៍របស់កុមារនៅកម្ពុជាឱ្យកាន់តែរីកចម្រើនមួយកម្រិតថែមទៀតដែរ។

ជាចុងក្រោយនេះ យើងខ្ញុំសូមលើកដៃប្រណមឡើងខន្តីអភ័យទោសទុកជាមុនពីសំណាក់សិស្សនិស្សិត មិត្តអ្នកអាន សាស្ត្រាចារ្យ និងអ្នកសិក្សាស្រាវជ្រាវនូវរាល់កំហុសឆ្គងទាំងអត្ថន័យ អក្ខរាវិរុទ្ធ ខ្លឹមសារ ឃ្លាឃ្លោង អក្ខរាវិរុទ្ធ ការប្រើប្រាស់ពាក្យពេចន៍មិនសមរម្យដែលកើតមានឡើងដោយអចេតនាត្រង់ប្រការណាមួយនៃស្នាដៃនេះ។ យើងខ្ញុំរីករាយនឹងទទួលយកនូវការរិះគន់ទាំងឡាយ ដើម្បីស្ថាបនាការស្រាវជ្រាវនេះឱ្យកាន់តែល្អប្រសើរឡើងមួយកម្រិតថែមទៀត។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម** ........ ១

**ជំពូកទី ១**

**សញ្ញាណទូទៅនៃសុំកូន**

**ផ្នែកទី ១. ការសុំកូន** ........ ៥

**កថាភាគទី ១. និយមន័យនៃសុំកូន** ........ ៥

**កថាភាគទី ២. គោលបំណងនៃការសុំកូន** ........ ៥

**កថាភាគទី ៣. លក្ខណៈពិសេសនៃការសុំកូន** ........ ៥

**ផ្នែកទី ២. ប្រភេទ និងសារៈសំខាន់នៃសុំកូន** ........ ៦

**កថាភាគទី ១. ប្រភេទនៃសុំកូន** ........ ៦

**កថាភាគទី ២. សារៈសំខាន់នៃសុំកូន** ........ ៧

១. សារៈសំខាន់នៃសុំកូនពេញលេញ ........ ៧

២. សារៈសំខាន់នៃសុំកូនធម្មតា ........ ៧

**ជំពូកទី ២**

**សុំកូនពេញលេញ**

**ផ្នែកទី ១. សញ្ញាណទូទៅនៃសុំកូនពេញលេញ** ........ ៨

**កថាភាគទី ១. និយមន័យ** ........ ៨

**កថាភាគទី ២. គោលបំណងនៃការបង្កើតសុំកូនពេញលេញ** ........ ៨

**ផ្នែកទី ២. លក្ខខណ្ឌនៃការបង្កើតសុំកូនពេញលេញ** ........ ៨

**កថាភាគទី ១. លក្ខខណ្ឌទាក់ទងនឹងបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម** ........ ៩

១. អាយុរបស់ឪពុកម្តាយចិញ្ចឹម ........ ៩

២. ភាពមានសហព័ទ្ធ និងសហការរបស់ឪពុកម្តាយចិញ្ចឹម........ ១០

**កថាភាគទី ២. លក្ខខណ្ឌទាក់ទងនឹងកូនសុំ** ........ ១១

១. អាយុរបស់កូនសុំ........ ១១

២. ស្ថានភាពរបស់កូនសុំ........ ១១

**កថាភាគទី ៣. លក្ខខណ្ឌផ្សេងៗ** ......... ១១
**កថាភាគទី ៤. នីតិវិធីនៃការសុំកូនពេញលេញ** ......... ១៣
១. ការដាក់ពាក្យសុំ ......... ១៣
២. អ្នកមានសិទ្ធិក្នុងការដាក់ពាក្យសុំ ......... ១៣
៣. ទម្រង់នៃការដាក់ពាក្យសុំ ......... ១៤
៤. ទីកន្លែងនៃការដាក់ពាក្យសុំ ......... ១៤
៥. ពន្ធដែលត្រូវបង់នៅពេលដាក់ពាក្យសុំ ......... ១៥
៦. ការពិនិត្យពាក្យសុំ ......... ១៥
៧. មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ ......... ១៥
**កថាភាគទី ៥. ក្រោយនីតិវិធីនៃការសុំកូនពេញលេញ** ......... ១៥
**កថាភាគទី ៦. ការចាត់ចែងរក្សាការពារ** ......... ១៧
**កថាភាគទី ៧. ដីកាសម្រេច** ......... ១៨
**កថាភាគទី ៨. បណ្តឹងជំទាស់** ......... ១៩
**ផ្នែកទី ៣. អានុភាពនៃសុំកូនពេញលេញ** ......... ១៩
**កថាភាគទី ១. ការកាត់ផ្តាច់ទំនាក់ទំនងញាតិ** ......... ១៩
**កថាភាគទី ២. ការបង្កើតទំនាក់ទំនងជាមួយឪពុកម្តាយចិញ្ចឹម** ......... ២០
**ផ្នែកទី ៤. សិទ្ធិរបស់សុំកូនពេញលេញ** ......... ២០
**កថាភាគទី ១. សិទ្ធិទទួលដឹងអំពីកំណើត** ......... ២០
**កថាភាគទី ២. សិទ្ធិក្នុងការជ្រើសរើសនាមត្រកូល** ......... ២១
**កថាភាគទី ៣. សិទ្ធិស្ថិតនៅក្រោមអំណាចមេបាររបស់ឪពុកម្តាយចិញ្ចឹមរបស់កូនសុំដែលជាអនីតិជន** ......... ២១
**កថាភាគទី ៤. សិទ្ធិទទួលបានអាហារកាតព្វកិច្ចរបស់កូនសុំដែលជាអនីតិជន** ......... ២២
**កថាភាគទី ៥. សិទ្ធិធ្វើ និងទទួលសន្តតិកម្ម** ......... ២២
**ផ្នែកទី ៥. ការកាត់កាល់សុំកូនពេញលេញ** ......... ២២
**កថាភាគទី ១. មូលហេតុនៃការកាត់កាល់សុំកូនពេញលេញ** ......... ២៣
**កថាភាគទី ២. អ្នកដែលមានសិទ្ធិកាត់កាល់សុំកូនពេញលេញ** ......... ២៤

១. តំណាងអយ្យការ ........ ២៤
២. ឪពុកម្ដាយបង្កើត ........ ២៤
៣. កូនសុំ ........ ២៥
**កថាភាគទី ៣. អានុភាពនៃការកាត់កាល់ស្មុំកូនពេញលេញ** ........ ២៥

## ជំពូកទី ៣
## ស្មុំកូនធម្មតា

**ផ្នែកទី ១. សញ្ញាណទូទៅនៃស្មុំកូនធម្មតា** ........ ២៦
**កថាភាគទី ១. និយមន័យ** ........ ២៦
**កថាភាគទី ២. លក្ខណៈពិសេសនៃស្មុំកូនធម្មតា** ........ ២៦
**ផ្នែកទី ២. លក្ខខណ្ឌនៃការបង្កើតស្មុំកូនធម្មតា** ........ ២៦
**កថាភាគទី ១. លក្ខខណ្ឌទាក់ទងនឹងបុគ្គលដែលនឹងក្លាយឪពុកម្ដាយចិញ្ចឹម** ........ ២៦
១. អាយុរបស់ឪពុកម្ដាយចិញ្ចឹម ........ ២៦
២. ស្ថានភាពរបស់ឪពុកម្ដាយចិញ្ចឹម ........ ២៧
**កថាភាគទី ២. លក្ខខណ្ឌទាក់ទងនឹងកូនសុំ** ........ ២៧
១. អាយុរបស់កូនសុំ ........ ២៧
២. ស្ថានភាពរបស់កូនសុំ ........ ២៧
**កថាភាគទី ៣. នីតិវិធីនៃការស្មុំកូនធម្មតា** ........ ២៨
១. ការដាក់ពាក្យសុំ ........ ២៨
២. អ្នកមានសិទ្ធិក្នុងការដាក់ពាក្យសុំ ........ ២៩
៣. ទម្រង់នៃការដាក់ពាក្យសុំ ........ ២៩
៤. ទីកន្លែងនៃការដាក់ពាក្យសុំ ........ ៣០
៥. ពន្ធដែលត្រូវបង់នៅពេលដាក់ពាក្យសុំ ........ ៣០
៦. មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតស្មុំកូនធម្មតា ........ ៣០
**កថាភាគទី ៤. ដីកាសម្រេច** ........ ៣០
**កថាភាគទី ៥. បណ្ដឹងជំទាស់** ........ ៣១
**ផ្នែកទី ៣. អានុភាពនៃស្មុំកូនធម្មតា** ........ ៣២

**កថាភាគទី ១. ការបង្កើតញាតិភាពរវាងឪពុកម្ដាយចិញ្ចឹម** ..................................................................៣២

**កថាភាគទី ២. ការបន្តញាតិភាពរវាងឪពុកម្ដាយបង្កើត**..........................................................................៣២

**ផ្នែកទី ៤. សិទ្ធិរបស់ស្មុំកូនធម៌តា** .................................................................................................. ៣២

**កថាភាគទី ១. សិទ្ធិក្នុងការជ្រើសរើសនាមត្រកូល** .............................................................................៣៣

**កថាភាគទី ២. សិទ្ធិស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្ដាយបង្កើត និងឪពុកម្ដាយចិញ្ចឹមរបស់កូនដែលជាអនីតិជន** .....................................................................................................................៣៣

**កថាភាគទី ៣. សិទ្ធិទទួលបានអាហារកាតព្វកិច្ចរបស់កូនដែលជាអនីតិជន**.................................៣៣

**កថាភាគទី ៤. សិទ្ធិធ្វើ និងទទួលសន្តតិកម្ម** ........................................................................................៣៣

**ផ្នែកទី ៥. ការកាត់កាល់ស្មុំកូនធម៌តា**...................................................................................................៣៤

**កថាភាគទី ១. លក្ខខណ្ឌនៃការកាត់កាល់ស្មុំកូនធម៌តា** ....................................................................... ៣៤

១. ការកាត់កាល់ស្មុំកូនធម្មតាតាមការព្រមព្រៀង................................................................................... ៣៤

២. ការកាត់កាល់ស្មុំកូនធម្មតាតាមពាក្យបណ្ដឹងរបស់ភាគីម្ខាង ................................................ ៣៥

**កថាភាគទី ២. មូលហេតុ និងការវិនិច្ឆ័យនៃការកាត់កាល់ស្មុំកូនធម៌តា**........................ ៣៦

**កថាភាគទី ៣. ពាក្យសុំឱ្យកាត់កាល់ស្មុំកូនធម៌តា**................................................................................... ៣៦

**កថាភាគទី ៤. អានុភាពនៃការកាត់កាល់ស្មុំកូនធម៌តា** .......................................................................... ៣៦

**សេចក្ដីសន្និដ្ឋាន**...................................................................................................................................៣៧

**អនុសាសន៍**.......................................................................................................................................... ៣៩

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

កុមារ គឺជាផ្នែកមួយយ៉ាងសំខាន់បំផុតរបស់សង្គម ហើយកុមារក៏ជាធនធានមនុស្សមួយដែលមិនអាចខ្វះបានក្នុងការអភិវឌ្ឍន៍ប្រទេសជាតិដែរ ប្រសិនបើធនធានមនុស្សប្រកបទៅដោយសក្តានុពលច្បាស់លាស់នោះនឹងធ្វើឱ្យប្រទេសជាតិ ទទួលបាននូវលទ្ធផលដ៏ល្អជាទីគាប់ប្រសើរនៅពេលអនាគត។ ដូច្នេះកុមារត្រូវតែទទួលបានការមើលថែយ៉ាងយកចិត្តទុកដាក់ពីសំណាក់គ្រួសារ ជាពិសេសឪពុកម្តាយនៃកុមារផ្ទាល់។ ទន្ទឹមនឹងនេះដែរក៏មានកុមារមួយចំនួនដែលខ្វះភាពកក់ក្តៅ តាមរយៈការខ្ជីខ្ជារបស់ឪពុកម្តាយ ឬមានការប៉ះទង្គិចខាងផ្លូវចិត្តដែលកើតមានឡើងតាមរូបភាពនៃការធ្វើបាបពីសំណាក់ឪពុកម្តាយ។ ផ្ទុយទៅវិញក៏មានគ្រួសារមួយចំនួនដែរដែលប្រាថ្នាចង់បាននូវបុត្រា និងបុត្រីដែលជារបស់ខ្លួនដើម្បីមកបំពេញលក្ខណៈជាគ្រួសារមួយដ៏ពេញលេញហើយមានសុភមង្គល ប៉ុន្តែពួកគាត់មិនអាចធ្វើការបង្កើតកូនដោយខ្លួនឯងបានដោយសារបញ្ហាផ្សេងៗដូចជាបញ្ហាសុខភាពដែលជាហេតុធ្វើឱ្យពួកគាត់បង្ខំចិត្តបោះបង់ចោលនូវគំនិតបង្កើតកូនដោយធម្មជាតិ ដោយប្តូរមកសុំកូនវិញ។ ដូច្នេះហើយទើបយើងសង្កេតឃើញមានគ្រួសារមួយចំនួន បានសុំកូនពីគ្រួសារដទៃទៀតដែលគ្មានលទ្ធភាពចិញ្ចឹមបីបាច់មើលថែរក្សាកូន ឬគ្រួសារដែលបានបោះបង់កូនចោល ដើម្បីយកមកធ្វើជាកូនបង្កើតរបស់ខ្លួន។ ដោយសារតែមានបញ្ហាទាំងនេះទើបរាជរដ្ឋាភិបាល ក៏ដូចជាក្រសួងដែលពាក់ព័ន្ធបានបង្កើតនូវច្បាប់ដែលស្តីពីសុំកូននៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ក្នុងគោលដៅជួយដល់កុមារដែលខ្វះភាពកក់ក្តៅ ជួយកាត់បន្ថយក្មេងកំព្រា និងជួយដល់ប្តីប្រពន្ធដែលត្រូវការបុត្រផងដែរ។

ជាការពិតណាស់ បញ្ហាពាក់ព័ន្ធនឹងការសុំកូនត្រូវបានចែងនៅក្នុងច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារតាំងពីយូរណាស់មកហើយ ប៉ុន្តែយើងសង្កេតឃើញថា ប្រជាពលរដ្ឋកម្ពុជាពុំទាន់ជ្រាបច្បាស់នៅឡើយថាអ្វីជាការសុំកូនដែលត្រូវបានទទួលស្គាល់ដោយច្បាប់។ ជារឿយៗ យើងតែងឃើញបុគ្គលដែលចង់ធ្វើការសុំកូន ភាគច្រើនគាត់ធ្វើការសុំកូនតាមរយៈការដោះដូរជាថវិកាជូនទៅភាគីឪពុកម្តាយបង្កើត ដើម្បីទទួលយកកូននោះមកធ្វើជាកូនចិញ្ចឹម ឬកូនសុំរបស់ខ្លួនដោយពុំបានអនុវត្តទៅតាមនីតិវិធីច្បាប់ឡើយ។ ចំពោះបុគ្គលខ្លះទៀត ធ្វើការសុំកូនក្នុងគោលបំណងទុច្ចរិត ដើម្បីយកកូនសុំនោះមកធ្វើជាអ្នកបម្រើខ្លួន និងខ្លះទៀតឈានដល់ការប្រើប្រាស់អំពើហិង្សាលើកូនសុំនោះទៀតផង។ បញ្ហាទាំងនេះតែងតែកើតមាន ដោយសារការយល់ដឹងរបស់ប្រជាពលរដ្ឋខ្មែរទាក់ទងនឹងការសុំកូននៅមានកម្រិតនៅឡើយ។

ពាក្យថា « សុំ » គឺបានមកពីពាក្យថា សុំ មានន័យថាការសុំរបស់អ្វីពីអ្នកដទៃ ដើម្បីយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ឬស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។ ចំណែកឯពាក្យថា « ការសុំកូន » យើងមិនឃើញមានពន្យល់នៅក្នុងវចនានុក្រមសម្តេចព្រះសង្ឃរាជជួនណាត ក៏ដូចជាសទ្ទានុក្រមផ្នែករដ្ឋប្បវេណីទេ។ ប៉ុន្តែបើយើងក្រឡេក

មើលទៅក្នុងច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ វិញនៅផ្នែកទី៤ ដែលបានចែងអំពីសុំកូន និងបានឱ្យនិយមន័យពាក្យថា « ការសុំកូន » នេះជាកិច្ចសន្យា ដែលចងបុគ្គល ២( ពីរ )នាក់ គឺម្នាក់ហៅថា ឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹម ហើយម្នាក់ទៀតហៅថាកូនចិញ្ចឹម ឱ្យមានចំណងនឹងគ្នាដូចជាបុត្តភាពមានខាន់ស្លា។ មានន័យថា ជាកិច្ចសន្យាដែលចងបុគ្គលដែលជាឪពុក ឬម្តាយចិញ្ចឹម និងកូនសុំឱ្យមានទំនាក់ទំនងនឹងគ្នា ដូចនឹងទំនាក់ទំនងរវាងឪពុកម្តាយ និងកូនបង្កើតដែរ។ ម៉្យាងវិញទៀត ក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជកម្ពុជាឆ្នាំ២០០៧ បានបញ្ញត្តិទាក់ទងនឹងសុំកូននេះមាន ២( ពីរ ) ប្រភេទគឺ សុំកូនពេញលេញ និងសុំកូនធម្មតា ហើយច្បាប់បានកំណត់ពីនីតិវិធីយ៉ាងត្រឹមត្រូវ និងច្បាស់លាស់នៅក្នុងការបង្កើតសុំកូនទាំងពីរនេះ។ ការបង្កើតសុំកូននេះ មិនថាសុំកូនពេញលេញ ឬសុំកូនធម្មតា គឺត្រូវធ្វើឡើងតាមរយៈតុលាការមានសមត្ថកិច្ច ដើម្បីសម្រេចពីការបង្កើតសុំកូននេះតាមរយៈសេចក្តីសម្រេចរបស់តុលាការមានសមត្ថកិច្ចនោះ។ ហេតុនេះហើយ តាមរយៈការចង្អុលបង្ហាញ និងជ្រោមជ្រែងពីសំណាក់សាស្ត្រាចារ្យណែនាំទើបខ្ញុំក្នុងនាមជានិស្សិតផ្នែកនីតិសាស្ត្រ និងប្រជាពលរដ្ឋកម្ពុជាមួយរូប បានលើកយកប្រធានបទស្តីពី « សុំកូននៅព្រះរាជាណាចក្រកម្ពុជា » នេះមកធ្វើការបកស្រាយ ដើម្បីឱ្យនិស្សិតដែលកំពុងសិក្សា និងនិស្សិតជំនាន់ក្រោយៗទៀត ក៏ដូចជាប្រជាពលរដ្ឋទូទៅបានយល់ពីបញ្ហាសុំកូននៅព្រះរាជាណាចក្រកម្ពុជាឱ្យបានកាន់តែច្បាស់ និងយល់ថាអ្វីខ្លះជាសិទ្ធិដែលកូនសុំអាចទទួលបានបន្ទាប់ពីការសុំកូនបានបង្កើតអានុភាពតាមច្បាប់ និងចូលរួមលុបបំបាត់ការសុំកូនដោយចេតនាទុច្ចរិត ដើម្បីការពារដល់សិទ្ធិរបស់កូនសុំគ្រប់រូប។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយផ្អែកទៅតាមរយៈការរៀបរាប់ខ្លះៗពីខាងលើ យើងបានដឹងហើយថាអ្វីទៅជាការសុំកូនដែលទទួលស្គាល់ដោយច្បាប់ ហើយការសុំកូននោះមានពីរប្រភេទ។ ប៉ុន្តែអ្វីដែលយើងត្រូវដឹងបន្ថែមទៀតនោះគឺ តើសុំកូនទាំងពីរនេះមានលក្ខណៈខុសគ្នាដូចម្តេចខ្លះ? ហើយតើមានលក្ខខណ្ឌកំណត់ដោយច្បាប់អ្វីខ្លះទើបគេអាចសុំកូនទាំងពីរប្រភេទនេះបាន? ក្រោយពីទទួលបានការអនុញ្ញាត និងទទួលបានសេចក្តីសម្រេចពីតុលាការរួច តើការសុំកូននោះមានអានុភាពយ៉ាងដូចម្តេច ហើយកូនសុំនោះមានសិ៦ ទ្ធិអ្វីខ្លះ? ប្រសិនបើទំនាក់ទំនងរវាងកូនសុំ និងឪពុកម្តាយចិញ្ចឹមមិនមានភាពចុះសម្រុងនឹងគ្នា ឬភាគីណាម្ខាងត្រូវរងទារុណកម្ម ឬអំពើហិង្សាពីសំណាក់ភាគីណាម្ខាងទៀត តើគេអាចកាត់កាល់សុំកូនទាំងពីរនេះបានដែរឬទេ? ដោយរបៀបណាខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះធ្វើឡើងក្នុងគោលបំណងចែករំលែកនូវពុទ្ធិ និងបង្ហាញឱ្យឃើញថាប្រធានបទមួយនេះពិតជាមានសារៈសំខាន់ខ្លាំងណាស់ដល់ប្រជាពលរដ្ឋក៏ដូចជាសិស្សនិស្សិត ក្នុងការសិក្សារៀនសូត្រស្វែងយល់បន្ថែម។ លើសពីនេះទៅទៀត យើងខ្ញុំចង់បញ្ចៀសនូវបញ្ហារំលោភសិទ្ធិកុមារ ការប្រើអំពើហិង្សា ការធ្វើទារុណកម្មទៅលើកុមារ និងការជួញដូរកុមារជាដើម។ ជាពិសេស ក្នុងគោលបំណងរួមចំណែកមួយដើម្បីជា

ជំនួយស្មារតីដល់ប្រជាពលរដ្ឋទាំងអស់ឱ្យយល់កាន់តែច្បាស់អំពីបញ្ហាសុំកូន អ្នកដែលអាចសុំកូនបាន អានុភាពគតិយុត្ត នីតិវិធីតាមរយៈសេចក្តីសម្រេចរបស់តុលាការ និងបញ្ឈប់ការសុំកូនដោយមិនមានការទទួលស្គាល់ដោយច្បាប់ក្នុងគោលបំណងទុច្ចរិត។ ជាងនេះទៅទៀត វាក៏អាចក្លាយជាទុនសម្រាប់និស្សិតជំនាន់ក្រោយៗក្នុងការសិក្សាស្វែងយល់ដើម្បីជាប្រយោជន៍ក្នុងការសិក្សាថ្នាក់នីតិសាស្ត្រនេះផងដែរ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ចំពោះប្រធានបទដែលយើងខ្ញុំបានលើកយកមកសិក្សាស្រាវជ្រាវនេះ គឺយើងខ្ញុំស្រាវជ្រាវ និងចងក្រងផ្តោតសំខាន់ទៅលើក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ រហូតមកដល់បច្ចុប្បន្នតែប៉ុណ្ណោះ ចំណែកឯច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ ក្រមរដ្ឋប្បវេណី ឆ្នាំ១៩៦៧ និងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ គ្រាន់តែជាសញ្ញាណខ្លីៗ ដែលជាករណីសិក្សាទេ។ ហើយចំណុចសំខាន់មួយចំនួនដែលយើងខ្ញុំយកមកសរសេរចងក្រងឡើងនោះមានដូចជា ៖

- ស្វែងយល់អំពីសញ្ញាណនៃរបបសុំកូន និងប្រភេទនៃរបបសុំកូននៅព្រះរាជាណាចក្រកម្ពុជា
- ស្វែងយល់អំពីលក្ខខណ្ឌ និងនីតិវិធីនៃការបង្កើតរបបសុំកូនទាំងពីរប្រភេទ
- ស្វែងយល់អំពីអានុភាពរបស់សុំកូន សិទ្ធិ និងការកាត់កាល់របបសុំកូន
- ស្វែងយល់អំពីភាពខុសគ្នារវាងសុំកូនទាំងពីរប្រភេទតែប៉ុណ្ណោះ ដោយមិនមានការបកស្រាយពីសុំកូនអន្តរប្រទេសឡើយ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទអ្វីមួយ ពិតជាមានការលំបាកណាស់ ព្រោះយើងត្រូវចំណាយពេលច្រើនរួមទាំងកម្លាំងកាយ និងកម្លាំងចិត្ត ជាពិសេសគឺត្រូវមានការព្យាយាមទៀតផងដែរទើបការសិក្សាស្រាវជ្រាវទទួលបានជោគជ័យ។ ទោះបីជាមានការលំបាកយ៉ាងណាក៏ដោយក៏យើងខ្ញុំនៅតែខិតខំតស៊ូព្យាយាមជម្នះឱ្យទាល់តែបាន ពីព្រោះការសិក្សាស្រាវជ្រាវប្រធានបទនេះគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់យើងខ្ញុំ និងសិស្សនិស្សិតទាំងអស់ដូចជា ៖

- ទទួលបានចំណេះដឹងថ្មីៗពាក់ព័ន្ធនឹងវិធីសាស្ត្រស្រាវជ្រាវ
- ទទួលបាននូវប្រភពឯកសារជាច្រើនដែលទាក់ទងនឹងប្រធានបទ
- យល់ដឹងកាន់តែលម្អិតទៅលើប្រធានបទដែលធ្វើការសិក្សាស្រាវជ្រាវ
- ចេះធ្វើការប្រៀបធៀបរវាងចំណុចខ្លាំង ខ្សោយ បញ្ហាប្រឈម និងដំណោះស្រាយ
- ធ្វើឱ្យកាន់តែច្បាស់បន្ថែមទៀតអំពីការរៀបប្រយោគ ឃ្លាឃ្លោង និងអក្ខរាវិរុទ្ធ

– ទទួលបានបទពិសោធន៍ល្អៗជាមួយអ្នកមានចំណេះដឹង និងអ្នកមានបទពិសោធន៍

– ជាពិសេសគឺបានបន្សល់នូវស្នាដៃទុកសម្រាប់សិស្សនិស្សិតជំនាន់ក្រោយបានសិក្សាស្រាវជ្រាវបន្តទៀត។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ចំពោះវិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ យើងខ្ញុំទាំងពីរនាក់បានខិតខំប្រើប្រាស់វិធីសាស្ត្រជាច្រើនដើម្បីយកមកសរសេរសារណានេះឡើង ដោយដកស្រង់ចេញពីខ្លឹមសារសំខាន់ៗនានាដែលប្រមូលបានពីលិខិតបទដ្ឋានគតិយុត្តជាតិដែលមានជាធរមាន សៀវភៅរបាយការណ៍នៅតាមបណ្ណាល័យនានាក្នុងរាជធានីភ្នំពេញ ធ្វើការស្រាវជ្រាវពីប្រព័ន្ធអ៊ីនធឺណែត ព្រមទាំងឯកសាររបស់សិស្សច្បងមួយចំនួន ដែលយើងខ្ញុំដាក់នៅក្នុងឧបសម្ព័ន្ធ និងឯកសារយោង។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងប្រធានបទនៃសារណាដែលយើងខ្ញុំធ្វើនេះ គឺឈរលើការបកស្រាយដោយផ្អែកលើឯកសារ និងបច្ចេកទេសនៃការអនុវត្តសុទ្ធសាធដែលស្តីពី ស្នុំនៅព្រះរាជាណាចក្រកម្ពុជា ក្នុងនោះយើងខ្ញុំបានបែងចែកជាបួនជំពូក និងផ្នែកធំៗដូចជា ៖

**ជំពូកទី ១ សញ្ញាណទូទៅនៃស្នុំកូន**

– ផ្នែកទី ១ ការស្នុំកូន

– ផ្នែកទី ២ ប្រភេទ និងសារៈសំខាន់នៃស្នុំកូន

**ជំពូកទី ២ ស្នុំកូនពេញលេញ**

– ផ្នែកទី ១ សញ្ញាណទូទៅនៃស្នុំកូនពេញលេញ

– ផ្នែកទី ២ លក្ខខណ្ឌនៃការបង្កើតស្នុំកូនពេញលេញ

– ផ្នែកទី ៣ អានុភាពនៃស្នុំកូនពេញលេញ

– ផ្នែកទី ៤ សិទ្ធិរបស់ស្នុំកូនពេញលេញ

– ផ្នែកទី ៥ ការកាត់កាល់ស្នុំកូនពេញលេញ

**ជំពូកទី ៣ ស្នុំកូនធម្មតា**

– ផ្នែកទី ១ សញ្ញាណទូទៅនៃស្នុំកូនធម្មតា

– ផ្នែកទី ២ លក្ខខណ្ឌនៃការបង្កើតស្នុំកូនធម្មតា

– ផ្នែកទី ៣ អានុភាពនៃស្នុំកូនធម្មតា

– ផ្នែកទី ៤ សិទ្ធិរបស់ស្នុំកូនធម្មតា

– ផ្នែកទី ៥ ការកាត់កាល់ស្នុំកូនធម្មតា

# ជំពូកទី ១
# សញ្ញាណទូទៅនៃសុំកូន

## ផ្នែកទី ១. ការសុំកូន

### កថាភាគទី ១. និយមន័យនៃសុំកូន

ពាក្យថា សុំកូន ត្រូវបានគេឱ្យនិយមន័យខុសៗគ្នាដូចខាងក្រោម ៖

តាមក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មិនមានមាត្រាណាមួយដែលបានចែងពីនិយមន័យនៃសុំកូនទេ ប៉ុន្តែបើយើងឈរលើខ្លឹមសារនៃបញ្ញត្តិដែលចែងពីសុំកូន គឺយើងអាចទាញនិយមន័យនៃសុំកូនបានថា គឺជារបបមួយដែលទទួលស្គាល់ឱ្យជនដែលគ្មានទំនាក់ទំនងសាច់ញាតិបង្កើតនូវទំនាក់ទំនងឪពុកម្ដាយ និងកូនដូចជាឪពុកម្ដាយ និងកូនបង្កើតដែរ។

ចំណែកឯមាត្រា១០៨ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ ចែងថាសុំកូន គឺជាកិច្ចសន្យាដែលចងបុគ្គលពីរនាក់ គឺម្នាក់ហៅថាឪពុកចិញ្ចឹម ឬម្ដាយចិញ្ចឹម ហើយម្នាក់ទៀតហៅថាកូនចិញ្ចឹមឱ្យមានចំណងនឹងគ្នាដូចជាបុគ្គភាពមានភាពខាន់ស្លា។

បើយើងក្រឡេកទៅមើលក្រមរដ្ឋប្បវេណី ឆ្នាំ១៩៦៧ មាត្រា៣១៥ បានចែងថាសុំកូន គឺជាកិច្ចសន្យាមួយយ៉ាងឱឡារិកដែលចងបុគ្គលពីរ គឺម្នាក់ហៅថាឪពុកសុំ ហើយម្នាក់ទៀតហៅថាកូនសុំ ឱ្យមានចំណងទាក់ទងគ្នាដូចជាបុគ្គភាពមានខាន់ស្លាដែរ។

### កថាភាគទី ២. គោលបំណងនៃការសុំកូន

ការសុំកូន គឺមានគោលបំណងជួយកុមារដែលគ្មានទីពឹង កុមារដែលខ្វះភាពកក់ក្ដៅ កុមារដែលទទួលរងនូវការរំលោភបំពានមិនបានទទួលការអប់រំរៀនសូត្រ ដើម្បីផ្ដល់ឱ្យកុមារទាំងនោះទទួលបាននូវការការពារ ការយកចិត្តទុកដាក់ និងដើម្បីស្វែងរកឪពុកម្ដាយថ្មីដែលអាចចិញ្ចឹមបីបាច់ថែរក្សា ទទួលបាននូវការរៀនសូត្រ ផ្ដល់នូវសេវាសុខភាព ពោលគឺការគោរពសិទ្ធិជាមូលដ្ឋានរបស់កុមារ។ ម៉្យាងវិញទៀត ការសុំកូននេះក៏មានគោលបំណងដើម្បីជួយដល់សហព័ទ្ធដែលមិនអាចមានកូន និងដើម្បីស្នងមរតក ឬអាជីវកម្ម ឬក៏គ្មានកូនសម្រាប់ចិញ្ចឹមមើលថែនៅពេលដែលខ្លួនចាស់ទៅ។

### កថាភាគទី ៣. លក្ខណៈពិសេសនៃការសុំកូន

យោងតាមក្រមរដ្ឋប្បវេណី សុំកូនក្នុងប្រទេសអាចជាសុំកូនពេញលេញ និងសុំកូនធម្មតា។ តាមការពិតសុំកូនបង្កើតឱ្យមានទំនាក់ទំនងញាតិរវាងកូនសុំ និងឪពុកម្ដាយចិញ្ចឹម ព្រមទាំងញាតិលោហិតរបស់ឪពុកម្ដាយ

ចិញ្ចឹមផងដែរ។ ជាពិសេសញាតិភាពនេះត្រូវបានចាត់ទុកដូចគ្នាទៅនឹងញាតិលោហិតផងដែរ។ [1] មិនតែប៉ុណ្ណោះកូនសុំមានសិទ្ធិ និងករណីយកិច្ចដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមដែរ។ [2] ចំពោះលក្ខណៈពិសេសនៃស្មុំកូន គឺតម្រូវឱ្យបំពេញនូវលក្ខខណ្ឌមួយចំនួន ដូចជាការបង្កើតដោយពាក់ព័ន្ធទៅលក្ខខណ្ឌចំពោះឪពុកម្តាយចំពោះកូនសុំ បន្ទាប់មកគឺអានុភាពទៅលើការសុំ សិទ្ធិរបស់កូនសុំ ជាចុងក្រោយគឺការកាត់កាល់។

## ផ្នែកទី ២. ប្រភេទ និងសារៈសំខាន់នៃស្មុំកូន

### កថាភាគទី ១. ប្រភេទនៃស្មុំកូន

ដោយយោងតាមក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជាស្មុំកូនត្រូវបានបែងចែកជាពីរ គឺស្មុំកូនពេញលេញ និងស្មុំកូនធម្មតា។ ស្មុំកូនទាំងពីរប្រភេទនេះមានលក្ខខណ្ឌ និងអានុភាពខុសៗគ្នា ដូចជា ៖

**ស្មុំកូនពេញលេញ ៖** ស្មុំកូនពេញលេញមានលក្ខខណ្ឌក្នុងការបង្កើតតឹងរឹងជាងស្មុំកូនធម្មតា ដោយស្មុំកូននេះអាចបង្កើតបានចំពោះតែកុមារតូចៗ ដែលជាគោលការណ៍មានអាយុតិចជាង ៨( ប្រាំបី )ឆ្នាំ និងអាចបង្កើតបានចំពោះតែបុគ្គលដែលមានសហព័ទ្ធប៉ុណ្ណោះ ហេតុនេះហើយបុគ្គលដែលមិនទាន់មានសហព័ទ្ធ មិនអាចបង្កើតស្មុំកូនពេញលេញបានទេ។ ស្មុំកូនពេញលេញមានអានុភាពបង្កើតនូវញាតិថ្មី ប៉ុន្តែត្រូវកាត់ផ្តាច់ទំនាក់ទំនងជាមួយនឹងញាតិលោហិត ពោលគឺបង្កើតនូវទំនាក់ទំនងញាតិរវាងកូនសុំ និងឪពុកម្តាយចិញ្ចឹមព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹម ដោយតម្រូវឱ្យកូនសុំកាត់ផ្តាច់ទាំងស្រុងនូវទំនាក់ទំនងញាតិរវាងកូនសុំ និងឪពុកម្តាយបង្កើតព្រមទាំងញាតិលោហិតទាំងអស់របស់ឪពុកម្តាយបង្កើត។

**ស្មុំកូនធម្មតា ៖** ស្មុំកូនធម្មតាអាចបង្កើតបានទាំងអនីតិជន និងនីតិជន គ្រាន់តែតម្រូវឱ្យអ្នកសុំនោះមានអាយុចាប់ពី ២៥( ម្ភៃប្រាំ )ឆ្នាំ ឡើងទៅតែប៉ុណ្ណោះ និងត្រូវមានអាយុច្រើនជាងកូនសុំ។ ស្មុំកូនធម្មតាវិញមានអានុភាពបង្កើតនូវញាតិថ្មី ពោលគឺបន្ថែមនូវញាតិថ្មីដោយមិនតម្រូវឱ្យកាត់ផ្តាច់នូវទំនាក់ទំនាក់ញាតិជាមួយនឹងឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតទេ ពោលគឺញាតិភាពរវាងកូនសុំ និងឪពុកម្តាយបង្កើតនៅតែបន្ត។ [3]

[1] មើលមាត្រា៩៨០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[2] មើលមាត្រា១០២៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[3] មើលមាត្រា១០២៦.១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

## កថាភាគទី ២. សារៈសំខាន់នៃសុំកូន

### ១. សារៈសំខាន់នៃសុំកូនពេញលេញ

កូនសុំពេញលេញបានបង្កើតនូវទំនាក់ទំនងអចិន្ត្រៃយ៍ជាមួយឪពុកម្ដាយចិញ្ចឹម គឺកូនសុំមានឋានៈ និងសិទ្ធិដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្ដាយចិញ្ចឹមដែរ។ ការបង្កើតកូនសុំពេញលេញនេះគឺអាចជួយដល់កុមារឱ្យគេចផុតពីភាពរស់នៅលំបាកក្រីក្រ កុមារដែលទទួលរងនូវអំពើហឹង្សាពីសំណាក់ឪពុកម្ដាយបង្កើតដោយជំនួសមកវិញនូវមជ្ឈដ្ឋានថ្មីដែលមានឪពុកម្ដាយចិញ្ចឹមចាំផ្ដល់នូវភាពកក់ក្ដៅ មើលថែទាំ និងផ្គត់ផ្គង់ឱ្យកូនសុំមានអនាគតល្អ។ ពិសេសជាងនេះទៅទៀតរបបសុំកូនពេញលេញនេះគឺមានការទទួលស្គាល់ដោយច្បាប់។

### ២. សារៈសំខាន់នៃសុំកូនធម្មតា

ចំពោះករណីសុំកូនធម្មតាវិញ កូនសុំ និងឪពុកម្ដាយបង្កើតមានសិទ្ធិទាមទារករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច និងមានសិទ្ធិធ្វើសន្តិកម្មឱ្យគ្នាទៅវិញទៅមក។ មានន័យថាចំណងទាក់ទងរវាងកូនសុំ និងឪពុកម្ដាយបង្កើតមិនត្រូវបានកាត់ផ្ដាច់ឡើយ។ ក្រោយពីបញ្ចប់នីតិវិធីសុំកូនធម្មតារួច កូនសុំក៏មានឋានៈ និងសិទ្ធិដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្ដាយចិញ្ចឹមដែរ។ របបសុំកូនធម្មតានេះគឺមានការទទួលស្គាល់ដោយច្បាប់។

# ជំពូកទី ២

# សុំកូនពេញលេញ

## ផ្នែកទី ១. សញ្ញាណទូទៅនៃសុំកូនពេញលេញ

### កថាភាគទី ១. និយមន័យ

សុំកូនពេញលេញ គឺសម្តៅដល់ការសុំអនីតិជនដែលមានអាយុក្រោម ៨( ប្រាំបី )ឆ្នាំ យកធ្វើជាកូនសុំដោយបញ្ចប់ញាតិភាពជាមួយញាតិលោហិតនៃឪពុកម្តាយបង្កើតហើយការសុំនេះត្រូវសម្រេចដោយតុលាការ។[4] ពោលការសុំកូនពេញលេញ គឺជាការបង្កើតទំនាក់ទំនងឪពុកម្តាយនឹងកូនជាមួយឪពុកម្តាយចិញ្ចឹម និងបញ្ចប់ទំនាក់ទំនងឪពុកម្តាយបង្កើតនឹងកូន ព្រមទាំងបញ្ចប់ញាតិលោហិតនៃឪពុកម្តាយបង្កើត រួមទាំងសិទ្ធិនិងកាតព្វកិច្ចរវាងកុមារ និងឪពុកម្តាយបង្កើត ឬអាណាព្យាបាលកុមារ ហើយការសុំនេះត្រូវធ្វើតាមសេចក្តីសម្រេចរបស់តុលាការតាមនីតិវិធីច្បាប់។

សរុបសេចក្តីមក របបសុំកូនពេញលេញ គឺតម្រូវឱ្យមានការកាត់ផ្តាច់រាល់ទំនាក់ទំនងគតិយុត្តិទាំងអស់រវាងកុមារ និងឪពុកម្តាយបង្កើត ឬអាណាព្យាបាលរបស់ខ្លួន រួចបង្កើតទំនាក់ទំនងថ្មីជាមួយនឹងឪពុកម្តាយចិញ្ចឹមវិញ។ លើសពីនេះទៅទៀត អានុភាពនៃកូនសុំត្រូវមានឋានៈដូចគ្នាទៅនឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមដែរ និងត្រូវទទួលបាននូវរាល់សិទ្ធិ និងករណីយកិច្ចដូចគ្នាទៅនឹងកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយឪពុកម្តាយចិញ្ចឹម។

### កថាភាគទី ២. គោលបំណងនៃការបង្កើតសុំកូនពេញលេញ

សុំកូនពេញលេញ គឺជារបបសម្រាប់ផ្តល់នូវគ្រួសារសុខដុមរមនាមួយដែលមានទាំងម្តាយ ទាំងឪពុកចំពោះកុមារអភ័ព្វ ក្នុងគោលបំណងចិញ្ចឹមកូននោះឱ្យមានស្នេហភាព និងសុខភាពល្អ ហើយក៏ជារបបមួយប្រហាក់ប្រហែលនឹងទំនាក់ទំនងឪពុកម្តាយបង្កើត ដែលខុសពីសុំកូនធម្មតា។ របបសុំកូនពេញលេញក្នុងក្រមរដ្ឋប្បវេណីកម្ពុជា គឺមានគោលគំនិតបង្កើតទំនាក់ទំនងរវាងឪពុកម្តាយនឹងកូនឱ្យដូចទំនាក់ទំនងរវាងឪពុកម្តាយនឹងកូនបង្កើតដែរ ហេតុនេះហើយពេលដែលបានសុំកូនមានអានុភាពទំនាក់ទំនងរវាងឪពុកម្តាយនឹងកូនបង្កើតត្រូវរលត់តាមផ្លូវច្បាប់។

## ផ្នែកទី ២. លក្ខខណ្ឌនៃការបង្កើតសុំកូនពេញលេញ

ការបង្កើតរបបសុំកូនពេញលេញ ត្រូវធ្វើឡើងតាមសេចក្តីសម្រេចរបស់តុលាការក្រោមលក្ខខណ្ឌយ៉ាងតឹងរឹង ដែលមានលក្ខខណ្ឌខុសពីសុំកូនធម្មតា ដែលត្រូវធ្វើតាមទម្រង់កិច្ចសន្យា និងកើតឡើងដោយការព្រម

[4] សន្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧។

ព្រៀងរវាងឪពុកម្តាយបង្កើតរបស់កូនសុំ ឬអាណាព្យាបាលរបស់កូនសុំ និងអ្នកដាក់ពាក្យសុំ។ ដោយឡែកសុំកូនពេញលេញ កំណត់យកអនីតិជនដែលមានស្ថានភាពគ្រួសារមិនអំណោយផលធ្វើជាកម្មវត្ថុ ដោយតម្រូវឱ្យមានការស្រាវជ្រាវ និងវិនិច្ឆ័យអំពីផលប្រយោជន៍របស់កុមារ និងទំនាក់ទំនងដែលមានលក្ខណៈដូចកូនបង្កើតផងដែរ ហេតុនេះនៅពេលបង្កើតឱ្យមានសុំកូនពេញលេញត្រូវបំពេញលក្ខខណ្ឌទាំងឡាយដូចខាងក្រោម ៖

**កថាភាគទី ១. លក្ខខណ្ឌទាក់ទងនឹងបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម**

បើយោងទៅតាមក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ការសុំកូនពេញលេញអាចប្រព្រឹត្តទៅបានលុះត្រាតែឪពុកម្តាយចិញ្ចឹមទាំងពីរមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទៅតាមលក្ខខណ្ឌដែលបានកំណត់ ហើយត្រូវមានសេចក្តីសម្រេចរបស់តុលាការឱ្យមានការសុំកូនពេញលេញនោះទើបការសុំកូនកើតចេញជារូបរាងបាន ហើយលក្ខខណ្ឌទាំងនោះមានដូចជា ៖

**១. អាយុរបស់ឪពុកម្តាយចិញ្ចឹម**

ដោយសារការបង្កើតសុំកូនពេញលេញ គឺជាការផ្តល់គ្រួសាមួយដ៏ពេញលេញ ដូច្នេះអាយុរបស់ឪពុកម្តាយចិញ្ចឹមក៏ជាលក្ខខណ្ឌចម្បង ដែលតុលាការត្រូវពិនិត្យពិចារណាផ្ទៀងផ្ទាត់ឱ្យបានល្អិតល្អន់។ ដូចនេះទើបក្រមរដ្ឋប្បវេណីបានកំណត់លក្ខខណ្ឌច្បាស់លាស់អំពីអាយុអប្បបរមារបស់ឪពុកម្តាយចិញ្ចឹម និងគម្លាតអប្បបរមារវាងឪពុកម្តាយចិញ្ចឹម និងកូនសុំ។

អាយុឪពុកម្តាយចិញ្ចឹមត្រូវកំណត់អប្បរមា ២៥( ម្ភៃប្រាំ )ឆ្នាំ ហើយគម្លាតគ្នារវាងអាយុនៃឪពុកម្តាយ និងអាយុរបស់កូនសុំគឺ ២០( ម្ភៃ )ឆ្នាំ ដើម្បីបង្ហាញពីភាពចាស់ទុំផ្នែកស្មារតី និងរាងកាយក្នុងការបីបាច់ថែរក្សាទារក ឬកូនក្មេង ហេតុនេះហើយទើបច្បាប់មានការកំណត់យ៉ាងតឹងរឹងចំពោះលក្ខខណ្ឌនៃអាយុរបស់ឪពុកម្តាយដែលសុំកូនពេញលេញនេះ។[5]

ម៉្យាងវិញទៀតលក្ខខណ្ឌមួយនេះ គឺតម្រូវឱ្យមានភាពសមស្របរវាងលក្ខខណ្ឌអ្នកដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម និងអ្នកដែលនឹងក្លាយជាកូនសុំ ដែលអាចឱ្យពួកគេមានគម្លាតអាយុដ៏សមរម្យដូចទៅនឹងឪពុកម្តាយ និងកូនបង្កើតដែរ។ ហេតុនេះចំពោះឪពុកម្តាយចិញ្ចឹមដែលមានអាយុ ២៥( ម្ភៃប្រាំ )ឆ្នាំ អាចសុំកូនដែលមានអាយុតិចជាង ៥( ប្រាំ )ឆ្នាំ ដែលមានអាយុតិចជាងឪពុកម្តាយចិញ្ចឹមយ៉ាងតិចណាស់ ២០( ម្ភៃ )ឆ្នាំ។

**ឧទាហរណ៍ ៖** លោកស្រី សុភាព និងលោក សារី បានរៀបការជាមួយគ្នាអស់រយៈពេល ៥ ឆ្នាំ មកហើយ តែពួកគេមិនមានកូនជាមួយគ្នាឡើយ។ លោកស្រី សុភាព មានអាយុ ២៥( ម្ភៃប្រាំ ) ឆ្នាំ ចំណែកលោក សារី មានអាយុ ៣០( សាមសិប ) ឆ្នាំ។ ដោយអ្នកទាំងពីរមានបំណងចង់សុំក្មេងម្នាក់ដែលមានអាយុ ៧( ប្រាំពីរ ) ឆ្នាំ មកចិញ្ចឹមធ្វើជាកូនសុំពេញលេញ។ ក្នុងករណីបែបនេះ លោកស្រី សុភាព និងលោក សារី សុទ្ធតែមានអាយុចាប់ពី

[5] មើលមាត្រា១០០៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

២៥( ម្ភៃប្រាំ )ឆ្នាំ ដែលអាចសុំកូនអ្នកដទៃមកចិញ្ចឹមបាន រីឯលោក សារី មានអាយុ ៣០( សាមសិប )ឆ្នាំ ពោល គឺមានអាយុលើសក្មេងដែលនឹងក្លាយជាកូនសុំចំនួន ២៣( ម្ភៃបី )ឆ្នាំ ក៏ប៉ុន្តែលោកស្រី សុភាព មានអាយុលើស ក្មេងដែលនឹងក្លាយជាកូនសុំត្រឹមតែ ១៧( ដប់ប្រាំពីរ )ឆ្នាំ ប៉ុណ្ណោះ។ ដូចនេះលោកស្រី សុភាព មិនបានបំពេញ លក្ខខណ្ឌដែលតម្រូវតាមមាត្រា១០០៩ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។ មានន័យថា អ្នកទាំងពីរមិនអាចក្លាយ ជាឪពុកម្តាយចិញ្ចឹម តាមរយៈសុំកូនពេញលេញចំពោះក្មេងដែលមានអាយុ ៧( ប្រាំពីរ )ឆ្នាំ បានឡើយ។ ផ្ទុយ ទៅវិញ អ្នកទាំងពីរអាចធ្វើការសុំក្មេងដែលមានអាយុ ៥( ប្រាំ )ឆ្នាំ យកមកធ្វើកូនចិញ្ចឹមបាន។

## ២. ភាពមានសហព័ទ្ធ និងសហការរបស់ឪពុកម្តាយចិញ្ចឹម

បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម គឺត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ។ ដូច្នេះបុគ្គលដែលនៅ លីវមិនអាចក្លាយជាឪពុកម្តាយចិញ្ចឹមនៃកូនសុំពេញលេញបានឡើយ។ ការសុំកូនពេញលេញនេះអាចកើតមាន ឡើង លុះត្រាតែមានការសហការ និងឯកភាពថាយល់ព្រមរវាងប្តីប្រពន្ធ បើមិនដូច្នេះទេប្តី ឬប្រពន្ធតែម្ខាងមិន អាចក្លាយជាឪពុក ឬម្តាយចិញ្ចឹមគេបានឡើយ។ [6]

ជាបដិបញ្ញត្តិ ត្រូវលើកលែងចំពោះករណីសុំកូនរបស់សហព័ទ្ធ ៖

ដោយយោងតាមមាត្រា១០០៨ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ប្តី ឬប្រពន្ធតែម្ខាងពុំអាច ក្លាយជាឪពុក ឬម្តាយចិញ្ចឹមបានឡើយ ប្រសិនបើសហព័ទ្ធម្ខាងទៀតមិនក្លាយជាម្តាយ ឬឪពុកចិញ្ចឹម។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលប្តីប្រពន្ធណាម្ខាង ក្លាយជាឪពុក ឬម្តាយចិញ្ចឹមរបស់ កូនបង្កើតនៃសហព័ទ្ធម្ខាងទៀត។ ក្នុងករណីនេះ ប្រសិនបើសហព័ទ្ធតែម្ខាងចង់សុំកូនរបស់សហព័ទ្ធម្ខាងទៀត មកធ្វើជាកូនសុំ នោះគឺពុំបាច់មានការយល់ព្រមពីសហព័ទ្ធម្ខាងទៀតឡើយ ពោលគឺករណីដែលអនាគតកូន ចិញ្ចឹមត្រូវក្លាយជាកូនចុង ហេតុនេះសុំកូននេះមិនចាំបាច់មានការសហការរវាងប្តី ប្រពន្ធនោះទេ។

**ឧទាហរណ៍ ៖** លោកស្រី ចិន្តា ជាស្ត្រីមេម៉ាយកូនម្នាក់ឈ្មោះ ភក្តី ដែលមានអាយុ ៥( ប្រាំ )ឆ្នាំ។ នៅឆ្នាំ ២០១៣ លោកស្រី ចិន្តា បានសម្រេចចិត្តរៀបអាពាហ៍ពិពាហ៍ជាមួយនឹងបុរសម្នាក់គឺលោក សុខជា។ ក្រោយពី រៀបការរួចហើយ លោក សុខជា មានបំណងបង្កើតសុំកូនពេញលេញជាមួយនឹង ភក្តី ដែលជាកូនរបស់លោក ស្រី ចិន្តា។ នៅក្នុងករណីបែបនេះ លោកស្រី ចិន្តា គេជាម្តាយបង្កើតរបស់ ភក្តី ទៅហើយដូចនេះលោកស្រី ចិន្តា មិនអាចក្លាយជាម្តាយចិញ្ចឹមរបស់ ភក្តី នោះទេ។ ហេតុដូច្នេះហើយ ក្រមរដ្ឋប្បវេណីអនុញ្ញាតឱ្យលោក សុខជា តែ ម្នាក់ឯងអាចក្លាយជាឪពុកចិញ្ចឹមរបស់ ភក្តី បាន។

[6] មើលមាត្រា១០០៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

## កថាភាគទី ២. លក្ខខណ្ឌទាក់ទងនឹងកូនសុំ

ដោយយោងតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ មាត្រា១១០ ក៏បានកំណត់ពីរបបនៃការសុំកូនផងដែរ រួមទាំងចំនួនកុមារដែលត្រូវក្លាយជាកូនសុំ គឺជាគោលការណ៍គេអាចសុំកូនបានត្រឹមពីរនាក់ប៉ុណ្ណោះ ដោយក្នុងមួយដងបានតែមួយនាក់ប៉ុណ្ណោះ។ ប្រសិនបើក្នុងករណីដែលកូនសុំនោះមានមួយណាស្លាប់ គេអាចសុំកូនមួយនាក់ទៀតបាន។ ផ្ទុយមកវិញបើយើងក្រឡេកមកមើលក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ វិញយើងមិនបានឃើញមានមាត្រាណាមួយដែលបានកំណត់អំពីចំនួននៃកូនសុំទេ។

### ១. អាយុរបស់កូនសុំ

ជាគោលការណ៍ កូនសុំត្រូវមានអាយុតិចជាង ៨( ប្រាំបី )ឆ្នាំ។[7] ដោយមាត្រានេះមិនបានកម្រិតពីអាយុកូនសុំមិនឱ្យលើសពី ៨( ប្រាំបី )ឆ្នាំ នោះទេ ព្រោះថារបបសុំកូនពេញលេញនេះ គឺតម្រូវឱ្យកូនសុំផ្តាច់នូវរាល់ទំនាក់ទំនងទាំងអស់ជាមួយឪពុកម្តាយបង្កើតព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើត ហើយត្រូវបង្កើតចំណងគតិយុត្តិមួយថ្មីទៀតជាមួយឪពុកម្តាយចិញ្ចឹម ដោយកូនសុំនោះត្រូវស្ថិតនៅក្រោមការគ្រប់គ្រងមើលថែរក្សាពីសំណាក់ឪពុកម្តាយចិញ្ចឹមទាំងស្រុង។ ចំពោះចំណុចនេះ បើគេអនុញ្ញាតឱ្យកូនសុំមានអាយុច្រើនពេកនោះ ពេលខ្លះវាអាចបង្កឱ្យមានផលវិបាកដល់ឪពុកម្តាយចិញ្ចឹម។

### ២. ស្ថានភាពរបស់កូនសុំ

តុលាការនឹងពិនិត្យទៅលើទិដ្ឋភាពកុមារ ក្នុងករណីកុមារមាន ៖

- មានភាពលំបាកខ្លាំង : ឪពុកម្តាយកុមារមានភាពក្រីក្រខ្លាំង ឬមានជម្ងឺផ្នែកស្មារតីធ្ងន់ធ្ងរ ឬកំពុងបាត់ខ្លួន ជាអាទិ៍។
- ការគ្រប់គ្រងកុមារមិនសមរម្យពីសំណាក់ឪពុកម្តាយ : អាចនឹងមានការបំពានដល់ផ្លូវចិត្ត ឬផ្លូវកាយតាមរយៈពាក្យសម្តី ឬកាយវិការអាចជាការមិនយកចិត្តទុកដាក់ក្នុងការមើលថែកុមារជាដើម។
- ភាពចាំបាច់ដើម្បីផលប្រយោជន៍កូន : អាចឱ្យកុមារមានភាពល្អប្រសើរទាំងផ្លូវចិត្ត និងផ្លូវកាយ និងការផ្គត់ផ្គង់ចាំបាច់ដល់កុមារបានល្អជាងឪពុកម្តាយបង្កើត។

## កថាភាគទី ៣. លក្ខខណ្ឌផ្សេងៗ

ដើម្បីបង្កើតសុំកូនពេញលេញបាន ត្រូវមានការយល់ព្រមពីឪពុកម្តាយបង្កើត ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន របស់កុមារដែលនឹងក្លាយជាកូនសុំនោះ។ លើកលែងតែក្នុងករណីឪពុកម្តាយបង្កើតរបស់កូនសុំនោះមិនអាចបង្ហាញឆន្ទៈបាន ឬមានករណីដែលមានការធ្វើបាបដោយឪពុកម្តាយបង្កើត ការបោះបង់កូនដោយ

[7] មាត្រា១០១០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

គំនិតទុច្ចរិត ឬហេតុផលផ្សេងៗទៀតដែលបំពានដល់ផលប្រយោជន៍របស់កុមារ ដែលនឹងក្លាយជាកូនសុំនោះយ៉ាងធ្ងន់ធ្ងរ។ [8] ដូច្នេះហើយក្នុងករណីនេះស្មុំកូនពេញលេញអាចបង្កើតបាន ដោយមិនចាំបាច់មានការយល់ព្រមពីឪពុកម្តាយបង្កើតឡើយ។ ការយល់ព្រមរបស់ឪពុកម្តាយបង្កើតអាចដកវិញនៅពេលណាក៏បាន មុនពេលដីកាសម្រេចបង្កើតស្មុំកូនពេញលេញចូលជាស្ថាពរ ក្នុងករណីឪពុកម្តាយបង្កើតរបស់កូនសុំបានដកនូវការយល់ព្រមតុលាការត្រូវលើកចោលពាក្យសុំបង្កើតនូវស្មុំកូនពេញលេញបាន លើកលែងតែការដកការយល់ព្រមនោះបំពានដល់ផលប្រយោជន៍ធ្ងន់ធ្ងររបស់កូនសុំនោះ។

**ឧទាហរណ៍ ៖** លោក បូរ៉ា និងលោកស្រី បូប្ផា មានកូនចំនួន ៥ នាក់។ ដោយសារតែកង្វះខាតក្នុងជីវភាពអ្នកទាំងពីរក៏បានសម្រេចចិត្តឱ្យកូនទាំង ៥ នាក់ ដែលសុទ្ធតែអនីតិជនដើរសុំទានយកប្រាក់មកចិញ្ចឹមពួកគេ ហើយមិនបានឱ្យកូនរបស់ពួកគេទៅរៀនសូត្រនៅសាលារៀនឡើយ។ ក្នុងករណីនេះដែរតុលាការអាចចាត់ទុកថាជាការបំពានដល់ផលប្រយោជន៍របស់កូនទាំង ៥ នាក់ យ៉ាងធ្ងន់ធ្ងរ មានន័យថាតុលាការអាចបង្កើតស្មុំកូនពេញលេញបានទោះបីជាពុំមានការយល់ព្រមពីអ្នកទាំងពីរដែលជាឪពុកម្តាយបង្កើតក៏ដោយ។

ការអនុវត្តស្មុំកូនពេញលេញអាចធ្វើទៅបាន លុះត្រាតែតុលាការយល់ឃើញថាមានការពិបាកយ៉ាងខ្លាំង ឬមិនសមរម្យក្នុងការគ្រប់គ្រងថែរក្សាកុមារ ដែលនឹងក្លាយជាកូនសុំដោយឪពុកម្តាយបង្កើត ឬមានស្ថានភាពពិសេសផ្សេងៗទៀត ដែលតុលាការយល់ឃើញថាមានភាពចាំបាច់ត្រូវបង្កើតស្មុំកូនពេញលេញ ដើម្បីផលប្រយោជន៍របស់កុមារ ។ [9] ស្ថានភាពទាំងនោះមានដូចជា ៖

- ករណីដែលឪពុកម្តាយបាត់ខ្លួន
- ការមានវិបត្តិផ្នែករាងកាយ
- មានជីវភាពក្រីក្រខ្លាំងដែលមិនអាចចិញ្ចឹមបីបាច់ថែរក្សាកូនបានល្អ
- ធ្វើបាបកូន ឬបោះបង់កូនចោល។

បន្ថែមពីនេះទៅទៀត ស្មុំកូនពេញលេញមានអានុភាពតាមច្បាប់ លុះត្រាតែបានបង្កើតតាមផ្លូវតុលាការ គឺមានន័យថាបុគ្គលដែលមានបំណងបង្កើតស្មុំកូនពេញលេញ ត្រូវតែដាក់ពាក្យសុំទៅតុលាការ ដោយបំពេញតាមលក្ខខណ្ឌខាងលើ ហើយប្រសិនបើតុលាការយល់ស្របតុលាការនឹងចេញដីកាសម្រេចបង្កើតរបបស្មុំកូនពេញលេញ បន្ទាប់មកនៅពេលដីកាសម្រេចចូលជាស្ថាពររបបស្មុំកូនពេញលេញនេះនឹងត្រូវបង្កើតឡើងទៅតាមផ្លូវច្បាប់។

[8] មាត្រា១០១១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[9] មើលមាត្រា១០១២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

**កថាខណ្ឌទី ៤. នីតិវិធីនៃការសុំកូនពេញលេញ**

ដំណើរនីតិវិធីនៃការសុំកូន មានន័យថាជានីតិវិធីក្នុងការដាក់ពាក្យសុំទៅតុលាការ និងការទទួលដីកាសម្រេចពីតុលាការក្នុងការអនុញ្ញាតឱ្យសុំកូន។

**១. ការដាក់ពាក្យសុំ**

ដើម្បីបង្កើតសុំកូនពេញលេញបាន គឺត្រូវធ្វើតាមរយៈពាក្យសុំរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមត្រូវដាក់ពាក្យសុំរួមគ្នាដោយសហការរវាងប្ដីប្រពន្ធទៅតុលាការដែលមានសមត្ថកិច្ច។ ក្នុងករណីដែលប្ដី ឬប្រពន្ធតែម្ខាងជាអ្នកដាក់ពាក្យសុំបង្កើតសុំកូនទៅតុលាការ នោះតុលាការត្រូវលើកចោលពាក្យសុំដោយដីកាសម្រេច ព្រោះជាពាក្យសុំដែលផ្ទុយនឹងច្បាប់។

**២. អ្នកមានសិទ្ធិក្នុងការដាក់ពាក្យសុំ**

យោងតាមមាត្រា១៦ នៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង បុគ្គលដែលអាចដាក់ពាក្យសុំត្រូវតែជាជនពាក់ព័ន្ធដែលអាចក្លាយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។ បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម គឺជាបុគ្គលដែលមានសិទ្ធិតាមបញ្ញត្តិសារធាតុក្នុងការដាក់ពាក្យសុំ។ នៅក្នុងពាក្យសុំចាប់ផ្ដើមរបបសុំកូនពុំចាំបាច់មានការដាក់ពាក្យរួមគ្នាជាមួយឪពុកម្ដាយបង្កើតរបស់កូនសុំទេ។ ចំណែកឯលក្ខខណ្ឌនៃការព្រមព្រៀងតាមមាត្រា១០១១ នៃក្រមនេះនៅក្នុងដំណើរការនៃការជំនុំជម្រះលើពាក្យ តុលាការនឹងសាកសួរឪពុកម្ដាយបង្កើតក្នុងនាមជាជនពាក់ព័ន្ធអំពីការឯកភាពឱ្យបង្កើតរបបសុំកូនពេញលេញ។ ជាគោលលការណ៍របបសុំកូនមិនអាចបង្កើតបានឡើយ ប្រសិនបើពុំមានការឯកភាពពីឪពុកម្ដាយបង្កើត ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កូនសុំ។ ប៉ុន្តែដើម្បីការពារឧត្តមប្រយោជន៍របស់កុមារ កាលបើឪពុកម្ដាយបង្កើត ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនពុំមានសមត្ថភាពក្នុងការបង្ហាញឆន្ទៈ ឬបានធ្វើបាប ឬបោះបង់កុមារចោលដោយគំនិតទុច្ចរិត ឬមូលហេតុផ្សេងទៀត របបសុំកូនពេញលេញត្រូវបង្កើតឡើងដោយពុំចាំបាច់មានការឯកភាពពីជនទាំងនោះឡើយ។ សកម្មភាពដាក់ពាក្យសុំក៏តម្រូវឱ្យអ្នកដាក់ពាក្យមានសមត្ថភាពនៅក្នុងការធ្វើសកម្មភាពស្របទៅតាមច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹងដែរ។ បើក្នុងករណីការយកកូនរបស់សហព័ទ្ធមកធ្វើជាកូនចិញ្ចឹម បុគ្គលដែលនឹងក្លាយជាឪពុក ឬម្ដាយចិញ្ចឹមអាចដាក់ពាក្យតែម្នាក់ឯងបាន។ ប៉ុន្តែបើក្នុងករណីដែលសហព័ន្ធណាម្ខាង គឺជាជនដែលស្ថិតនៅក្រោមរបបអាណាព្យាបាលទូទៅ សកម្មភាពដាក់ពាក្យសុំរបស់សហព័ន្ធនោះក៏ត្រូវបានទទួលស្គាល់ដែរ។ ប៉ុន្តែប្រសិនបើនៅពេលដាក់ពាក្យសុំសហព័ន្ធនោះពុំមានសមត្ថភាពក្នុងការបង្ហាញឆន្ទៈទេ ពោលគឺ ពុំអាចយល់ដឹងបានអំពីលទ្ធផលតាមផ្លូវច្បាប់នៃអំពើរបស់ខ្លួន សហព័ន្ធនោះពុំមានលក្ខណៈសម្បត្តិជាអ្នកដាក់ពាក្យសុំឡើយ ហើយវិធានការតំណាង

ពិសេសមិនអាចយកមកអនុវត្តបានឡើយក្នុងនីតិវិធីនេះ ព្រោះរបបអ្នកតំណាងពិសេសអនុវត្តតែចំពោះជនដែលខ្វះសមត្ថភាពក្នុងការធ្វើសកម្មភាព។

### ៣. ទម្រង់នៃការដាក់ពាក្យសុំ

ពាក្យសុំបង្កើតស្មុំកូនពេញលេញ អាចធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់បានលើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសដែលមានក្នុងច្បាប់ ហើយនៅក្នុងពាក្យសុំនោះត្រូវសរសេរបញ្ជាក់នូវចំណុចដូចខាងក្រោម ៖

ក- អត្តសញ្ញាណជនពាក់ព័ន្ធ : ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់អ្នកដែលដាក់ពាក្យសុំ ( ឪពុកម្តាយចិញ្ចឹម ) ហើយឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ( ឪពុកម្តាយបង្កើត និងកូនសុំ )។

ខ- ខ្លឹមសារនៃដីកាសម្រេច ឬសកម្មភាពផ្សេងៗទៀតរបស់តុលាការ ដែលអ្នកដាក់ពាក្យសុំទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ។

ដើម្បីដាក់ពាក្យសុំដោយផ្ទាល់មាត់ អ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្តីថ្លែងការណ៍នូវចំណុចនីមួយៗ ដែលកំណត់ក្នុងកថាខណ្ឌទី២ ខាងលើនេះ នៅចំពោះមុខក្រឡាបញ្ជី។ ក្នុងករណីនេះក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុ និងចុះហត្ថលេខា។ កំណត់ហេតុនេះត្រូវបានកំណត់ថាជាពាក្យសុំ។ បន្ថែមពីលើនេះ អ្នកដាក់ពាក្យសុំត្រូវបង្ហាញនៅក្នុងពាក្យសុំរបស់ខ្លួនពីអង្គហេតុដែលជាមូលហេតុនៃការទាមទារដូចជា ៖

- អង្គហេតុដែលបញ្ជាក់ថាខ្លួន និងកូនសុំបានបំពេញតាមគ្រប់លក្ខខណ្ឌដែលច្បាប់បានតម្រូវ
- អង្គហេតុដែលបញ្ជាក់ថាឪពុកម្តាយបង្កើត ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនកូនសុំបានយល់ព្រមចំពោះការបង្កើតស្មុំកូនពេញលេញ
- អង្គហេតុដែលបញ្ជាក់ថាមានស្ថានភាពចាំបាច់ពិសេស ក្នុងការបង្កើតស្មុំកូនពេញលេញដើម្បីជាផលប្រយោជន៍របស់កូនសុំជាដើម។ល។

### ៤. ទីកន្លែងនៃការដាក់ពាក្យសុំ

ពាក្យសុំត្រូវដាក់នៅតុលាការខាងលំនៅឋានរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម។ [10] ក្នុងករណីដែលបុគ្គលដែលជាអ្នកសុំមិនមានលំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូច្នេះគេនឹងកំណត់យកទីសំណាក់របស់បុគ្គលនោះដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជាធ្វើជាលំនៅឋាន។

[10] ឧបសម្ព័ន្ធទី៤ .៧ ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០។

### ៥. ពន្ធដែលត្រូវបង់នៅពេលដាក់ពាក្យសុំ

តាមច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង អ្នកដែលដាក់ពាក្យសុំត្រូវបង់ពន្ធចំនួន ៥០០០( ប្រាំពាន់ )រៀល។ [11] ក្នុងករណីដែលអ្នកដាក់ពាក្យសុំមិនបានបង់ពន្ធទេតុលាការត្រូវកំណត់អំឡុងពេលសមរម្យ និងបង្គាប់ឱ្យបង់ពន្ធនោះ។ ប្រសិនបើអ្នកដាក់ពាក្យសុំនៅតែមិនព្រមបង់ពន្ធនោះទេ តុលាការត្រូវលើកពាក្យសុំចោលដោយដីកាសម្រេច។ ក្រៅពីពន្ធដាក់ពាក្យសុំ អ្នកដាក់ពាក្យសុំត្រូវទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធតាមការកំណត់របស់តុលាការ ដើម្បីអាចឱ្យតុលាការធ្វើការបញ្ជូនឯកសារ ការពិនិត្យភស្តុតាង ឬសកម្មភាពផ្សេងទៀតដែលចាំបាច់សម្រាប់នីតិវិធី។

### ៦. ការពិនិត្យពាក្យសុំ

ពេលទទួលបានពាក្យសុំ តុលាការត្រូវពិនិត្យពាក្យសុំថាបានសរសេរនូវចំណុចដែលច្បាប់តម្រូវហើយឬនៅ បើមិនទាន់សរសេរ ឬសរសេរមិនត្រឹមត្រូវ តុលាការត្រូវបង្គាប់ឱ្យភាគីអ្នកដាក់ពាក្យសុំកែតម្រូវពាក្យសុំដោយទុករយៈពេលកំណត់មួយសមរម្យ។ បើអ្នកដាក់ពាក្យសុំ មិនព្រមកែតម្រូវតាមការបង្គាប់របស់តុលាការនោះតុលាការត្រូវលើកពាក្យសុំចោលដោយដីកាសម្រេច។ អ្នកដាក់ពាក្យសុំមានសិទ្ធិប្តឹងជំទាស់លើដីកាសម្រេចលើកចោលពាក្យសុំ ក្នុងអំឡុងពេលដែលច្បាប់បានកំណត់។

### ៧. មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ

ប្រសិនបើតុលាការយល់ឃើញថាមិនសមរម្យឱ្យឪពុកម្តាយគ្រប់គ្រងថែរក្សាកូន ដូចជាករណីដែលឪពុកម្តាយបានបាត់ខ្លួន ឬឪពុកម្តាយមានវិបត្តិផ្នែករាងកាយដែលធ្វើឱ្យមានការពិបាកក្នុងការគ្រប់គ្រងថែរក្សាកុមារ ឬឪពុកម្តាយដែលធ្វើបាប ឬបោះបង់កូនចោល ហើយយល់ឃើញថាដើម្បីលផលប្រយោជន៍កុមារចាំបាច់ត្រូវតែបញ្ចប់ញាតិភាពជាមួយឪពុកម្តាយនោះ ហើយបង្កើតសុំកូនជាមួយឪពុកម្តាយចិញ្ចឹម ទើបតុលាការអាចសម្រេចឱ្យបង្កើតសុំកូនបាន។

### កថាភាគទី ៥. ក្រោយនីតិវិធីនៃការសុំកូនពេញលេញ

ហេតុអ្វីបានជាចាំបាច់បង្កើតឱ្យមានអំឡុងពេលសាកល្បងចិញ្ចឹម? ហើយគេអនុវត្តយ៉ាងដូចម្តេច?

អំឡុងពេលសាកល្បង គឺជារយៈពេលដែលតុលាការបានកំណត់ ដើម្បីឈានដល់ការសម្រេចសេចក្តីក្នុងការបង្កើតសុំកូនពេញលេញ ដែលវាអាចឱ្យតុលាការធ្វើការពិចារណាមុននឹងវិនិច្ឆ័យអំពីភាពអាច ឬមិនអាចបង្កើតសុំកូនពេញលេញ។ ជាគោលការណ៍អំឡុងពេលចិញ្ចឹមកូនសាកល្បងមានរយៈពេលយ៉ាងតិច ៦(

[11] មាត្រា២២.១ ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០។

ប្រាំមួយ )ខែ។ [12] អំឡុងពេលសាកល្បងនឹងចាប់អនុវត្តក្រោយពេលអ្នកសុំបានដាក់ពាក្យសុំបង្កើតស្មុំកូនទៅតុលាការ មិនមែនកើតឡើងមុនការដាក់ពាក្យសុំទៅតុលាការនោះទេ។

ការបង្កើតអំឡុងពេលសាកល្បងចិញ្ចឹមនេះ គឺក្នុងគោលបំណងដើម្បីពិនិត្យថាទៅលើស្ថានភាពជាក់ស្តែងអំពីទំនាក់ទំនងរវាងកូនសុំ ជាមួយនឹងឪពុកម្តាយចិញ្ចឹម ថាតើឪពុកម្តាយចិញ្ចឹមមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងថែរក្សាកុមារដែរឬទេ? ហើយតើអាចបង្កើតទំនាក់ទំនងល្អជាមួយកូនសុំ ឬទេ? និងថាតើមានភាពចុះសម្រុងគ្នារវាងកូនសុំ និងឪពុកម្តាយចិញ្ចឹមដែរ ឬយ៉ាងណា? ប្រសិនបើតុលាការពិនិត្យទៅឃើញថា នៅក្នុងអំឡុងពេលចិញ្ចឹមកូនសាកល្បងនេះ កុមារនោះមិនមានភាពចុះសម្រុងជាមួយឪពុកម្តាយចិញ្ចឹមនោះទេ នោះតុលាការនឹងមិនសម្រេចឱ្យបង្កើតស្មុំកូនពេញលេញឡើយ ព្រោះស្ថានភាពដែលរស់នៅមិនចុះសម្រុងអាចប៉ះពាល់ដល់សតិអារម្មណ៍របស់កុមារទាំងពេលបច្ចុប្បន្ន និងអនាគត។

ការកំណត់អំពីរយៈពេលចិញ្ចឹមកូនសាកល្បង គឺអាស្រ័យទៅតាមស្ថានភាពជាក់ស្តែង ពោលគឺអាចមានរយៈពេលតិចឬ ច្រើនជាង ៦(ប្រាំមួយ)ខែ ទៅតាមឆន្ទានុសិទ្ធិរបស់ចៅក្រមដែលជាអ្នកទទួលបន្ទុក ប្រសិនបើចៅក្រមយល់ឃើញថា រយៈពេលអប្បបរមាតិច ឬលើស ៦( ប្រាំមួយ )ខែនោះ ជារយៈពេលសមរម្យដែលមានភាពចាំបាច់ដើម្បីជាមូលដ្ឋានសម្រាប់ការវិនិច្ឆ័យ ចៅក្រមត្រូវមានសំអាងហេតុពិសេសក្នុងសេចក្តីសម្រេច ដែលកំណត់អំពីអំឡុងពេលចិញ្ចឹមកូនសាកល្បងនេះ។ ជាអញ្ញត្រកម្ម ឪពុកម្តាយចិញ្ចឹមអាចរួចផុតពីអំឡុងពេលនៃការចិញ្ចឹមសាកល្បងក្នុងករណីដែលឪពុកម្តាយចិញ្ចឹមនោះ មានជាភស្តុតាងដែលបញ្ជាក់ថាខ្លួនបានគ្រប់គ្រង និងថែរក្សាកុមារជាយូរណាស់មកហើយ ពោលគឺកុមារនោះបានរស់នៅជាមួយឪពុកម្តាយចិញ្ចឹមនោះតាំងពីមុនពេលដែលពួកគាត់ដាក់ពាក្យសុំមកម្ល៉េះ ហើយរយៈពេលនៃការរស់នៅជាមួយកុមារនោះមានរយៈពេលលើសពី ៦( ប្រាំមួយ )ខែ។ ប្រសិនបើមានជាឯកសារ ដែលតុលាការពិនិត្យមើលឃើញថាមានភាពត្រឹមត្រូវហើយនោះ តុលាការអាចសម្រេចទទួលស្គាល់សុំកូនពេញលេញបានតែម្តង ដោយពុំចាំបាច់ឆ្លងកាត់អំឡុងពេលចិញ្ចឹមកូនដោយសាកល្បងឡើយ។ ដើម្បីអាចសម្រេចបាននូវការចិញ្ចឹមកូនសាកល្បង ជាបឋមឪពុកម្តាយបង្កើត ឬអ្នកមានអំណាចមេបាត្រូវមានភាពឯកភាពគ្នាប្រគល់កុមារទៅឱ្យឪពុកម្តាយចិញ្ចឹមដើម្បីគ្រប់គ្រង និងមើលថែរក្សាកុមារនោះដោយសន្តិវិធី។ ប្រសិនបើមានការជំទាស់ មិនអនុញ្ញាតឱ្យគ្រប់គ្រងទេនោះ ឪពុកម្តាយចិញ្ចឹមអាចដាក់ពាក្យសុំចាត់ចែងរក្សាការពារ។

[12] មើលមាត្រា១០១៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

**កថាភាគទី ៦. ការចាត់ចែងរក្សាការពារ**

ការចាត់ចែងរក្សាការពារក្នុងអត្ថបទនៃស៊ុំកូនពេញលេញនេះ គឺជាការព្យួរអំណាចមេបាជាអាទិ៍ មុនពេលដែលដីកាសម្រេចឱ្យបង្កើតស៊ុំកូនពេញលេញបង្កើតអានុភាព។ [13] ការសម្រេចអំពីការព្យួរអំណាចមេបាត្រូវធ្វើឡើងជាដីកាសម្រេច ការចេញដីកាសម្រេចនេះ ត្រូវតែមានពាក្យសុំពីឪពុកម្ដាយចិញ្ចឹម ប្រសិនបើឪពុកបង្កើត ឬម្ដាយបង្កើតបង្ហាញឆន្ទៈរារាំងមិនអនុញ្ញាតឱ្យកូនទៅឪពុកម្ដាយចិញ្ចឹម ដើម្បីគ្រប់គ្រងទៅតាមច្បាប់នោះទេ នោះ( អំឡុងពេលចិញ្ចឹមកូនសាកល្បង ) ឪពុកម្ដាយចិញ្ចឹមអាចដាក់ពាក្យសុំ ដើម្បីស្នើសុំតុលាការចេញដីកាសម្រេចរក្សាការពារព្យួរជាបណ្ដោះអាសន្ននូវអំណាចមេបារបស់ឪពុកបង្កើត ឬម្ដាយបង្កើត ឬអ្នកមានអំណាចមេបាសម្រាប់អនីតិជននោះ និងកំណត់អំពីអ្នកដែលមានអំណាចមេបាជំនួស។

**ឧទាហរណ៍ ៖** លោក សំណាង និង លោកស្រី គន្ធា ជាសហព័ទ្ធនឹងគ្នាមានកូនម្នាក់ឈ្មោះ វិសាល។ លោក សំណាង និងលោកស្រី គន្ធា រស់នៅមិនចុះសម្រុងនឹងគ្នាក៏បានលែងលះគ្នាតាមផ្លូវច្បាប់ ហើយតុលាការបានសម្រេចឱ្យលោកស្រី គន្ធា ជាអ្នកមានអំណាចមេបាលើកូន វិសាល ព្រោះលោក សំណាង ពុំមានលទ្ធភាពគ្រប់គ្រាន់ដើម្បីចិញ្ចឹមថែរក្សាលើកូននោះទេ ។ លោកស្រី គន្ធា បានធ្វើបាបកូន វិសាល ជាញឹកញាប់។ ដោយឃើញអំពីស្ថានភាពបែបនេះ ទើបលោក រតនៈ និងលោកស្រី ធីតា បានដាក់ពាក្យសុំបង្កើតស៊ុំកូនពេញលេញជាមួយកូន វិសាល ដោយលោក សំណាង បានឯកភាពឱ្យបង្កើត តែលោកស្រី គន្ធា ជំទាស់ដាច់ខាត ដោយអះអាងថាខ្លួនជាម្ដាយ និងជាអ្នកមានអំណាចមេបាជាបណ្ដោះអាសន្ន ដែលជាអំណាចមេបាដែលទទួលស្គាល់ដោយតុលាការទៀតផង។

ក្នុងករណីនេះ លោក រតនៈ និង លោកស្រី ធីតា អាចដាក់ពាក្យសុំព្យួរអំណាចមេបាពីលោកស្រី គន្ធា បាន។ ហើយតុលាការអាចសម្រេចជ្រើសតាំងលោក សំណាង ជាអ្នកអនុវត្តកិច្ចការជំនួសបាន ដើម្បីឱ្យលោក សំណាង អាចទទួលដំណឹងអំពីដីកាសម្រេចស៊ុំកូនពេញលេញ និងធ្វើជាតំណាងសម្រាប់កូន វិសាល។ ដីកាសម្រេចរក្សាការពារ ត្រូវតែមានមូលហេតុត្រឹមត្រូវដើម្បីការពារផលប្រយោជន៍របស់ដីកាសម្រេចរក្សាការពារចំពោះកុមារ។ ប្រសិនបើតុលាការយល់ឃើញថា ការបដិសេធនេះ មិនប៉ះពាល់ដល់ផលប្រយោជន៍របស់កូនស៊ុំទេនោះ ពោលគឺពុំចូលក្នុងស្ថានភាពដែលមានចែងក្នុងមាត្រា ១០១១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីទេ ឆ្នាំ ២០០៧ ឆន្ទៈយល់ព្រមរបស់ឪពុកម្ដាយបង្កើត គឺមានភាពចាំបាច់។ ពីព្រោះថាការបដិសេធចំពោះការប្រគល់កូននេះបានបង្ហាញពីចេតនាជំទាស់ចំពោះការបង្កើតស៊ុំកូនពេញលេញ ដែលជាលក្ខខ័ណ្ឌចាំបាច់មួយ ក្នុងចំណោមលក្ខខ័ណ្ឌតឹងរឹងដ៏ទៃផ្សេងទៀត។

[13] មាត្រា ៤៨ ច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹង ឆ្នាំ២០១០។

ប្រសិនបើស្ថានភាពដូចការរៀបរាប់ខាងលើមែននោះ តុលាការអាចចេញដីកាសម្រេចច្រានចោលការទាមទាររបស់អ្នកដាក់ពាក្យសុំ ក្រោមមូលហេតុខ្វះការយល់ព្រមពីឪពុកម្តាយបង្កើត។ ផ្ទុយទៅវិញ ប្រសិនបើតុលាការយល់ឃើញថា មានអង្គហេតុចូលក្នុងស្ថានភាពដែលមានចែងក្នុងមាត្រា ១០១១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីនោះ ឆ្នាំ២០០៧ ( មានការវាយធ្វើបាបកូន ឬបោះបង់កូនចោលដោយគំនិតទុច្ចរិត ) តុលាការត្រូវចេញដីកាសម្រេចរក្សាការពារ ដោយផ្អែកលើភាពចាំបាច់ដើម្បីផលប្រយោជន៍កុមារ។ នៅក្នុងដីកាសម្រេចរក្សាការពារ តុលាការត្រូវបង្គាប់ឱ្យឪពុកម្តាយបង្កើតប្រគល់កូនឱ្យអ្នកអនុវត្តអំណាចមេបាជំនួស ដើម្បីសម្រេចគោលបំណងនៃការចាត់ចែង។

**កថាភាគទី ៧. ដីកាសម្រេច**

ដីកាសម្រេច គឺជាសេចក្តីសម្រេចរបស់តុលាការ។ សុំកូននៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវទទួលស្គាល់ដោយដីកាសម្រេច។[14] នៅក្នុងដីកាសម្រេចត្រូវធ្វើជាលាយលក្ខណ៍អក្សរសរសេរសំអាងហេតុ និងសេចក្តីសម្រេចបញ្ចប់ ហើយចៅក្រមត្រូវចុះហត្ថលេខាលើសេចក្តីសម្រេចនេះ។[15] ការចេញដីកាសម្រេចនេះ តុលាការត្រូវផ្ទៀងផ្ទាត់អំពីលក្ខខណ្ឌយ៉ាងតឹងរឹងដែលបានកំណត់ដោយច្បាប់ ( កថាខណ្ឌទី២ នៃអត្ថបទនេះ )។

ប្រសិនបើលក្ខខណ្ឌទាំងនោះបានបំពេញរួចហើយ ហើយបានឆ្លងកាត់ដំណាក់កាលនៃការចិញ្ចឹមកូនសាកល្បងហើយនោះ តុលាការនឹងត្រូវចេញដីកាសម្រេចទទួលស្គាល់សុំកូនពេញលេញ។ ផ្ទុយទៅវិញ ប្រសិនបើមានលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌផ្សេងទៀតមិនត្រូវបានបំពេញទេនោះ តុលាការនឹងត្រូវចេញដីកាសម្រេចលើកចោលពាក្យសុំតាមកំណត់ច្បាប់។

គ្រប់ទម្រង់នៃដីកាសម្រេចអំពីសុំកូនពេញលេញនេះ ចៅក្រមត្រូវសរសេរសំអាងហេតុជានិច្ច ដើម្បីធានាភាពមិនលម្អៀងនៃការសម្រេចរបស់ចៅក្រមទទួលបន្ទុក។ ម្យ៉ាងទៀតការសរសេរសំអាងហេតុនេះត្រូវតែបង្ហាញឱ្យបានច្បាស់លាស់នូវមូលហេតុនៃការវិនិច្ឆ័យចំពោះភាគី ដើម្បីឱ្យភាគីមានភាពងាយស្រួលក្នុងការប្តឹងជំទាស់។ ជាទូទៅសំអាងហេតុ ត្រូវសរសេរឱ្យមានភាពស៊ីចង្វាក់ជាមួយនឹងសេចក្តីសម្រេច ពីព្រោះសំអាងហេតុ គឺជាមូលហេតុដែលនាំឱ្យមានការសម្រេចវិនិច្ឆ័យចំពោះអង្គហេតុនីមួយៗ។

ក្រោយពីចេញដីកាសម្រេចរួចហើយ ដីកាសម្រេចនោះត្រូវជូនដំណឹងដល់ជនដែលត្រូវទទួលដីកាសម្រេចនោះ។[16] ដីកាសម្រេចនេះត្រូវជូនដំណឹងជាចាំបាច់ ពីព្រោះដីកាសម្រេចនេះនឹងត្រូវកំណត់អំពីចិរវេលានៃការចូលជាស្ថាពរ គឺគិតចាប់ពីថ្ងៃដែលភាគីទាំងអស់បានទទួលដំណឹងអំពីដីកាសម្រេច។ ការជូនដំណឹងទៀត

[14] មើលមាត្រា៣៥ ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០។

[15] មើលមាត្រា៣៥ ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០។

[16] មើលមាត្រា៣៦ ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០។

សោត គឺដើម្បីបើកសិទ្ធិជូនភាគីប្តឹងជំទាស់តាមកំណត់ច្បាប់។ ក្នុងអត្ថន័យនេះ មានន័យថាដីកាសម្រេចនឹងត្រូវចូលជាស្ថាពរក្រោយពេលចិរវេលានៃបណ្តឹងជំទាស់បានកន្លងហួស។ ដូចនេះ ទោះបីជាភាគីដែលពាក់ព័ន្ធបានទទួលដំណឹងអំពីដីកាសម្រេចនេះហើយមិនធ្វើបណ្តឹងជំទាស់ក៏ដោយ ក៏ដីកាសម្រេចមិនអាចចូលជាស្ថាពរបានឡើយប្រសិនបើបណ្តឹងជំទាស់មិនទាន់ហួសផុត។ ប្រសិនបើមានភាគីណាមួយមិនសុខចិត្ត ភាគីនោះអាចដាក់ពាក្យបណ្តឹងជំទាស់បានតាមកំណត់ច្បាប់។

### កថាភាគទី ៤. បណ្តឹងជំទាស់

ជាទូទៅ គ្រប់បណ្តឹងជំទាស់ទាំងអស់រមែងកើតចេញពីភាពមិនពេញចិត្ត ចំពោះសេចក្តីសម្រេចក្រោមទម្រង់ជាដីកាសម្រេច ឬសាលក្រម ឬសាលដីកា។ បណ្តឹងជំទាស់ គឺជាបណ្តឹងដែលធ្វើឡើងពីសំណាក់បុគ្គលដែលទទួលរងឥទ្ធិពលបណ្តាលឱ្យខូចប្រយោជន៍ដល់សិទ្ធិ ឬឋានៈគតិយុត្តរបស់ខ្លួនដោយសេចក្តីសម្រេចរបស់តុលាការ។ នៅក្នុងរឿងសុំកូនពេញលេញ បើបុគ្គលណាដែលទទួលរងឥទ្ធិពលបណ្តាលឱ្យខូចប្រយោន៍របស់ខ្លួនដោយដីកាសម្រេចសុំកូនពេញលេញ បុគ្គលនោះអាចប្តឹងជំទាស់ចំពោះដីកាសម្រេចនោះបាន។

ពាក្យបណ្តឹងជំទាស់ ត្រូវធ្វើឡើងក្នុងរយៈពេល ២( ពីរ )សប្តាហ៍ ក្រោយទទួលដំណឹងអំពីដីកាសម្រេច។[17] ពាក្យបណ្តឹងជំទាស់ ត្រូវដាក់ពាក្យនៅសាលាដំបូងដែលចេញដីកាសម្រេច តែពាក្យបណ្តឹងជំទាស់នេះ ជាសមត្ថកិច្ចផ្តាច់មុខរបស់សាលាឧទ្ធរណ៍។ អានុភាពនៃពាក្យបណ្តឹងជំទាស់ គឺអាចរារាំងការចូលជាស្ថាពរនៃដីកាសម្រេចបានជាបណ្តោះអាសន្ន ពោលគឺត្រូវរង់ចាំចំណាត់ការលើបណ្តឹងជំទាស់ជាបឋម រហូតដល់សាលាឧទ្ធរណ៍ចេញដីកាសម្រេចអំពីបណ្តឹងជំទាស់នេះ។ ពាក្យបណ្តឹងជំទាស់ត្រូវកំណត់បង់ពន្ធក្នុងចំនួនទឹកប្រាក់៥០០០( ប្រាំពាន់ )រៀល។[18]

## ផ្នែកទី ៣. អានុភាពនៃសុំកូនពេញលេញ

យើងឃើញថារបបសុំកូន បង្កើតឱ្យមានអានុភាពនៅពេលដែលដីកាសម្រេចសុំកូនជាស្ថាពរ។ ហើយនៅពេលដែលចូលជាស្ថាពរនៃដីកាសម្រេចនេះ វាក៏បានបង្កើតបាននូវអានុភាពគតិយុត្តិមួយចំនួនផងដែរ ក្នុងនោះមានដូចជា ការកាត់ផ្តាច់ទំនាក់ទំនងញាតិ និងការបង្កើតទំនាក់ទំនងជាមួយឪពុកម្តាយចិញ្ចឹមជាដើម។

### កថាភាគទី ១. ការកាត់ផ្តាច់ទំនាក់ទំនងញាតិ

របបសុំកូនពេញលេញមានគោលបំណងចិញ្ចឹមកុមារ ដែលបានសុំឱ្យដូចជាកូនបង្កើតក្នុងមជ្ឈដ្ឋានគ្រួសារដែលមានស្ថិរភាពល្អ ដូច្នេះកូនសុំត្រូវស្ថិតនៅក្រោមការគ្រប់គ្រងទាំងស្រុងរបស់ឪពុកម្តាយចិញ្ចឹម។ មានន័យថាការចូលជ្រៀតជ្រែក ឬការរំខានមិនសមស្របពីឪពុកម្តាយបង្កើតដូចជា ការទាមទារយកកូនវិញ ឬការ

[17] មើលមាត្រា៤០ ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០។

[18] មើលមាត្រា៣៩ ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០។

ទាមទារចរចាជួបកូនជាដើមត្រូវបានហាមឃាត់ ហើយអំពើទំនើងដូចជា ការទាមទារអាហារកាតព្វកិច្ចពីកូននៅពេលដែលកូននោះពេញវ័យជាដើមក៏ចាំបាច់ត្រូវដាក់ការរឹតត្បិតផងដែរ។ ហេតុដូច្នេះបានជាច្បាប់តម្រូវឱ្យមានការបញ្ចប់ និងផ្តាច់ទំនាក់ទំនងញាតិភាពរវាងកូនសុំ និងឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតនោះតាមរយៈការបង្កើតស្មុំកូនពេញលេញ។ ក៏ប៉ុន្តែក្នុងករណីសហព័ទ្ធម្ខាងសុំកូនដែលជាកូនបង្កើតរបស់សហព័ទ្ធម្ខាងទៀតដូចជា កូនសុំដែលជាកូនចុងការសុំកូនដោយសហព័ទ្ធតែម្ខាងជាការគ្រប់គ្រាន់ ហើយចំពោះការគ្រប់គ្រងថែរក្សាក្នុងនាមជាឪពុក ឬម្តាយបង្កើតរបស់សហព័ទ្ធម្ខាងទៀតមិនចាំបាច់ឱ្យមានការបញ្ចប់ទំនាក់ទំនងញាតិភាពជាមួយឪពុក ឬម្តាយបង្កើតនោះ និងញាតិលោហិតរបស់ឪពុក ឬម្តាយបង្កើតនោះឡើយ។ [19]

**ឧទាហរណ៍ ៖** ប្រសិនបើលោក ឧត្តម បានសុំកូនចុងរបស់គាត់ឈ្មោះ បញ្ញា ( ដែលជាកូនរបស់ប្រពន្ធគាត់ឈ្មោះ ពិសី ) មកចិញ្ចឹមធ្វើជាកូនសុំពេញលេញវិញ។ បានសេចក្តីថា ញាតិភាពរវាង បញ្ញា និងលោកស្រី ពិសី ដែលជាម្តាយបង្កើតមិនត្រូវបានបញ្ចប់ទេ។

*** សម្គាល់ :** ទោះបីជាក្រោយពេលទំនាក់ទំនងញាតិត្រូវបានបញ្ចប់ក៏ដោយ ក៏បញ្ញត្តិមាត្រា៩៥១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ការហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍រវាងញាតិលោហិត គឺនៅតែយកមកអនុវត្ត។

### កថាភាគទី ២. ការបង្កើតទំនាក់ទំនងជាមួយឪពុកម្តាយចិញ្ចឹម

ទំនាក់ទំនងរវាងកូនចិញ្ចឹម និងឪពុកម្តាយចិញ្ចឹម ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹមត្រូវបានបង្កើតឡើង នៅពេលដែលដីកាសម្រេចចាប់ផ្តើមស្មុំកូនមានអានុភាពចូលជាស្ថាពរ។ ដូច្នេះកូនសុំមានឋានៈដូចគ្នាទៅនឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម មានន័យថាកូនសុំត្រូវទទួលបានសិទ្ធិ និងករណីយកិច្ចដូចគ្នានឹងកូនបង្កើតដែរ។ ម៉្យាងទៀតក្នុងករណីដែលប្តីប្រពន្ធណាម្ខាងក្លាយជាឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹមរបស់កូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុកបង្កើត ឬម្តាយបង្កើត និងឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម។ [20]

## ផ្នែកទី ៤. សិទ្ធិរបស់ស្មុំកូនពេញលេញ

### កថាភាគទី ១. សិទ្ធិទទួលដឹងអំពីកំណើត

ដូចដែលយើងបានធ្វើការបកស្រាយខាងលើហើយថា នៅពេលដែលកូនសុំបានកាត់ផ្តាច់ទំនាក់ទំនងញាតិភាពរវាងឪពុកម្តាយបង្កើត និងញាតិលោហិតរបស់ឪពុកម្តាយបង្កើតទៅតាមនីតិវិធីច្បាប់រួចនោះ ការស្មុំកូនពេញលេញក៏បានកើតឡើង ដូច្នេះបញ្ជីកំណើតរបស់កូនសុំត្រូវបានធ្វើជាថ្មី ប៉ុន្តែនៅក្នុងសំបុត្រកំណើត ឬ

[19] មើលមាត្រា១០១៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[20] មើលមាត្រា១០១៥.៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

សេចក្តីចម្លងសំបុត្រកំណើត ឬឯកសារដកស្រង់នៃបញ្ជីកំណើត មិនបានសរសេរចំណុចស្តីពីស្មុំកូនឡើយ។[21] ទោះបីជាយ៉ាងណាមិញកូនសុំនៅតែអាចមានសិទ្ធិដឹងអំពីកំណើតរបស់ខ្លួនបានជានិច្ច នៅពេលដែលខ្លួនបានក្លាយជានីតិជន ប៉ុន្តែបើកូនសុំមានគោលបំណងមិនល្អ តុលាការមិនអនុញ្ញាតឡើយ លើកលែងតែក្នុងករណីតែមានស្ថានភាពពិសេស និងបញ្ជាក់អំពីមូលហេតុត្រឹមត្រូវតែប៉ុណ្ណោះ។[22]

**កថាភាគទី ២. សិទ្ធិក្នុងការជ្រើសរើសនាមត្រកូល**

នៅពេលដែលកូនសុំមានអានុភាព កូនសុំនោះនឹងក្លាយទៅជាកូនពេញសិទ្ធិរបស់ឪពុកម្តាយចិញ្ចឹម ដែលទទួលបានឋានៈដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម ព្រមទាំងមានសិទ្ធិ និងករណីយកិច្ចដូចគ្នានឹងកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយនឹងឪពុកម្តាយចិញ្ចឹមដែរ។ ចំណែកឯការប្រើសប្រាស់នាមត្រកូលវិញ យើងឃើញថាកូនៗភាគច្រើន គឺយកនាមត្រកូលតាមឪពុកម្តាយ ហើយការដាក់នាមត្រកូលរបស់កូនជាទូទៅគេធ្វើឡើងតាំងពីថ្ងៃដែលកូននោះទើបតែកើតមកម្ល៉េះ។ ដូច្នេះហើយកូនសុំនោះប្រាកដជាមាននាមត្រកូលរបស់ខ្លួនមុនពេលបង្កើតស្មុំកូនទៅទៀត ហេតុនេះហើយបន្ទាប់ពីការបង្កើតស្មុំកូនរួច គេអាចផ្តល់ជម្រើសដល់កូនសុំនោះក្នុងការប្រើប្រាស់នាមត្រកូលថ្មីរបស់ឪពុកម្តាយចិញ្ចឹម ឬប្រើប្រាស់នាមត្រកូលមុនពេលស្មុំកូនបាន ដោយយោងតាមមាត្រា១០១៥ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

**កថាភាគទី៣. សិទ្ធិស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹមរបស់កូនសុំដែលជាអនីតិជន**

អំណាចមេបា គឺជាសិទ្ធិ និងករណីយកិច្ចក្នុងការបីបាច់ថែរក្សាកូនដែលជាអនីតិជន និងគ្រប់គ្រងលើទ្រព្យសម្បត្តិរបស់កូននោះ។ ជាទូទៅ កូនគ្រប់រូបដែលជាអនីតិជនត្រូវស្ថិតក្រោមការគ្រប់គ្រង និងថែរក្សារបស់ឪពុកម្តាយ ឬអ្នកមានអំណាចមេបារបស់កូននោះដែលស្របទៅនឹងច្បាប់។ ដោយឡែកចំពោះករណីកូនសុំវិញនៅពេលដែលការស្មុំកូនពេញលេញមានអានុភាពហើយនោះ កូនសុំនឹងត្រូវបញ្ចប់ញាតិភាពរវាងឪពុកម្តាយបង្កើត ហើយបង្កើតញាតិភាពថ្មីជាមួយនឹងឪពុកម្តាយចិញ្ចឹមវិញ។ ដូចនេះកូនសុំមិនត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្តាយបង្កើតទៀតទេ។ កូនសុំដែលនៅតែជាអនីតិជនត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម។[23] ប៉ុន្តែបើក្នុងករណីប្រសិនបើសហព័ទ្ធណាម្ខាងក្លាយជាឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹម

[21] មើលមាត្រា១០១៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[22] មើលមាត្រា១០១៩ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[23] មើលមាត្រា១០១៩.៣.១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

របស់កូនបង្កើតនៃសហព័ទ្ធម្ខាងទៀត នោះកូនសុំត្រូវស្ថិតនៅក្រោមអំណាចមេបារូមរបស់ឪពុកបង្កើត ឬម្ដាយបង្កើត និងឪពុកចិញ្ចឹម ឬម្ដាយចិញ្ចឹម។ [24]

**កថាភាគទី ៤. សិទ្ធិទទួលបានអាហារកាតព្វកិច្ចរបស់កូនសុំដែលជាអនីតិជន**

ពាក្យថា « អាហារកាតព្វកិច្ច » ដោយយោងតាមសន្ទានុក្រមផ្នែករដ្ឋប្បវេណី បានឱ្យនិយមន័យថា ជាកិច្ចដែលត្រូវបំពេញតាមច្បាប់ ឬតាមសេចក្ដីសម្រេចរបស់តុលាការ ដែលតម្រូវឱ្យបុគ្គលម្នាក់ ឬច្រើននាក់ផ្ដល់នូវប្រាក់ ឬទ្រព្យ ដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅដល់បុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងញាតិជាមួយគ្នា។ ដោយកូនសុំត្រូវបានធ្វើឱ្យដូចជាកូនមានខាន់ទាំងស្រុង ក្នុងទំនាក់ទំនងរបស់កូនសុំជាមួយឪពុកម្ដាយចិញ្ចឹម មានសិទ្ធិ និងករណីយកិច្ចដូចគ្នានឹងសិទ្ធិ និងករណីយកិច្ចនៃទំនាក់ទំនងរវាងកូនបង្កើត និងឪពុកម្ដាយបង្កើតដែរ។ [25] ហេតុដូច្នេះ ទំនាក់ទំនងរវាងឪពុកម្ដាយចិញ្ចឹម និងកូនសុំត្រូវបានចាត់ទុកថាជាទំនាក់ទំនងញាតិលោហិតខ្សែផ្ទាល់ ហើយករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចក៏ត្រូវកើតឡើងរវាងឪពុកម្ដាយចិញ្ចឹម និងកូនសុំដែរ។ មានន័យថាកូនគ្រប់រូបមិនថាកូនបង្កើតក្ដី ឬកូនសុំក្ដីដែលជាអនីតិជនត្រូវតែទទួលបានការផ្គត់ផ្គង់ពីឪពុកម្ដាយ តាមរយៈប្រាក់ ឬទ្រព្យសម្បត្តិនានា សម្រាប់ការរស់នៅប្រចាំថ្ងៃ និងការសិក្សារៀនសូត្រជាដើម។

**កថាភាគទី ៥. សិទ្ធិធ្វើ និងទទួលសន្តតិកម្ម**

សន្តតិកម្ម គឺជាការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មរតកជនទៅឱ្យសន្តតិជនម្នាក់ ឬច្រើននាក់តាមឆន្ទៈ ឬតាមច្បាប់។ [26] ក្រោយពីតុលាការចេញដីកាសម្រេចបង្កើតសុំកូនពេញលេញជាស្ថាពរ កូនសុំត្រូវទទួលបានសិទ្ធិដូចនឹងកូនបង្កើតដែរ ហើយក្នុងនោះក៏មានសិទ្ធិទទួលសន្តតិកម្មផងដែរ។ ដូច្នេះកូនសុំ និងឪពុកម្ដាយចិញ្ចឹមមានសិទ្ធិធ្វើសន្តតិកម្មឱ្យគ្នាទៅវិញទៅមក ហើយញាតិលោហិតរបស់ឪពុកម្ដាយចិញ្ចឹមក៏អាចមានសិទ្ធិធ្វើសន្តតិកម្មឱ្យគ្នាទៅវិញទៅមកនឹងកូនសុំបានដែរ។ តាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ កូនរបស់មតកជនត្រូវក្លាយជាសន្តតិជនលំដាប់ទី១ជានិច្ច។ [27] ហើយការបែងចែកមត៌កនេះមិនថាកូនបង្កើតក្ដី ឬកូនសុំក្ដីត្រូវមានចំណែកមត៌កស្មើៗគ្នា ដោយយោងតាម១១៥៦ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។ ក្នុងករណីកូនរបស់មតកជនបានស្លាប់មុន ឬស្របពេលគ្នានឹងការចាប់ផ្ដើមសន្តតិកម្ម កូនរបស់ជននោះនឹងក្លាយជាសន្តតិជនជំនួស។

**ផ្នែកទី ៥. ការកាត់កាល់សុំកូនពេញលេញ**

ការកាត់កាល គឺជាការបញ្ចប់ទំនាក់ទំនងញាតិរវាងកូនសុំនឹងឪពុកម្ដាយចិញ្ចឹម ព្រមទាំងញាតិលោហិតរបស់ឪពុកម្ដាយចិញ្ចឹម។ ដោយសារតែសុំកូនពេញលេញមានទំនាក់ទំនងដូចឪពុកម្ដាយនឹងកូនបង្កើតដែរ ហេតុនេះហើយជាគោលការណ៍មិនអនុញ្ញាតឱ្យមានការកាត់កាល់ឡើយ ក៏ប៉ុន្តែមិនត្រូវទុកបន្តនូវសុំកូនទេ

[24] មើលមាត្រា១០១៩.៣.២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[25] មើលមាត្រា១០១៥.១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[26] សន្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំង ផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧។

[27] មាត្រា១១៥៦.១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ប្រសិនបើមានការខូចខាតផលប្រយោជន៍យ៉ាងធ្ងន់ធ្ងររបស់កូនសុំ។ ការស្នើសុំកាត់កាល់កូនសុំពេញលេញបាន លុះត្រាតែក្នុងករណីដែលត្រូវនឹងចំណុចដែលបានកំណត់នៅក្នុងមាត្រា១០១៦ នៃក្រមរដ្ឋប្បវេណី។ ការកាត់កាល់ត្រូវធ្វើឡើងតាមនីតិវិធីបណ្តឹងឋានៈបុគ្គលហើយតុលាការសម្រេចសេចក្តីដោយចេញសាលក្រម។

**កថាភាគទី ១. មូលហេតុនៃការកាត់កាល់សុំកូនពេញលេញ**

ទោះបីកូនសុំមិនមែនជាកូនបង្កើតក៏ពិតមែន ប៉ុន្តែក្នុងច្បាប់បានកំណត់យ៉ាងច្បាស់លាស់អំពីសិទ្ធិ និងករណីយកិច្ចដែលកូនសុំទទួលបានបន្ទាប់ពីដីកាសម្រេចរបស់តុលាការចូលជាស្ថាពរ ហេតុដូចនេះកូនសុំមានលក្ខណៈដូចនឹងកូនបង្កើតដែរ ដូច្នេះឪពុកម្តាយចិញ្ចឹម និងកូនសុំមិនអាចបញ្ចប់ទំនាក់ទំនងនឹងគ្នាបានងាយៗនោះទេ។ ម្យ៉ាងវិញទៀតសុំកូនគ្រាន់តែជាកូនដែលសន្មតតាមច្បាប់ប៉ុណ្ណោះមិនមែនជាកូនបង្កើតដែលកើតចេញពីខ្សែលោហិតទេ ដូចនេះសុំកូនអាចបញ្ចប់ទៅវិញបានដោយការកាត់កាល់បាន។[28]

សុំកូនកើតឡើងដោយសារសហព័ទ្ធដែលមានបំណងចង់បានកូន ប៉ុន្តែមិនអាចមានកូនបានដោយបញ្ហាសុខភាព ឬកើតឡើងដោយសារការចង់ជួយសង្គ្រោះកុមារ ដែលខ្វះភាពកក់ក្តៅឱ្យទទួលបានគ្រួសារថ្មីមួយដែលមានសុភមង្គល ប៉ុន្តែប្រសិនបើមានការធ្វើបាបដោយឪពុកម្តាយចិញ្ចឹម ឬបោះបង់កូនសុំចោលដោយគំនិតទុច្ចរិត ឬហេតុផលផ្សេងៗទៀតដែលបំពានដល់ផលប្រយោជន៍របស់កូនសុំយ៉ាងធ្ងន់ធ្ងរ នោះកូនសុំអាចដាក់ពាក្យបណ្តឹងទាមទារកាត់កាល់បាន។ ហើយប្រសិនបើក្នុងករណីដែលឪពុកម្តាយបង្កើតមានលទ្ធភាពគ្រប់គ្រាន់ក្នុងការថែរក្សាកូនបង្កើតបានឡើងវិញនោះ ឪពុកម្តាយបង្កើតអាចដាក់ពាក្យបណ្តឹងទាមទារឱ្យមានការកាត់កាល់បាន។[29] លើសពីនេះទៅទៀតក៏នៅមានចំណុចមួយចំនួនផ្សេងទៀតដែលជាមូលហេតុនៃបណ្តឹងទាមទារនៃការកាត់កាល់ផងដែរ គឺអាស្រ័យទៅលើឆន្ទានុសិទ្ធិរបស់តុលាការ បើតុលាការយល់ឃើញថា មានភស្តុតាងបញ្ជាក់ពីអត្ថិភាពនៃលក្ខខណ្ឌនៃការកាត់កាល់ ដូចបានកំណត់ខាងលើនេះ នោះតុលាការនឹងសម្រេចចេញសាលក្រមដើម្បីប្រកាសពីការកាត់កាល់សុំកូនពេញលេញបាន។

**ឧទាហរណ៍ ៖** បន្ទាប់ពីបានបង្កើតសុំកូនពេញលេញរួចរាល់ហើយ កូនសុំបានទៅរស់នៅជាមួយនឹងឪពុកម្តាយចិញ្ចឹម។ នៅក្នុងអំឡុងពេលនៃការរស់នៅជាមួយនឹងឪពុកម្តាយចិញ្ចឹម កូនសុំបានទទួលរងនូវការធ្វើបាបឥតត្រាប្រណីពីសំណាក់ម្តាយចិញ្ចឹម ហើយឪពុកចិញ្ចឹមក៏មិនបានចាត់វិធានការណាមួយដើម្បីទប់ស្កាត់សកម្មភាពធ្វើបាបរបស់ម្តាយចិញ្ចឹមមកលើកូនសុំដែរ។ ជាងនេះទៅទៀតឪពុកម្តាយបង្កើតរបស់កូនសុំដែលធ្លាប់តែមានជីវភាពក្រីក្រ ដោយសារតែមានជម្ងឺប្រចាំកាយ ក៏បបានធូរស្បើយហើយបានប្រកបកិច្ចការជំនួញដើម្បីចិញ្ចឹមជីវភាពបានល្អប្រសើរជាងមុន។ ក្នុងករណីបែបនេះ ឪពុកម្តាយបង្កើតដែលមានបំណងចង់ទាមទារ

[28] មើលមាត្រា១០១៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[29] មើលមាត្រា១០១៦.១.ខ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

យកកូនមកវិញ ត្រូវដាក់ពាក្យបណ្ដឹងទាមទារកាត់កាល់ ហើយបើតុលាការយល់ឃើញថា មានភស្តុតាងបញ្ជាក់ពីអត្ថិភាពនៃលក្ខខណ្ឌដូចដែលបានកំណត់ នោះតុលាការនឹងសម្រេចសាលក្រមដើម្បីប្រកាសពីការកាត់កាល់សុំកូនពេញលេញ។

* **សម្គាល់** : នៅក្នុងករណីដែលឪពុកម្ដាយចិញ្ចឹមបានធ្វើបាបកូន ក៏ប៉ុន្តែឪពុកម្ដាយបង្កើតមិនមានលទ្ធភាពដើម្បីគ្រប់គ្រងថែរក្សាកូនទេ ឬបានស្លាប់បាត់បង់ជីវិតទៅហើយ ដូចនេះតុលាការមិនអាចកាត់កាល់សុំកូនពេញលេញបានទេ ពីព្រោះតែខ្វះលក្ខខណ្ឌទី២ នៃមាត្រា១០១៦ ដែលកំណត់ដោយច្បាប់។ នៅក្នុងករណីនេះគេអាចប្រើវិធីការព្យួរ ឬដកហូតអំណាចមេបាពីឪពុកម្ដាយចិញ្ចឹម [30] ហើយជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនវិញ ដើម្បីការពារផលប្រយោជន៍របស់អនីតិជននោះ។

### កថាភាគទី ២. អ្នកដែលមានសិទ្ធិកាត់កាល់សុំកូនពេញលេញ

ក្រោយពីស្វែងយល់អំពីមូលហេតុនៃការកាត់កាល់ហើយ ការកាត់កាល់កូនសុំពេញលេញមិនមែនសុទ្ធតែអាចធ្វើឡើងដោយបុគ្គលគ្រប់រូបបានឡើយ ព្រោះការកាត់កាល់នាំឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កុមារដែលជាកូនសុំ ដូច្នេះហើយបានជាច្បាប់បានបញ្ញត្តិយ៉ាងច្បាស់ពីអ្នកដែលអាចមានសិទ្ធិដាក់ពាក្យបណ្ដឹងសុំកាត់កាល់សុំកូននេះបាន ហើយបុគ្គលទាំងនោះមានដូចជាកូនសុំ ឪពុកម្ដាយបង្កើត និងតំណាងអយ្យការ។ ដោយឡែកចំពោះឪពុកម្ដាយចិញ្ចឹម មិនត្រូវបានច្បាប់ទទួលស្គាល់ថាជាអ្នកមានសិទ្ធិដាក់ពាក្យសុំកាត់កាល់សុំកូនពេញលេញឡើយ។ ដូចនេះ ឪពុកម្ដាយចិញ្ចឹមគ្មានសិទ្ធិដាក់ពាក្យសុំកាត់កាលសុំកូនពេញលេញទេ ទោះក្នុងកាលៈទេសៈណាក៏ដោយ។

#### ១. តំណាងអយ្យការ

នៅក្នុងក្រមរដ្ឋប្បវេណីតំណាងអយ្យការគឺជាគូក្ដីរណបនៅក្នុងនីតិវិធីតុលាការ។ ក្នុងករណីដែលយល់ឃើញថាចាំបាច់ត្រូវការពារនូវផលប្រយោជន៍របស់សាធារណៈ តុលាការត្រូវជូនដំណឹងទៅតំណាងអយ្យការថាពាក្យបណ្ដឹងបានទទួល។ ទោះបីជាគ្មានការជូនដំណឹងដូចបានកំណត់ខាងលើពីតុលាការក៏ដោយក៏តំណាងអយ្យការអាចចូលរួមនៅក្នុងនីតិវិធីនៃបណ្ដឹងរដ្ឋប្បវេណី និងបញ្ចេញយោបល់បានដែរ ប្រសិនបើយល់ឃើញថាដើម្បីការពារប្រយោជន៍សាធារណៈ។ [31]

#### ២. ឪពុកម្ដាយបង្កើត

បើមានការធ្វើបាបដោយឪពុកម្ដាយចិញ្ចឹម បោះបង់កូនចោលដោយគំនិតទុច្ចរិត ឬហេតុផលផ្សេងៗដែលបំពានដល់ផលប្រយោជន៍កូនសុំយ៉ាងធ្ងន់ធ្ងរនោះ ឪពុកម្ដាយបង្កើតមានសិទ្ធិធ្វើការប្ដឹងទាមទារឱ្យមានការ

---

[30] មើលមាត្រា១០៤៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[31] មើលមាត្រា៦ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

កាត់កាលស្មុំកូនពេញលេញបាន ដោយយោងតាមាត្រា១០១៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។ ការអនុញ្ញាត បែបនេះដោយសារតែឪពុកម្តាយបង្កើតជាអ្នកដែលបង្កើតកូនសុំនោះ ទើបច្បាប់បានផ្តល់សិទ្ធិឱ្យឪពុកម្តាយ បង្កើតមានសិទ្ធិនៅក្នុងការកាត់កាលនេះដោយផ្អែកទៅលើជីវភាពព្រោះក្រោយពេលកាត់កាលឪពុកម្តាយបង្កើត គឺជាអ្នកចិញ្ចឹមបីបាច់ថែរក្សាកូនសុំវិញ។

**៣. កូនសុំ**

ដើម្បីធានានូវផលប្រយោជន៍របស់កូនសុំ ក្រមរដ្ឋប្បវេណីបានផល់សិទ្ធិឱ្យកូនសុំដាក់ពាក្យប្តឹងទាមទារ ឱ្យកាត់កាលស្មុំកូនពេញលេញបានដោយយោងផ្អែកទៅលើមូលហេតុដែលបានរៀបរាប់នៅខាងលើ ទោះបីជា កូនសុំនោះជាអនីតិជនក៏ដោយ។

**កថាភាគទី ៣. អានុភាពនៃការកាត់កាល់ស្មុំកូនពេញលេញ**

តាមក្រមរដ្ឋប្បវេណីកម្ពុជាយើងបានទទួលស្គាល់នូវការបង្កើតឡើងវិញ ដោយស្វ័យប្រវត្តិនូវញាតិភាព រវាងកូនសុំ និងឪពុកម្តាយបង្កើត និងញាតិភាពជាមួយញាតិលោហិតរបស់ឪពុកម្តាយបង្កើត នឹងកូនសុំក្រោយ ពីបញ្ចប់ដោយស្មុំកូនពេញលេញត្រូវបានកើតឡើងវិញគិតចាប់ពីថ្ងៃដែលបានកាត់កាល់។ [32] រីឯញាតិភាពរវាង កូនចិញ្ចឹមសហព័ទ្ធរបស់ជននោះ បច្ចាញាតិផ្ទាល់ និងសហព័ទ្ធរបស់បច្ចាញាតិផ្ទាល់នោះ ជាមួយឪពុកម្តាយចិញ្ចឹម និងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹមនោះ ត្រូវបានបញ្ចប់ដោយការកាត់កាល់ ឬលែងទទួលស្គាល់។

សរុបសេចក្តីមក អានុភាពនៃសាលក្រមសម្រេចកាត់កាល់ស្មុំកូនពេញលេញនឹងធ្វើឱ្យមានការកាត់ផ្តាច់ ទំនាក់ទំនងញាតិរវាងឪពុកម្តាយចិញ្ចឹម និងកូនសុំហើយបង្កើតឡើងវិញនូវទំនាក់ទំនងញាតិភាពជាមួយនឹង ឪពុកម្តាយបង្កើតវិញ។

[32] មើលមាត្រា១០១៧ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

# ជំពូកទី ៣

# សុំកូនធម្មតា

## ផ្នែកទី ១. សញ្ញាណទូទៅនៃសុំកូនធម្មតា

### កថាភាគទី ១. និយមន័យ

សុំកូនធម្មតា សម្ដៅដល់ការសុំកូនដែលកូននោះ អាចជាអនីតិជន ឬនីតិជនដោយមិនកាត់ផ្ដាច់ញាតិភាពពីឪពុកម្ដាយបង្កើត ហើយការសុំនេះត្រូវសម្រេចដោយតុលាការ។ ការសុំកូនធម្មតាមិនខុសប្លែកពីករណីសុំកូនពេញលេញឡើយ ការបង្កើតសុំកូនធម្មតាត្រូវអនុលោមទៅតាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ក៏ប៉ុន្តែសុំកូននេះមិនមានអានុភាពបញ្ចប់ញាតិភាពរវាងកូនសុំ និងឪពុកម្ដាយបង្កើតឡើយ។ ទន្ទឹមនឹងនេះផងដែរការកាត់កាល់សុំកូនធម្មតាអាចធ្វើទៅបានតាមរបៀបពីរយ៉ាង ពោលគឺខុសប្លែកបីលក្ខខណ្ឌនៃការកាត់កាល់សុំកូនពេញលេញ។

### កថាភាគទី ២. លក្ខណៈពិសេសនៃសុំកូនធម្មតា

ដោយសារតែសុំកូនធម្មតាមិនមានលក្ខណៈតឹងរឹងដូចសុំកូនពេញលេញទេ ដូច្នេះលក្ខខណ្ឌផ្សេងៗដែលទាក់ទងនឹងករណីយកិច្ច និងសិទ្ធិក៏ងាយស្រួលក្នុងការទទួលយកផងដែរ ដូចជាញាតិភាពរវាងកូនសុំ និងឪពុកម្ដាយបង្កើតនៅតែបន្តអត្ថិភាពរហូត ហើយកូនសុំ និងឪពុកម្ដាយបង្កើតនៅតែមានសិទ្ធិធ្វើសន្តតិកម្មឱ្យគ្នាទៅវិញទៅមក។ កូនសុំធម្មតានឹងទទួលបានគ្រប់លក្ខខណ្ឌ ដែលកូនបង្កើតនៃឪពុកម្ដាយចិញ្ចឹមទទួលបានទាំងសិទ្ធិ និងករណីយកិច្ច។

## ផ្នែកទី ២. លក្ខខណ្ឌនៃការបង្កើតសុំកូនធម្មតា

លក្ខខណ្ឌនៃការបង្កើតកូនសុំធម្មតា ក៏មិនខុសពីលក្ខខណ្ឌនៃការបង្កើតសុំកូនពេញលេញប៉ុន្មានដែរ មានដូចជាអាយុរបស់ឪពុកម្ដាយចិញ្ចឹម និងកូនសុំ ការចូលរួមរបស់សហព័ន្ធម្ខាងរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយបង្កើត និងមូលដ្ឋានវិនិច្ឆ័យដែលតុលាការនឹងពិចារណា។

ដើម្បីបង្កើតសុំកូនធម្មតា លក្ខខណ្ឌមួយចំនួនត្រូវតែបំពេញជាពិសេស គឺត្រូវបង្កើតឡើងដោយសេចក្ដីសម្រេចរបស់តុលការ។

### កថាភាគទី ១. លក្ខខណ្ឌទាក់ទងនឹងបុគ្គលដែលនឹងក្លាយឪពុកម្ដាយចិញ្ចឹម

#### ១. អាយុរបស់ឪពុកម្ដាយចិញ្ចឹម

បុគ្គលដែលក្លាយជាឪពុកម្ដាយចិញ្ចឹមត្រូវមានអាយុចាប់ពី ២៥( ម្ភៃប្រាំ )ឆ្នាំ ឡើងទៅអាចដាក់ពាក្យសុំជាមួយនឹងបុគ្គលដែលនឹងក្លាយជាកូនសុំ ទៅតុលាការឱ្យបង្កើតសុំកូនធម្មតាបាន។ ហើយបុគ្គលដែលនឹងក្លាយទៅជាកូនសុំមិនត្រូវជាបុព្វញាតិរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម ឬបុគ្គលដែលមានអាយុច្រើន

ជាងបុគ្គលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមឡើយ។[33] មានន័យថា អាយុរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមត្រូវបានកម្រិត ដោយឱ្យមានអាយុចាប់ពី ២៥( ម្ភៃប្រាំ )ឆ្នាំ។

**២. ស្ថានភាពរបស់ឪពុកម្ដាយចិញ្ចឹម**

បុគ្គលដែលនឹងក្លាយទៅជាឪពុកម្ដាយចិញ្ចឹមអាចជាបុគ្គលដែលមានសហព័ទ្ធ ឬបុគ្គលដែលគ្មានសហព័ទ្ធក៏បាន។

ចំពោះបុគ្គលដែលមានសហព័ទ្ធចង់សុំកូនធម្មតា ចាំបាច់ត្រូវតែមានការយល់ព្រមពីសំណាក់សហព័ទ្ធម្ខាងទៀត ទើបសហព័ទ្ធម្ខាងទៀតអាចដាក់ពាក្យសុំបង្កើតសុំកូនបាន។

ចំពោះកូនសុំជានីតិជន ករណីដែលមានសហព័ទ្ធតែម្ខាងជាអ្នកដាក់ពាក្យសុំសុំកូនធម្មតា នោះកូនសុំមានអានុភាពចំពោះតែអ្នកដាក់ពាក្យសុំតែប៉ុណ្ណោះ។

ចំពោះកូនសុំជាអនីតិជន បុគ្គលដែលមានសហព័ទ្ធត្រូវដាក់ពាក្យសុំដោយសហការគ្នា ទើបអាចបង្កើតសុំកូនធម្មតាបាន។[34] ប៉ុន្តែបើក្នុងករណីយកកូនរបស់សហព័ទ្ធម្ខាងទៀតមកធ្វើជាកូនសុំ ឬសហព័ទ្ធម្ខាងទៀតមិនអាចបង្ហាញឆន្ទៈបាន ដោយសារមានជម្ងឺផ្នែកស្មារតី ជាដើម នោះសុំកូនអាចបង្កើតឡើងបានដោយសហព័ទ្ធតែម្ខាងតែប៉ុណ្ណោះ។[35]

បុគ្គលដែលជាឪពុកម្ដាយចិញ្ចឹម ត្រូវតែមានឆន្ទៈពិតប្រាកដក្នុងការបង្កើតទំនាក់ទំនងសុំកូន។

**កថាភាគទី ២. លក្ខខណ្ឌទាក់ទងនឹងកូនសុំ**

**១. អាយុរបស់កូនសុំ**

នៅក្នុងលក្ខខណ្ឌសុំកូនធម្មតាមិនត្រូវបានកំណត់ជាដាច់ខាតឡើយពីអាយុរបស់បុគ្គលដែលនឹងក្លាយជាកូនសុំ ដូច្នេះកូនសុំអាចជាអនីតិជន ឬនីតិជន ប៉ុន្តែចំនុចដែលសំខាន់នោះ គឺបុគ្គលដែលនឹងក្លាយជាកូនសុំមិនត្រូវជាបុព្វញាតិរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមទេ មិនតែប៉ុណ្ណោះបុគ្គលដែលនឹងក្លាយជាកូនសុំមិនត្រូវមានអាយុលើសពីបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមឡើយ។

**២. ស្ថានភាពរបស់កូនសុំ**

តុលាការអាចបង្កើតសុំកូនធម្មតាបាន លុះត្រាតែមានការបង្ហាញឆន្ទៈពិតប្រាកដរបស់ភាគីក្នុងការបង្កើតទំនាក់ទំនងរវាងឪពុកម្ដាយ និងកូន។ បើតុលាការយល់ឃើញថា សុំកូនបានបំពានក្នុងគោលបំណងរៀបអាពាហ៍ពិពាហ៍រវាងបុគ្គល ដែលមានភេទផ្សេងគ្នា ឬដូចគ្នា ឬក្នុងគោលបំណងមិនត្រឹមត្រូវផ្សេងទៀត តុលាការ

[33] មាត្រា១០២០.១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[34] មើលមាត្រា១០២១.១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[35] មើលមាត្រា១០២១.២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

នឹងមិនចេញសេចក្តីសម្រេចស្មុំកូនធម្មតាឡើយ។[36] ក្នុងករណីបើបុគ្គលដែលនឹងក្លាយជាកូនសុំជាអនីតិជន អ្នកដែលត្រូវផ្តល់ការយល់ព្រមទៅនឹងការស្មុំកូនធម្មតា គឺអ្នកតំណាងដែលច្បាប់បានកំណត់របស់អនីតិជន ពោលគឺអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន។[37]

បើអនីតិជនបានដល់អាយុ ១៥( ដប់ប្រាំ )ឆ្នាំ ដើម្បីបង្កើតការស្មុំកូនត្រូវទទួលការយល់ព្រមពីអនីតិជននោះ។ ទោះបីជាអនីតិជននោះមិនទាន់ដល់អាយុ ១៥( ដប់ប្រាំ )ឆ្នាំ ក៏ដោយបើអនីតិជននោះអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន តុលាការត្រូវសួរយោបល់របស់អនីតិជន ដើម្បីវិនិច្ឆ័យអំពីភាពចាំបាច់ពិសេស ដើម្បីផលប្រយោជន៍របស់អនីតិជន។[38]

ករណីបុគ្គលដែលនឹងក្លាយជាកូនសុំជាអនីតិជន តុលាការអាចឱ្យបង្កើតស្មុំកូនបានលុះត្រាតែយល់ឃើញថាមានភាពចាំបាច់ពិសេស ដើម្បីផលប្រយោជន៍របស់អនីតិជននោះ។[39] ក្នុងករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំជាអនីតិជន បើឪពុកម្តាយបង្កើតរបស់បុគ្គលនោះលែងលះ ហើយតុលាការត្រូវសួរយោបល់របស់ឪពុក ឬម្តាយដែលមិនមែនជាអ្នកមានអំណាចមេបា ដើម្បីវិនិច្ឆ័យអំពីចំណុចដែលកំណត់ក្នុងចំណុចខាងលើដោយយោងតាមមាត្រា១០២៤ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ទន្ទឹមនឹងនេះ បើក្នុងករណីកូនសុំជានីតិជន តុលាការនឹងសម្រេចឱ្យបង្កើតស្មុំកូនធម្មតា បើពិនិត្យទៅឃើញថាមានឆន្ទៈពិតប្រាកដក្នុងការបង្កើតទំនាក់ទំនងស្មុំកូនធម្មតាជាមួយនឹងឪពុកម្តាយចិញ្ចឹម។[40]

**កថាភាគទី ៣. នីតិវិធីនៃការស្មុំកូនធម្មតា**

នីតិវិធីនៃស្មុំកូនធម្មតា គឺស្រដៀងនឹងនីតិវិធីនៃស្មុំកូនពេញលេញដែរគ្រាន់តែវាមានភាពខុសគ្នាបន្តិចបន្តួចត្រង់ចំណុចខ្លះៗ។

**១. ការដាក់ពាក្យសុំ**

បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមត្រូវដាក់ពាក្យសុំបង្កើតស្មុំកូនធម្មតាទៅតុលាការ។ ការតម្រូវឱ្យឆ្លងកាត់ផ្លូវតុលាការវាជាការចាំបាច់ ព្រោះកម្មវត្ថុនៃស្មុំកូនធម្មតាអាចជាអនីតិជន ឬនីតិជន ហើយការកំណត់បែបនេះដើម្បីឱ្យមានការស្រាវជ្រាវ និងវិនិច្ឆ័យដោយប្រុងប្រយ័ត្នពីផលប្រយោជន៍របស់កុមារ។

[36] មើលមាត្រា១០២៣.២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[37] មើលមាត្រា១០២០.២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[38] មើលមាត្រា១០២៤.៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[39] មាត្រា១០២៤.១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[40] មើលមាត្រា១០២៣.១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

### ២. អ្នកមានសិទ្ធិក្នុងការដាក់ពាក្យសុំ

ក្នុងករណីដែលកូនសុំជានីតិជន បុគ្គលដែលក្លាយជាឪពុកម្តាយចិញ្ចឹមត្រូវដាក់ពាក្យសុំរួមគ្នាជាមួយបុគ្គលដែលនឹងក្លាយជាកូនសុំ។ [41] បើបុគ្គលដែលជាកូនសុំជាបុគ្គលដែលមានសហព័ទ្ធ បុគ្គលនោះមិនចាំបាច់ត្រូវមានការយល់ព្រមពីសហព័ទ្ធនៃបុគ្គលដែលនឹងក្លាយជាកូនសុំនោះទេ ព្រោះសុំកូនធម្មតាបង្កើតឡើងដោយឆន្ទៈរបស់ភាគីផ្ទាល់។ បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមត្រូវដាក់ពាក្យសុំរួមជាមួយអ្នកមានអំណាចមេបា ឬអាណាព្យាបាលសម្រាប់អនីតិជនរបស់កូនសុំក្នុងនាមជាអ្នកមានអំណាចមេបា។ [42] បើកូនសុំជាអនីតិជនដែលមានអាយុដល់ ១៥ឆ្នាំ គឺការដាក់ពាក្យសុំត្រូវមានការយល់ព្រមពីអនីតិជននោះ។ មានន័យថា បើអនីតិជននោះបដិសេធសុំកូននឹងមិនអាចបង្កើតបានឡើយ។ [43]

### ៣. ទម្រង់នៃការដាក់ពាក្យសុំ

ទម្រង់នៃពាក្យសុំសុំកូនធម្មតា គឺដូចគ្នានឹងទម្រង់នៃពាក្យសុំសុំកូនពេញលេញដែរ។ ពាក្យសុំនេះអាចធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់បាន។ ពាក្យសុំត្រូវសរសេរបញ្ជាក់នូវចំណុចដូចខាងក្រោម ៖

ក- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់អ្នកដែលដាក់ពាក្យសុំ ( ឪពុកម្តាយចិញ្ចឹម ) ហើយឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ( ឪពុកម្តាយបង្កើត និងកូនសុំ )។

ខ- ខ្លឹមសារនៃដីកាសម្រេច ឬសកម្មភាពផ្សេងៗទៀតរបស់តុលាការ ដែលអ្នកដាក់ពាក្យសុំទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ។

ដើម្បីដាក់ពាក្យសុំដោយផ្ទាល់មាត់ អ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្តីថ្លែងការណ៍នូវចំណុចនីមួយៗ ដែលកំណត់ក្នុងកថាខណ្ឌទី២ ខាងលើនេះ នៅចំពោះមុខក្រឡាបញ្ជី។ ក្នុងករណីនេះក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុ និងចុះហត្ថលេខា។ កំណត់ហេតុនេះត្រូវបានកំណត់ថាជាពាក្យសុំ។ បន្ថែមពីលើនេះ អ្នកដាក់ពាក្យសុំត្រូវបង្ហាញនៅក្នុងពាក្យសុំរបស់ខ្លួនពីអង្គហេតុដែលជាមូលហេតុនៃការទាមទារដូចជា ៖

- អង្គហេតុដែលបញ្ជាក់ថាខ្លួន និងកូនសុំបានបំពេញតាមគ្រប់លក្ខខណ្ឌដែលច្បាប់បានតម្រូវ
- អង្គហេតុដែលបញ្ជាក់ថាឪពុកម្តាយបង្កើត ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនកូនសុំបានយល់ព្រមចំពោះការបង្កើតសុំធម្មតា
- អង្គហេតុដែលបញ្ជាក់ថាមានស្ថានភាពចាំបាច់ពិសេស ក្នុងការបង្កើតសុំកូនដើម្បីជាផលប្រយោជន៍របស់កូនសុំជាដើម។ល។

[41] មើលមាត្រា១០២០.១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[42] មើលមាត្រា១០២០.២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[43] មើលមាត្រា១០២៤.៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

**៤. ទីកន្លែងនៃការដាក់ពាក្យសុំ**

ពាក្យសុំត្រូវដាក់នៅតុលាការខាងលំនៅឋានរបស់បុគ្គលដែលនឹងក្លាយជាកូនសុំ។[44]

**ឧទាហរណ៍ ៖** លោក សម្បត្តិ មានអាយុ ៤០ឆ្នាំ ជាបុរសពោះម៉ាយដែលមានទីលំនៅនៅរាជធានីភ្នំពេញ ហើយគាត់មានបំណងសុំយកលោក វិចិត្រ ភេទប្រុស អាយុ ២០ឆ្នាំ ដែលមានទីលំនៅនៅខេត្តកណ្ដាលមកធ្វើជាកូនសុំធម្មតា។ ក្នុងករណីនេះ លោក សម្បត្តិ និងលោក វិចិត្រ ត្រូវដាក់ពាក្យសុំព្រមគ្នាទៅតុលាការខេត្តកណ្ដាលដើម្បីអាចបង្កើតស្មុំកូនធម្មតាបាន។

**៥. ពន្ធដែលត្រូវបង់នៅពេលដាក់ពាក្យសុំ**

ពន្ធដែលត្រូវបង់នៅពេលដាក់ពាក្យសុំស្មុំកូនធម្មតា គឺដូចនឹងពន្ធដាក់ពាក្យសុំស្មុំកូនពេញលេញដែរ គឺអ្នកដែលដាក់ពាក្យសុំត្រូវបង់ពន្ធចំនួន ៥០០០( ប្រាំពាន់ )រៀល។[45]

**៦. មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតស្មុំកូនធម្មតា**

តុលាការអាចឱ្យបង្កើតស្មុំកូនធម្មតាបានលុះត្រាតែឈរផ្អែកទៅលើមូលដ្ឋានដូចខាងក្រោម ៖

ក. ករណីដែលមានការបញ្ជាក់អំពីឆន្ទៈពិតប្រាកដរបស់ភាគី ក្នុងការបង្កើតទំនាក់ទំនងរវាងឪពុកម្ដាយ និងកូន។[46]

ខ. តុលាការមិនត្រូវឱ្យបង្កើតស្មុំកូនឡើយ បើយល់ឃើញថាស្មុំកូនត្រូវបានបំពានក្នុងគោលបំណងរៀបអាពាហ៍ពិពាហ៍រវាងភេទផ្សេងគ្នា ឬភេទដូចគ្នា ឬក្នុងគោលបំណងមិនត្រឹមត្រូវផ្សេងទៀត។[47]

ប្រសិនបើកូនសុំ ជាអនីតិជនតុលាការអាចឱ្យបង្កើតស្មុំកូនបានលុះត្រាតែយល់ឃើញថាមានភាពចាំបាច់ពិសេស ដើម្បីផលប្រយោជន៍របស់កូនសុំ ដែលជាអនីតិជននោះ។ តុលាការត្រូវពិចារណាអំពីឆន្ទៈរបស់អនីតិជន កាលបើអនីតិជនមានអាយុ ១៥ឆ្នាំ ហើយទោះបីជាពុំមានអាយុ ១៥ឆ្នាំ ក៏ដោយក៏តុលាការអាចសួរយោបល់ពីអនីតិជនបានដែរ។ លើសពីនេះទៅទៀត ក្នុងករណីឪពុកម្ដាយបង្កើតលែងលះគ្នា មុននឹងបង្កើតស្មុំកូនធម្មតាតុលាការត្រូវសួរយោបល់ឪពុកបង្កើត ឬម្ដាយបង្កើត ដែលមិនមែនជាអ្នកមានអំណាចមេបា។

**កថាភាគទី ៤. ដីកាសម្រេច**

ដីកាសម្រេច គឺជាការសម្រេចសេចក្ដីដែលតុលាការ ឬចៅក្រមអាចធ្វើដោយមិនឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់បាន ហើយមិនមែនជាសាលក្រម។[48] ការបង្កើតស្មុំកូនធម្មតា តុលាការត្រូវចេញដីកា

---

[44] មើលឧបសម្ព័ន្ធទី៤ .៩ ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីមិនមែនជាបណ្ដឹង ឆ្នាំ២០១០។

[45] មាត្រា២២.១ ច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ឆ្នាំ២០១០។

[46] មើលមាត្រា១០២៣.១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[47] មើលមាត្រា១០២៣.២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[48] មាត្រា១៧៩.២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

សម្រេចអំពីពាក្យសុំនៃស្នុំកូនធម្មតា។ ប្រសិនបើតុលាការយល់ឃើញថាពាក្យសុំនៃស្នុំកូនធម្មតាបានបំពេញលក្ខខណ្ឌទាំងអស់ តុលាការត្រូវចេញដីកាសម្រេចដែលទទួលស្គាល់ស្នុំកូនធម្មតា ផ្ទុយទៅវិញ ប្រសិនបើតុលាការយល់ឃើញថា ពាក្យសុំនៃស្នុំកូនធម្មតាមិនបានបំពេញលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌដែលកំណត់នៅក្នុងក្រមរដ្ឋប្បវេណីទេ នោះតុលាការត្រូវចេញដីកាសម្រេចដែលលើកចោលពាក្យសុំនោះ។

ដីកាសម្រេចអំពីពាក្យសុំនៃស្នុំកូនធម្មតា ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ត្រូវសរសេរសំអាងហេតុ និងសេចក្ដីសម្រេចបញ្ចប់ ហើយចៅក្រមត្រូវចុះហត្ថលេខាលើសេចក្ដីសម្រេចនោះ។ ការសរសេរសំអាងហេតុខាងលើនេះគឺដើម្បីធានាភាពមិនលំអៀងក្នុងការវិនិច្ឆ័យរបស់ចៅក្រម។ ម្យ៉ាងវិញទៀត ការសរសេរសំអាងហេតុនេះ ត្រូវតែបង្ហាញឱ្យបានច្បាស់លាស់នូវមូលហេតុនៃការវិនិច្ឆ័យនេះចំពោះភាគី ដើម្បីឱ្យភាគីមានភាពងាយស្រួលក្នុងការប្ដឹងជំទាស់។ ក្នុងករណីដែលតុលាការទទួលស្គាល់ស្នុំកូនធម្មតា លិខិតដីកាសម្រេចត្រូវសរសេរសេចក្ដីសម្រេចបញ្ចប់ដែលប្រកាសថា " អ្នកដាក់ពាក្យសុំឈ្មោះ ក ត្រូវក្លាយទៅជាកូនរបស់អ្នកដាក់ពាក្យសុំឈ្មោះ ខ តាមរយៈស្នុំកូនធម្មតា " ជាដើម។

នៅពេលតុលាការបានចេញដីកាសម្រេចអំពីពាក្យសុំនៃស្នុំកូនធម្មតា តុលាការត្រូវជូនដំណឹងអំពីដីកាសម្រេចនេះទៅជនដែលត្រូវទទួលដីកាសម្រេចនោះ។[49] ចំពោះវិធីជូនដំណឹងអំពីដីកាសម្រេច គឺមិនចាំបាច់ត្រូវធ្វើតាមរយៈការបញ្ជូន ដូចជាវិធីដែលក្រឡាបញ្ជីប្រគល់ដោយផ្ទាល់ទេ។ ក្រៅពីការបញ្ជូនបែបនេះ វិធីជូនដំណឹងអំពីដីកាសម្រេច ក៏អាចធ្វើតាមរយៈការផ្ញើ ដូចជាការផ្ញើតាមប្រៃសណីយ៍ ជាដើម។

ដីកាសម្រេចអំពីពាក្យសុំ នៃស្នុំកូនធម្មតាត្រូវចូលជាស្ថាពរនៅពេលអំឡុងពេលសម្រាប់ប្ដឹងជំទាស់បានកន្លងហួស ឬពេលដែលតុលាការនៃបណ្ដឹងជំទាស់ ដែលសំដៅដល់សាលាឧទ្ធរណ៍បានចេញដីកាសម្រេចអំពីបណ្ដឹងជំទាស់នោះ។ [50] ហេតុដូច្នេះ ទោះបីជាដីកាសម្រេចអំពីពាក្យសុំនៃស្នុំកូនធម្មតា ត្រូវបានជូនដំណឹងទៅអ្នកដាក់ពាក្យសុំក៏ដោយ ក៏ដីកាសម្រេចនេះមិនត្រូវមានអានុភាពមុនពេលផុតអំឡុងពេលសម្រាប់ប្ដឹងជំទាស់ឡើយ ។ ម្យ៉ាងទៀត ប្រសិនបើមានបណ្ដឹងជំទាស់ដីកាសម្រេចអំពីពាក្យសុំនៃស្នុំកូនធម្មតា មិនត្រូវមានអានុភាពទេ រហូតដល់ពេលសាលាឧទ្ធរណ៍ចេញដីកាសម្រេចអំពីពាក្យបណ្ដឹងជំទាស់នោះ។

### កថាភាគទី ៥. បណ្តឹងជំទាស់

បុគ្គលទទួលឥទ្ធិពលដែលខូចប្រយោជន៍ដល់សិទ្ធិ ឬឋានៈគតិយុត្តរបស់ខ្លួនដោយសារដីកាសម្រេចអំពីពាក្យសុំនៃស្នុំកូនធម្មតាអាចប្ដឹងជំទាស់បាន។ ដើម្បីប្ដឹងជំទាស់ អ្នកដាក់ពាក្យបណ្ដឹងជំទាស់ត្រូវបង់ពន្ធចំនួន ៥.០០០(ប្រាំពាន់)រៀល។ ប្រសិនបើអ្នកដាក់ពាក្យបណ្ដឹងជំទាស់ មិនបានបង់ពន្ធខាងលើនេះទេ តុលាការត្រូវកំណត់អំឡុងពេលសមរម្យ និងបង្គាប់ឱ្យបង់ពន្ធនោះ។ ក្នុងករណីនេះ ប្រសិនបើអ្នកដាក់ពាក្យបណ្ដឹងជំទាស់នៅតែមិនបានបង់ពន្ធទេនោះ តុលាការត្រូវលើកលិខិតពាក្យបណ្ដឹងជំទាស់ចោលបានដោយដីកាសម្រេច។ [51]

[49] មើលមាត្រា៣៦ ច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ឆ្នាំ២០១០។

[50] មើលមាត្រា៣៧ ច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ឆ្នាំ២០១០។

[51] មើលមាត្រា២២.៨ នៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ឆ្នាំ២០១០។

មាត្រា៤០ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង បានចែងអំពីអំឡុងពេលសម្រាប់ប្តឹងជំទាស់។ នៅក្នុងអំឡុងពេលនេះ ជនដែលអាចប្តឹងជំទាស់ អាចប្តឹងជំទាស់បានដោយត្រូវតែដាក់ពាក្យបណ្តឹងជំទាស់ ក្នុងអំឡុងពេល ២សប្តាហ៍ ដោយគិតចាប់ពីថ្ងៃទទួលការជូនដំណឹងអំពីដីកាសម្រេចនោះ។ [52] អំឡុងពេលសម្រាប់ប្តឹងជំទាស់នោះ ពុំអាចពន្យារបានឡើយ។ [53]

## ផ្នែកទី ៣. អានុភាពនៃសុំកូនធម្មតា

នៅពេលដែលបំពេញលក្ខខណ្ឌទាំងឡាយដូចដែលមានកំណត់ខាងលើរួច នាំឱ្យការសុំកូនធម្មតាបានសម្រេចចូលជាស្ថាពរ នោះអានុភាពគតិយុត្តមួយចំនួនក៏បានកើតឡើងដូចខាងក្រោម ៖

### កថាភាគទី ១. ការបង្កើតញាតិភាពរវាងឪពុកម្តាយចិញ្ចឹម

ព្រមពេលជាមួយគ្នានេះដែរ ញាតិភាពរវាងកូនសុំ និងឪពុកម្តាយចិញ្ចឹម ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹមត្រូវបានបង្កើតឡើង។ ត្រង់ចំណុចនេះ គឺមិនខុសប្លែកពីសុំកូនពេញលេញឡើយ ដោយកូនសុំធម្មតាមានសិទ្ធិ និងករណីយកិច្ចដូចគ្នាទៅនឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមដែរ នៅក្នុងទំនាក់ទំនងជាមួយនឹងឪពុកម្តាយចិញ្ចឹម។ លើសពីនេះទៅទៀតកូនសុំធម្មតាអាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹមក៏បាន ឬនាមត្រកូលមុនពេលសុំកូនក៏បាន។ ទន្ទឹមនឹងនេះ ប្រសិនបើកូនសុំជាអនីតិជន កូនសុំនោះត្រូវស្ថិតក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម។ ប៉ុន្តែនៅក្នុងករណីដែលជាសុំកូនរបស់សហព័ទ្ធម្ខាងទៀតកូនសុំជាអនីតិជនត្រូវស្ថិតក្រោមអំណាចមេបារួមរបស់សហព័ទ្ធទាំងសងខាង។ [54]

### កថាភាគទី ២. ការបន្តញាតិភាពរវាងឪពុកម្តាយបង្កើត

សុំកូនធម្មតាមានភាពផ្ទុយគ្នាពីសុំកូនពេញលេញត្រង់ សុំកូនធម្មតានៅតែអាចបន្តញាតិភាពជាមួយឪពុកម្តាយបង្កើតបាន ហេតុនេះកូនសុំ និងឪពុកម្តាយបង្កើតមានសិទ្ធិធ្វើសន្តតិកម្មឱ្យគ្នាទៅវិញទៅមក ហើយក៏មានសិទ្ធិទាមទារអាហារកិច្ចចំពោះគ្នាទៅវិញទៅមកផងដែរ។ មានន័យថា កូនសុំ និងឪពុកម្តាយបង្កើតអាចទទួលបាននូវសិទ្ធិ និងករណីយកិច្ចក្នុងការធ្វើសន្តតិកម្ម ហើយផ្តល់ និងទទួលអាហារកាតព្វកិច្ចពីគ្នាទៅវិញទៅមក។

## ផ្នែកទី ៤. សិទ្ធិរបស់សុំកូនធម្មតា

សិទ្ធិរបស់សុំកូនធម្មតា និងកូនសុំពេញលេញ គឺមានភាពស្រដៀងគ្នា អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺសិទ្ធិរបស់កូនសុំធម្មតាហាក់បីដូចជាមានច្រើនជាងកូនសុំពេញលេញ។ តើអ្វីដែលអាចឱ្យយើងសន្និដ្ឋានថា កូនសុំធម្មតាមានសិទ្ធិច្រើនជាងកូនសុំពេញលេញ? យើងឃើញហើយថា កូនសុំធម្មតាមិនត្រូវបានផ្តាច់ទំនាក់

[52] មើលមាត្រា៤០.១ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០។

[53] មើលមាត្រា៤០.៤ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០។

[54] មើលមាត្រា១០២៧.៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ទំនងញាតិពីឪពុកម្តាយបង្កើតនោះទេ ដូច្នេះកូនសុំធម្មតាអាចទទួលបានផលប្រយោជន៍ពីឪពុកម្តាយបង្កើតផង និងឪពុកម្តាយចិញ្ចឹមផង។

**កថាភាគទី ១. សិទ្ធិក្នុងការជ្រើសរើសនាមត្រកូល**

នៅក្នុងការប្រើប្រាស់នាមត្រកូល កូនសុំធម្មតាក៏មានសិទ្ធិប្រើប្រាស់នាមត្រកូល ដែលខ្លួនពេញចិត្តដូចកូនសុំពេញលេញដែរ ពោលគឺកូនសុំធម្មតាអាចប្រើនាមត្រកូលរបស់ខ្លួនដែលមានមុនពេលក្លាយជាកូនសុំក៏បាន ឬប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹមក៏បាន។ [55] ម៉្យាងវិញទៀត ប្រសិនបើកូនសុំធម្មតាបានដូរនាមត្រកូលពេលសុំកូន នោះក្រោយពីការកាត់កាល់រួចកូនសុំធម្មតាអាចទទួលបានវិញនូវនាមត្រកូលមុនសុំកូនក៏បាន ឬក៏អាចបន្តប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹមក៏បានដែរ។ [56]

**កថាភាគទី ២. សិទ្ធិស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្តាយបង្កើត និងឪពុកម្តាយចិញ្ចឹមរបស់កូនដែលជាអនីតិជន**

កូនសុំពេញលេញតម្រូវឱ្យផ្តាច់ទំនាក់ទំនងញាតិភាពជាមួយឪពុកម្តាយបង្កើត ដូច្នេះគេអាចស្ថិតក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹមនៅក្នុងពេលដែលគេមិនទាន់ក្លាយជានីតិជន។ ប៉ុន្តែចំពោះកូនសុំធម្មតាវិញ គេនៅតែអាចបន្តញាតិលោហិតជាមួយឪពុកម្តាយបង្កើត ដូចនេះហើយទើបច្បាប់បានផ្តល់សិទ្ធិឱ្យកូនសុំធម្មតាស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្តាយបង្កើតផង និងឪពុកម្តាយចិញ្ចឹមផង។

**កថាភាគទី ៣. សិទ្ធិទទួលបានអាហារកាតព្វកិច្ចរបស់កូនដែលជាអនីតិជន**

កូនគ្រប់រូបមិនថាជាកូនបង្កើតក្តី ឬកូនសុំក្តី សុទ្ធតែមានសិទ្ធិទទួលបាននូវអាហារកាតព្វកិច្ចពីឪពុកម្តាយបង្កើត និងឪពុកម្តាយចិញ្ចឹមរបស់ខ្លួន ពីព្រោះវាជាករណីយកិច្ចរបស់ឪពុកម្តាយក្នុងការផ្គត់ផ្គង់កូនដែលជាអនីតិជន។ ដូច្នេះ នៅពេលបង្កើតសុំកូនធម្មតា កូនសុំបានក្លាយជាកូនរបស់ឪពុកម្តាយចិញ្ចឹម ប៉ុន្តែកូននោះនៅតែជាកូនរបស់ឪពុកម្តាយបង្កើតដដែល ដូច្នេះកូនសុំនោះមានសិទ្ធិទទួលបានអាហារកាតព្វកិច្ចពីសំណាក់ឪពុកម្តាយទាំងសងខាង ពោលគឺទាំងឪពុកម្តាយបង្កើត និងឪពុកម្តាយចិញ្ចឹម។ [57]

**កថាភាគទី ៤. សិទ្ធិធ្វើ និងទទួលសន្តតិកម្ម**

យើងបានដឹងពីខាងលើរួចមកហើយថា សន្តតិកម្មជាការផ្ទេរនូវសិទ្ធិ និងករណីយកិច្ចរបស់មរតកជនទៅឱ្យសន្តតិជនម្នាក់ ឬច្រើននាក់ តាមឆន្ទៈ ឬតាមច្បាប់។ ចំពោះសុំកូនពេញលេញ ដែលបានផ្តាច់ទំនាក់ទំនងញាតិពីឪពុកម្តាយបង្កើតហើយនោះ គេអាចទទួលបានសិទ្ធិធ្វើ និងទទួលសន្តតិកម្មតែពីឪពុកម្តាយចិញ្ចឹម និងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹមតែប៉ុណ្ណោះ។

[55] មើលមាត្រា១០២៧.២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[56] មើលមាត្រា១០៣២.២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[57] មើលមាត្រា១០២៦.២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ផ្ទុយទៅវិញ ចំពោះសុំកូនធម្មតា គឺគេទទួលបានផលប្រយោជន៍ច្រើនជាងកូនសុំពេញលេញត្រង់ថា គេនៅតែបន្តទំនាក់ទំនងជាមួយឪពុកម្តាយបង្កើត ដូច្នេះចំពោះសិទ្ធិផ្ញើ និងទទួលសន្តតិកម្ម គេអាចមានសិទ្ធិផ្ញើ និងទទួលសន្តតិកម្មពីឪពុកម្តាយបង្កើត ញាតិលោហិតរបស់ឪពុកម្តាយបង្កើតផង និងឪពុកម្តាយចិញ្ចឹម ញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹមផង។ តាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ កូនរបស់មតកជនត្រូវក្លាយជាសន្តតិជនលំដាប់ទី១ជានិច្ច។[58] ហើយការបែងចែកមត៌កនេះមិនថាកូនបង្កើតក្តី ឬកូនសុំក្តីត្រូវមានចំណែកមត៌កស្មើៗគ្នា ដោយយោងតាមមាត្រា១១៥៦ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។ ក្នុងករណីកូនរបស់មតកជនបានស្លាប់មុន ឬស្របពេលគ្នានឹងការចាប់ផ្តើមសន្តតិកម្ម កូនរបស់ជននោះនឹងក្លាយជាសន្តតិជនជំនួស។ ករណីនេះក៏អនុវត្តផងដែរ ប្រសិនបើកូនរបស់មតកជនបានបាត់បង់សិទ្ធិជាសន្តតិជនដោយមូលហេតុជាអភ័ព្វបុគ្គល ឬត្រូវបានផ្តាច់មត៌ក។ ក្នុងករណីកូនរបស់មតកជនជាកូនសុំ តាមរបបសុំកូនធម្មតាបានធ្វើឡើងមុនពេលកូនសុំមានកូន នៅពេលកូនសុំនោះស្លាប់មុនមតកជន កូនរបស់កូនសុំអាចទទួលបន្តមត៌កក្រោមរូបភាពជាសន្តតិកម្មជំនួស ប៉ុន្តែបើកូនសុំនោះមានកូនមុនពេលភ្ជាប់ទំនាក់ទំនងមតកជន នោះកូនរបស់កូនសុំនៃមតកជនមិនអាចអនុវត្តសិទ្ធិសន្តតិកម្មជំនួសបានទេ។

## ផ្នែកទី ៥. ការកាត់កាល់សុំកូនធម្មតា

ការកាត់កាលសុំកូនធម្មតាមានភាពខុសគ្នាពីសុំកូនពេញលេញ គឺសុំកូនធម្មតាអាចត្រូវកាត់កាល់តាមពីររបៀប ក៏ប៉ុន្តែការកាត់កាល់សុំកូនធម្មតានាំឱ្យមានអានុភាពដូចជាការកាត់កាល់សុំកូនពេញលេញដែរ។ ជាទូទៅការកាត់កាល់សុំកូនធម្មតាអាចធ្វើបានយ៉ាងងាយស្រួល កាលបើមានការព្រមព្រៀងរវាងភាគីនៃសុំកូន ហើយនៅក្នុងករណីដែលភាគីម្ខាងនៃសុំកូនមានគោលបំណងចង់ធ្វើការកាត់កាល់សុំកូនជាឯកតោភាគី គាត់ត្រូវដាក់ពាក្យប្តឹងទៅតុលាការ។

### កថាភាគទី ១. លក្ខខណ្ឌនៃការកាត់កាល់សុំកូនធម្មតា

#### ១. ការកាត់កាល់សុំកូនធម្មតាតាមការព្រមព្រៀង

ទោះជាយ៉ាងណាក៏ដោយក្រោយពីបានបង្កើតសុំកូនធម្មតាហើយ ភាគីនៃសុំកូនអាចព្រមព្រៀងគ្នាដើម្បីកាត់កាល់សុំកូននេះបាន។[59] នៅក្នុងករណីនេះភាគីទាំងសងខាងនៃសុំកូនត្រូវដាក់ពាក្យសុំទៅតុលាការនៃលំនៅឋានរបស់កូនសុំ បន្ទាប់មកតុលាការនឹងធ្វើការសម្រេចសេចក្តីដោយចេញជាដីកាសម្រេច យោងទៅតាមច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។

ម៉្យាងវិញទៀត នៅក្នុងករណីដែលកូនសុំជាអនីតិជន ពាក្យសុំព្រមព្រៀងកាត់កាល់សុំកូនត្រូវធ្វើឡើងដោយឪពុកម្តាយចិញ្ចឹម និងបុគ្គលដែលត្រូវក្លាយជាតំណាងដែលច្បាប់កំណត់របស់អនីតិជននោះ នៅក្រោយពេលកាត់កាល់។ ជាទូទៅបុគ្គលដែលនឹងក្លាយទៅជាអ្នកតំណាងដែលច្បាប់កំណត់របស់អនីតិជនគឺអាចជាឪពុក

[58] មាត្រា១១៥៦.១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[59] មើលមាត្រា១០២៨.១ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

ម្តាយបង្កើត ឬជាអាណាព្យាបាលសម្រាប់អនីតិជននោះតែម្តង។ ប៉ុន្តែប្រសិនបើឪពុកម្តាយបង្កើតរបស់អនីតិជនបានលែងលះគ្នា អ្នកទាំងពីរត្រូវពិភាក្សាគ្នាដើម្បីកំណត់ថា តើនរណាម្នាក់អាចនឹងក្លាយជាអ្នកមានអំណាចមេបាលើអនីតិជន ហើយបើការពិភាក្សាមិនអាចធ្វើបានទេតុលាការជាអ្នកកំណត់ថាឱ្យឪពុកបង្កើត ឬម្តាយបង្កើតដែលនឹងក្លាយជាអ្នកមានអំណាចមេបាលើកូនដែលជាអនីតិជននោះ។

យ៉ាងណាមិញ ក្នុងអត្ថន័យប្រហាក់ប្រហែលទៅនឹងការបង្កើតសុំកូនធម្មតាដែរ ក្រមរដ្ឋប្បវេណីតម្រូវឱ្យកូនសុំជាអនីតិជនដែលមានអាយុ ១៥ឆ្នាំ ត្រូវផ្តល់ការយល់ព្រមទៅនឹងការកាត់កាល់ទៅនឹងសុំកូននោះផងដែរទើបបាន។ ក្រៅពីនេះនៅពេលដែលអនីតិជនអាចបង្ហាញឆន្ទៈបាន តុលាការត្រូវសួរយោបល់របស់អនីតិជននោះផងដែរពាក់ព័ន្ធនឹងការសុំកូនធម្មតា។

ដោយឡែកនៅផ្នែកភាគីឪពុកម្តាយចិញ្ចឹមវិញ ក្រមរដ្ឋប្បវេណីបានតម្រូវឱ្យសហព័ទ្ធទាំងសងខាងដែលជាឪពុកម្តាយចិញ្ចឹមតាមរយៈការដាក់ពាក្យសុំបង្កើតសុំកូនដោយសហការគ្នា ត្រូវដាក់ពាក្យសុំកាត់កាល់សុំកូននោះជាមួយគ្នា លើកលែងតែសហព័ទ្ធណាម្ខាងមិនអាចបង្ហាញឆន្ទៈខ្លួនបាន។

ក្រោយពីបានទទួលពាក្យសុំកាត់កាល់សុំកូន តាមការព្រមព្រៀងនេះរួចហើយ តុលាការត្រូវពិនិត្យមើលថា តើគូភាគីពិតជាមានឆន្ទៈនៅក្នុងការរំលាយទំនាក់ទំនងសុំកូនដែរ ឬទេ មុននឹងធ្វើការសម្រេចសេចក្តីកាត់កាល់សុំកូននេះ។

## ២. ការកាត់កាល់សុំកូនធម្មតាតាមពាក្យបណ្តឹងរបស់ភាគីម្ខាង

ផ្ទុយពីករណីខាងលើ ប្រសិនបើមិនអាចទទួលបានការព្រមព្រៀងក្នុងការស្នើសុំកាត់កាល់សុំកូនធម្មតាបានទេ ភាគីម្ខាងនៃសុំកូនអាចនឹងដាក់ពាក្យបណ្តឹងទាមទារកាត់កាល់សុំកូនធម្មតាបាន ដោយយោងតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។ នៅក្នុងករណីនេះតុលាការត្រូវធ្វើសេចក្តីសម្រេចដោយចេញជាសាលក្រម។

ដោយយោងតាមអត្ថន័យនៃមាត្រា១០៣១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ ភាគីខាងឪពុកម្តាយចិញ្ចឹមអាចដាក់ពាក្យបណ្តឹងទាមទារកាត់កាល់សុំកូនធម្មតាបាន ហើយម្យ៉ាងវិញទៀតភាគីខាងកូនសុំធម្មតាក៏អាចដាក់ពាក្យបណ្តឹងទាមទារកាត់កាល់សុំកូនធម្មតាបានដែរ។

ប៉ុន្តែបើកូនសុំនៅជាអនីតិជននៅឡើយ អ្នកដែលនឹងក្លាយជាអ្នកតំណាងតាមច្បាប់កំណត់របស់កូនសុំគឺជាអ្នកដាក់ពាក្យបណ្តឹងទាមទារឱ្យតុលាការកាត់កាល់សុំកូនធម្មតានេះបាន។ ជាងនេះទៅទៀត បើកូនសុំបានដល់អាយុ ១៥ឆ្នាំ ហើយគឺចាំបាច់ត្រូវតែមានការយល់ព្រមពីអនីតិជនបន្ថែមទៀត។

សរុបសេចក្តីមក ក្នុងអត្ថន័យដើម្បីការពារផលប្រយោជន៍របស់អនីតិជនមាត្រា១០៣១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណីបានធ្វើការហាមឃាត់ ការដាក់ពាក្យបណ្តឹងទាមទារការកាត់កាល់សុំកូនធម្មតាពីសំណាក់ឪពុកម្តាយចិញ្ចឹម ប្រសិនបើកូនសុំជាអនីតិជននៅឡើយ។

**កថាភាគទី ២. មូលហេតុ និងការវិនិច្ឆ័យនៃការកាត់កាល់សុំកូនធម្មតា**

ការកាត់កាល់សុំកូនធម្មតាអាចធ្វើបានយ៉ាងងាយស្រួល កាលបើភាគីទាំងសងខាងមានបំណងពិតប្រាកដមែន ក្នុងការរំលាយទំនាក់ទំនងរវាងឪពុកម្តាយនឹងកូន ដែលតុលាការអាចសម្រេចឱ្យកាត់កាល់។ [60] លើសពីនេះទៅទៀតបុគ្គលដែលអាចដាក់ពាក្យបណ្តឹងទាមទារឱ្យកាត់កាល់បាន លុះត្រាតែភាគីម្ខាងទៀតបានប្រព្រឹត្តដូចទៅនឹងបញ្ញត្តិនៃមាត្រា១០៣១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ដែលចែងពីមូលហេតុនៃការកាត់កាល់សុំកូនធម្មតានេះ ដោយមូលហេតុទាំងនោះមានដូចជា ៖

- ត្រូវបានបោះបង់ដោយភាគីម្ខាងទៀត ដោយគំនិតទុច្ចរិត
- មិនច្បាស់លាស់ ក្នុងអំឡុងពេលយ៉ាងតិច ១( មួយ )ឆ្នាំ ថាភាគីម្ខាងទៀតនៅរស់ ឬទទួលមរណភាព
- មានហេតុធ្ងន់ធ្ងរផ្សេងទៀត ដែលបណ្តាលឱ្យមានការពិបាកក្នុងការបន្តសុំកូន។

**កថាភាគទី ៣. ពាក្យសុំឱ្យកាត់កាល់សុំកូនធម្មតា**

ភាគីនៃសុំកូន អាចដាក់ពាក្យសុំទៅតុលាការឱ្យកាត់កាល់សុំកូនធម្មតាបាន ក្នុងករណីដែលភាគីទាំងសងខាងព្រមព្រៀងអំពីការកាត់កាល់នេះ។ បើក្នុងករណីដែលកូនសុំជាអនីតិជននោះ ពាក្យសុំកាត់កាល់ត្រូវធ្វើឡើងដោយមានការព្រមព្រៀងគ្នានោះ ត្រូវធ្វើឡើងដោយឪពុកម្តាយចិញ្ចឹម និងបុគ្គលដែលត្រូវក្លាយជាអ្នកតំណាងដែលច្បាប់បានកំណត់ ក្រោយពេលកាត់កាល់។ ប៉ុន្តែបើកូនសុំដល់អាយុ ១៥( ដប់ប្រាំ )ឆ្នាំ ហើយត្រូវទទួលបានការយល់ព្រមពីកូនសុំនោះ។ ទោះបីជាអនីតិជនមិនទាន់ដល់អាយុ ១៥ឆ្នាំ ក៏ដោយបើកូនសុំនោះមានឆន្ទៈរបស់ខ្លួនតុលាការត្រូវសួរយោបល់របស់កូនសុំនោះជាមុនសិន។ [61]

**កថាភាគទី ៤. អានុភាពនៃការកាត់កាល់សុំកូនធម្មតា**

ក្នុងករណីដែលបានកាត់កាល់ដោយការព្រមព្រៀង ឬបានកាត់កាល់តាមផ្លូវតុលាការ អានុភាពទាំងឡាយនៃសុំកូនធម្មតា ត្រូវបានបញ្ចប់ឆ្ពោះទៅពេលអនាគត ដោយការកាត់កាល់ នោះក្រោយការកាត់កាល់កូនសុំអាចទទួលបានវិញនូវនាមត្រកូលមុនសុំកូនក៏បាន ឬអាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹមក៏បាន។ [62]

[60] មើលមាត្រា១០៣០ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[61] មើលមាត្រា១០២៨.១.២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

[62] មាត្រា១០៣២.២ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។

# សេចក្ដីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវប្រធានបទ « ស្មុំកូននៅព្រះរាជាណាចក្រកម្ពុជា » រួចមក យើងសង្កេតឃើញថា វាពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ សិស្សនិស្សិតក៏ដូចជា ប្រជាពលរដ្ឋខ្មែរគ្រប់រូបដែលគួរតែយល់ដឹងពីបញ្ហានេះ។ នៅក្នុងច្បាប់ស្ដីពីអាពាហ៍ និងគ្រួសារបានឱ្យនិយមន័យពាក្យថា « ការស្មុំកូន » នេះថា ជាកិច្ចសន្យាដែលចងបុគ្គល ២(ពីរ)នាក់ គឺម្នាក់ហៅថា ឪពុកចិញ្ចឹម ឬម្ដាយចិញ្ចឹម ហើយម្នាក់ទៀតហៅថាកូនចិញ្ចឹមឱ្យមានចំណងនឹងគ្នាដូចជាបុត្តភាពមានខាន់ស្លា។ មួយវិញទៀត នៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ បានបញ្ញត្តិទាក់ទងនឹងប្រភេទនៃការស្មុំកូន គឺមានពីរប្រភេទ នោះគឺស្មុំកូនពេញលេញ និងស្មុំកូនធម្មតា។ ស្មុំកូនពេញលេញ គឺជាការសុំអនីតិជនដែលមានអាយុក្រោម ៨(ប្រាំបី)ឆ្នាំ យកមកធ្វើជាកូនសុំដោយបញ្ចប់ញាតិភាព រវាងញាតិលោហិតនៃឪពុកម្ដាយបង្កើត ហើយការសុំនេះត្រូវសម្រេចដោយតុលាការ។ ចំណែកឯ ស្មុំកូនធម្មតា ជាការសុំកូនដែលកូននោះអាចជាអនីតិជន ឬនីតិជន ដោយមិនតម្រូវឱ្យកាត់ផ្ដាច់ញាតិភាពពីឪពុកម្ដាយបង្កើត ហើយការសុំនេះត្រូវសម្រេចដោយតុលាការដែរ។ ចំពោះស្មុំកូនពេញលេញ និងស្មុំកូនធម្មតា គឺច្បាប់តម្រូវឱ្យភាគីទាំងពីរនៃស្មុំកូនគោរពតាមលក្ខខណ្ឌមួយចំនួន។ ក្រោយពីដាក់ពាក្យសុំបង្កើតការស្មុំកូនរួចរាល់ហើយ បើតុលាការចេញសេចក្ដីសម្រេចអនុញ្ញាតឱ្យបង្កើតការស្មុំកូននោះ ការស្មុំកូននឹងបង្កើតអានុភាពគតិយុត្តឡើង។ អានុភាពចំពោះការស្មុំកូនពេញលេញ បានបង្កើតញាតិភាពថ្មីមួយរវាងកូនសុំ និងឪពុកម្ដាយចិញ្ចឹម ដែលកូនសុំនោះនឹងក្លាយជាកូនពេញសិទ្ធិរបស់ឪពុកម្ដាយចិញ្ចឹម។ មួយវិញទៀត គឺមានអានុភាពកាត់ផ្ដាច់ទំនាក់ទំនងញាតិរវាងកូនសុំ និងឪពុកម្ដាយបង្កើតរួមទាំងញាតិលោហិតរបស់ឪពុកម្ដាយបង្កើតដែរ។ ចំណែកអានុភាពនៃការស្មុំកូនធម្មតាវិញ គឺបង្កើតញាតិភាពថ្មីរវាងកូនសុំ និងឪពុកម្ដាយចិញ្ចឹមដូចគ្នា ប៉ុន្តែវាមិនមានអានុភាពកាត់ផ្ដាច់ទំនាក់ទំនងញាតិរវាងកូនសុំ និងឪពុកម្ដាយបង្កើតនោះទេ ពោលគឺកូនបង្កើត និងឪពុកម្ដាយបង្កើត រួមទាំងញាតិលោហិតទាំងអស់នៅតែអាចបន្តរហូតបាន។ ចំពោះសិទ្ធិរបស់កូនសុំយោងតាមស្មារតីនៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើនៅ ឆ្នាំ២០០៧ បន្ទាប់ពីការស្មុំកូនមានអានុភាពគតិយុត្តហើយនោះ កូនសុំត្រូវទទួលបានសិទ្ធិដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្ដាយចិញ្ចឹមនោះដែរ។ ប៉ុន្តែបើក្រឡេកទៅមើលសិទ្ធិរបស់កូនសុំវិញ សិទ្ធិរបស់កូនសុំពេញលេញ និងកូនសុំធម្មតាធម្មតាវាមិនមានលក្ខណៈខុសគ្នាទាំងស្រុងនោះទេ តែអាចនិយាយបានថាកូនសុំធម្មតាអាចទទួលបានអត្ថប្រយោជន៍បានច្រើនជាងកូនសុំពេញលេញ។ ជាចុងក្រោយ នៅពេលដែលច្បាប់អនុញ្ញាតឱ្យមានការបង្កើតស្មុំកូននោះច្បាប់ក៏អនុញ្ញាតឱ្យមានការកាត់កាល់ស្មុំកូនដូចគ្នាដែរ គ្រាន់តែគេតម្រូវឱ្យភាគីដែលមានសិទ្ធិក្នុងការកាត់កាល់បំពេញលក្ខខណ្ឌសំខាន់ៗមួយចំនួន និងត្រូវដាក់ពាក្យសុំកាត់កាល់ស្មុំកូនដូចគ្នានឹងពេលបង្កើតស្មុំកូនដែរ។ ចំពោះស្មុំកូនពេញលេញ ជនដែលអាចមានសិទ្ធិដាក់ពាក្យសុំកាត់កាល់ទៅតុលាការបាន មានដូចជា កូនសុំ ឪពុកម្ដា

យបង្កើត និងតំណាងអយ្យការ។ ដោយឡែក ការកាត់កាល់សុំកូនធម្មតាវិញ មានភាពស្មុគស្មាញបន្តិច ដោយការកាត់កាល់សុំកូនធម្មតាត្រូវបានចែកចេញជាពីរបែបធំៗ គឺការកាត់កាល់ដោយការព្រមព្រៀងគ្នា និងការកាត់កាល់តាមមូលហេតុដែលច្បាប់កំណត់។ ក្នុងករណីដែលគេធ្វើការកាត់កាល់ដោយការព្រមព្រៀងគ្នានោះភាគីទាំងសងខាងនៃសុំកូន សុទ្ធតែមានសិទ្ធិក្នុងការដាក់ពាក្យសុំកាត់កាល់ទៅតុលាការ ដោយគ្រាន់តែបញ្ជាក់ថាវាជាការព្រមព្រៀងគ្នាក្នុងការកាត់កាល់សុំកូននោះពិតមែន ប៉ុន្តែបើភាគីកូនសុំជាអនីតិជន នោះអ្នកតំណាងដែលច្បាប់បានកំណត់សម្រាប់អនីតិជន ជាអ្នកដាក់ពាក្យសុំជំនួសកូនសុំនោះ។ ផ្ទុយទៅវិញ បើការកាត់កាល់នោះមិនធ្វើតាមការព្រមព្រៀងគ្នាទេ មុននឹងគេអាចធ្វើការកាត់កាល់បាន គេត្រូវតែមានមូលហេតុដូចដែលច្បាប់បានកំណត់ ទើបតុលាការអាចធ្វើការសម្រេចឱ្យកាត់កាល់កូនសុំធម្មតាបាន។

សរុបសេចក្តីមក ការបង្កើតសុំកូននៅព្រះរាជាណាចក្រកម្ពុជា មានពីរគឺ សុំកូនពេញលេញ និងសុំកូនធម្មតា។ ទោះជាគេចង់បង្កើតការសុំកូនមួយណាក៏ដោយក៏ត្រូវធ្វើតាមនីតិវិធីដែលច្បាប់បានកំណត់ ទើបអាចមានអានុភាពគតិយុត្ត និងបញ្ជាក់ថាអ្នកចង់បង្កើតសុំកូនដោយគោលបំណងសុចរិត។ ការធ្វើបែបនេះ អាចធានាបានថាកុមារដែលនឹងក្លាយជាកូនសុំអាចទទួលបានផលប្រយោជន៍ដែលខ្លួនត្រូវទទួលបាន និងដើម្បីការពារសិទ្ធិកូនសុំនោះផងដែរ។

# អនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវសារណាក្រោមប្រធានបទ « ស្មុំកូននៅព្រះរាជាណាចក្រកម្ពុជា » ទាំងមូលរួចមក ក្នុងនាមយើងខ្ញុំជានិស្សិតផ្នែកនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងជាប្រជាពលរដ្ឋកម្ពុជា យើងខ្ញុំសូមផ្តល់អនុសាសន៍ខ្លះៗ ក្នុងគោលបំណងចង់ឱ្យសិស្សនិស្សិត ព្រមទាំងប្រជាពលរដ្ឋទាំងអស់បានយល់ដឹងបន្ថែមពីច្បាប់ និងនីតិវិធីនៃការស្មុំកូនដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ជាពិសេសការស្មុំកូនដែលធ្វើទៅតាមវិធានច្បាប់។ ដោយសង្កេតឃើញថា បញ្ហាស្មុំកូននៅប្រទេសកម្ពុជានៅតែជាបញ្ហាចោទយ៉ាងធ្ងន់ធ្ងរដែលឈានទៅដល់ការបង្កើតឱ្យមាន ការកាត់កាល់រវាងកូនសុំជាមួយឪពុកម្តាយចិញ្ចឹម។

ទន្ទឹមនឹងនេះក្រសួងស្ថាប័ន និងអាជ្ញាធរដែលពាក់ព័ន្ធទាំងអស់ គួរគប្បីចាត់វិធានការផ្សព្វផ្សាយ ក៏ដូចជាចែករំលែកនូវរាល់ការយល់ដឹងអំពីវិធានច្បាប់នានាឱ្យបានទូលំទូលាយនៅតាមមូលដ្ឋានជនបទដូចជា គួរតែបញ្ចូលច្បាប់សំខាន់ៗនានា ក្នុងកម្មវិធីសិក្សា ដើម្បីឱ្យប្អូនៗជាសិស្សបានយល់។ មិនតែប៉ុណ្ណោះអាជ្ញាធរគួរផ្សព្វផ្សាយតាមបណ្តាញសង្គម ឬតាមរយៈទូរទស្សន៍ វិទ្យុ កាសែតព្រមទាំងជម្រុញឱ្យមានការពន្យល់ និងបកស្រាយឱ្យបានច្បាស់លាស់ពីបញ្ហាស្មុំកូន។ ម្យ៉ាងវិញទៀត អាជ្ញាធរមានសមត្ថកិច្ច គួរខិតខំស្វែងរកដំណោះស្រាយ ដើម្បីបញ្ឈប់ការជួញដូរកុមារ ការកេងប្រវ័ញ្ចផលប្រយោជន៍កុមារតាមរយៈរូបភាពនៃការស្មុំកូន ដើម្បីឱ្យប្រជាជនយើងឱ្យបានយល់ដឹងពីការស្មុំកូនដែលមានលក្ខណៈត្រឹមត្រូវ តាមវិធានច្បាប់របស់ប្រទេសកម្ពុជាក្នុងគោលបំណងប្រកាន់ខ្ជាប់ការគោរព និងការការពារឧត្តមប្រយោជន៍របស់កុមារ។

ជាចុងក្រោយនេះ ប្រជាពលរដ្ឋទាំងអស់គ្នា គួរគប្បីនាំគ្នាគោរពនូវច្បាប់ដែលមានចែងនៅក្នុងច្បាប់នានានៃព្រះរាជាណាចក្រកម្ពុជា និងជួយការពារផលប្រយោជន៍ និងសិទ្ធិកុមារ ជៀសវាងការប្រើអំពើហិង្សា ឬទារុណកម្ម ឬបង្កើតការស្មុំកូនក្នុងគោលបំណងទុច្ចរិតនាពេលអនាគត។

# ឯកសារយោង


## ១. លិខិតបទដ្ឋានគតិយុត្ត

### ១.១. រដ្ឋធម្មនុញ្ញ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

### ១.២. ក្រម

- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦

### ១.៣. ច្បាប់

- ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០ ដែលព្រះរាជប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៦១០/០០៨ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១០
- ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១០/០១៣ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១០

## ២. ឯកសារផ្សេងទៀត

- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ៥ : គន្ថីទី ៧ ឆ្នាំ២០១០
- សេចក្តីពន្យល់មាត្រានីមួយៗក្រមរដ្ឋប្បវេណី គន្ថី៧
- សៀវភៅក្រមរដ្ឋប្បវេណី ភាគ៦ ឆ្នាំ២០១២
- សៀវភៅមេរៀនស្តីពី ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ២ រៀបរៀងដោយគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងតុលាការ ក្រសួងយុត្តិធម៌ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំ២០១៦
- សៀវភៅមេរៀនសង្ខេប នីតិរដ្ឋប្បវេណី របស់សាស្ត្រចារ្យ មេធាវី អ៊ីវ ប៉ូលី ឆ្នាំ២០១១

- សៀវភៅ ការស្មុំកូន របស់លោកខន សុខេង
- សៀវភៅជំនួយស្មារតី នីតិព្រហ្មទណ្ឌ និងគ្រួសារ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១៧
- វចានានុក្រមរបស់សម្តចសង្ឃរាជ ជួន ណាត
- សន្ទានុក្រមផ្នែក រដ្ឋប្បវេណី

# ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូង** ......

**ដីកាសម្រេចលេខ:** ...............

ថ្ងៃទី ...... ខែ...... ឆ្នាំ ......

# ដីកាសម្រេចបង្កើតសុំកូនពេញលេញ

យើង .................................. ចៅក្រមនៃសាលាដំបូង .................។

-បានឃើញ មាត្រា ៣ និងមាត្រាពាក់ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹងដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១០/០១៣ ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០១០។

-បានឃើញ មាត្រា ១០០៧ និងមាត្រាពាក់ព័ន្ធនៃក្រមរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧ ។

-បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ....... ចុះថ្ងៃទី ...... ខែ ...... ឆ្នាំ ....... ។

**អ្នកដាក់ពាក្យសុំ ៖**

១. ឈ្មោះ .................. ភេទ....... អាយុ ....... សញ្ជាតិ ....... មុខរបរ ....... មានទីលំនៅផ្ទះលេខ ......... ផ្លូវលេខ ......... សង្កាត់ ........ ខណ្ឌ ....... ខេត្ត/រាជធានី ឪពុកឈ្មោះ ............ ម្តាយឈ្មោះ ............. ។

២. ឈ្មោះ .................. ភេទ....... អាយុ ....... សញ្ជាតិ ....... មុខរបរ ....... មានទីលំនៅផ្ទះលេខ ......... ផ្លូវលេខ ......... សង្កាត់ ........ ខណ្ឌ ....... ខេត្ត/រាជធានី ឪពុកឈ្មោះ ............ ម្តាយឈ្មោះ ............. ។

**ឪពុកម្តាយបង្កើត ៖**

១. ឈ្មោះ .................. ភេទ....... អាយុ ....... សញ្ជាតិ ....... មុខរបរ ....... មានទីលំនៅផ្ទះលេខ ......... ផ្លូវលេខ ......... សង្កាត់ ........ ខណ្ឌ ....... ខេត្ត/រាជធានី ឪពុកឈ្មោះ ............ ម្តាយឈ្មោះ ............. ។

២. ឈ្មោះ .................. ភេទ....... អាយុ ....... សញ្ជាតិ ....... មុខរបរ ....... មានទីលំនៅផ្ទះលេខ ......... ផ្លូវលេខ ......... សង្កាត់ ........ ខណ្ឌ ....... ខេត្ត/រាជធានី ឪពុកឈ្មោះ ............ ម្តាយឈ្មោះ ............. ។

**កូនឈ្មោះ ៖** ................. ភេទ....... អាយុ ....... សញ្ជាតិ ....... មុខរបរ ....... មានទីលំនៅផ្ទះលេខ ......... ផ្លូវលេខ ......... សង្កាត់ ........ ខណ្ឌ ....... ខេត្ត/រាជធានី ឪពុកឈ្មោះ ............ ម្តាយឈ្មោះ ............. ។

**ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ ៖** បង្កើតសុំកូនពេញលេញរវាងឈ្មោះ **ក.** ភេទ ... កើតថ្ងៃទី.... ខែ ..... ឆ្នាំ ....... ឈ្មោះ **ខ.** ភេទ ... កើតថ្ងៃទី ... ខែ ... ឆ្នាំ ... ដែលមានឋានៈជាឪពុកម្តាយចិញ្ចឹម និង ឈ្មោះ **គ.** ភេទ ... កើតថ្ងៃទី....... ខែ ....... ឆ្នាំ ......... ដែលមានឋានៈជាកូនសុំ។

## សំអាងហេតុ

យោងតាមលទ្ធផលនៃការសាកសួរសាមីភាគី និង ពិនិត្យភស្តុតាងដែលមាននៅក្នុងសំណុំរឿង ឃើញថា ៖

១. អ្នកដាក់ពាក្យសុំឈ្មោះ **ក.** ភេទប្រុស កើតនៅថ្ងៃទី .... ខែ ..... ឆ្នាំ......... ដោយមានសំបុត្រកំណើតលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ជាប្តី និង ឈ្មោះ **ខ.** ភេទស្រី កើតថ្ងៃទី ... ខែ ... ឆ្នាំ ... គឺជាសហព័ទ្ធនឹងគ្នា ដោយមានសំបុត្រអាពាហ៍ពិពាហ៍លេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ។ ឈ្មោះ **គ.** ភេទ ... កើតនៅថ្ងៃទី ... ខែ ... ឆ្នាំ .... ដោយមានសំបុត្រកំណើតលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ...។ អ្នកដាក់ពាក្យសុំឈ្មោះ **ក.** មានអាយុ ... និង ឈ្មោះ **ខ.** មានអាយុ ... ពោលគឺមានអាយុលើសឈ្មោះ **គ.** លើសពី ២០ ឆ្នាំ។ ដូច្នេះ អ្នកដាក់ពាក្យសុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដើម្បីបង្កើតសុំកូនពេញលេញ តាមមាត្រា ១០០៨ មាត្រា ១០០៩ និង មាត្រា ១០១០ នៃក្រមរដ្ឋប្បវេណី។

២. ឈ្មោះ **ង.** និង ឈ្មោះ **ច.** ត្រូវជាឪពុកម្តាយបង្កើតរបស់ឈ្មោះ **គ.** បានយល់ព្រមឱ្យឈ្មោះ **គ.** ទៅឈ្មោះ **ក.** និង ឈ្មោះ **ខ.** ចិញ្ចឹមធ្វើជាកូនសុំពេញលេញ ដោយសារតែពួកខ្លួនមិនមានលទ្ធភាពសមរម្យក្នុងការចិញ្ចឹមបីបាច់ថែរក្សាឈ្មោះ **គ.**។

៣. បន្ទាប់ពីឈ្មោះ **ក.** និង ឈ្មោះ **ខ.** បានសាកល្បងចិញ្ចឹមឈ្មោះ **គ.** អស់រយៈពេល ... កន្លងមក ឃើញថា ឈ្មោះ **ក.** និង ឈ្មោះ **ខ.** បានរស់នៅចុះសម្រុងជាមួយនឹងឈ្មោះ **គ.**។

៤. មានស្ថានភាពគ្រប់គ្រាន់ដែលជាមូលដ្ឋានក្នុងការបង្កើតសុំកូនពេញលេញ សមស្របទៅតាមផលប្រយោជន៍កូន។

៥. យោងតាមមាត្រា ២២ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ប្រាក់ប្រដាប់ក្តីគឺជាបន្ទុករបស់អ្នកដាក់ពាក្យសុំ។

## សេចក្តីសម្រេចបញ្ចប់

១. បង្កើតសុំកូនពេញលេញ រវាងឈ្មោះ ក. ភេទ ... កើតថ្ងៃទី.... ខែ ..... ឆ្នាំ ...... ឈ្មោះ ខ. ភេទ ... កើតថ្ងៃទី ... ខែ ... ឆ្នាំ ... ដែលមានឋានៈជាឪពុកម្តាយចិញ្ចឹម និង ឈ្មោះ គ. ភេទ ... កើតថ្ងៃទី....... ខែ ........ ឆ្នាំ ......... ដែលមានឋានៈជាកូនសុំ។

២. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់អ្នកដាក់ពាក្យសុំ។

**ចៅក្រម**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូង ......**

**ដីកាសម្រេចលេខ:** ..............
ថ្ងៃទី...... ខែ...... ឆ្នាំ......

# ដីកាសម្រេចបង្កើតសុំកូនធម៌តា

យើង ................................. ចៅក្រមនៃសាលាដំបូង ..................។

-បានឃើញ មាត្រា ៣ និងមាត្រាពាក់ព័ន្ធនៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹងដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១០/ ០១៣ ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០១០។

-បានឃើញ មាត្រា ១០២០ និងមាត្រាពាក់ព័ន្ធនៃក្រមរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧ ។

-បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ....... ចុះថ្ងៃទី ...... ខែ ...... ឆ្នាំ ....... ។

**អ្នកដាក់ពាក្យសុំ ៖**

១. ឈ្មោះ ................. ភេទ....... អាយុ ....... សញ្ជាតិ ....... មុខរបរ ....... មានទីលំនៅផ្ទះលេខ ......... ផ្លូវលេខ ......... សង្កាត់ ........ ខណ្ឌ ....... ខេត្ត/រាជធានី ឪពុកឈ្មោះ ........... ម្តាយឈ្មោះ ............. ។

២. ឈ្មោះ ................. ភេទ....... អាយុ ....... សញ្ជាតិ ....... មុខរបរ ....... មានទីលំនៅផ្ទះលេខ ......... ផ្លូវលេខ ......... សង្កាត់ ........ ខណ្ឌ ....... ខេត្ត/រាជធានី ឪពុកឈ្មោះ ........... ម្តាយឈ្មោះ ............. ។

**ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារ ៖** បង្កើតសុំកូនធម៌តារវាងឈ្មោះ **ក.** ភេទ ...... កើតថ្ងៃទី.... ខែ ..... ឆ្នាំ ........ ដែលមានឋានៈជាម្តាយចិញ្ចឹម និង ឈ្មោះ **ខ.** ភេទ ... កើតថ្ងៃទី........ ខែ ........ ឆ្នាំ ......... ដែលមានឋានៈជាកូនសុំ។

## សំអាងហេតុ

យោងតាមលទ្ធផលនៃការសាកសួរសាមីភាគី និង ពិនិត្យភស្តុតាងដែលមាននៅក្នុងសំណុំរឿង ឃើញថា ៖

១. អ្នកដាក់ពាក្យសុំឈ្មោះ **ក.** ជាស្ត្រីមេម៉ាយ កើតនៅថ្ងៃទី ... ខែ ..... ឆ្នាំ......... ដោយមានសំបុត្រកំណើតលេខ .... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ពោលគឺមានអាយុ ..... បានព្រមព្រៀងបង្កើតសុំកូនធម៌តា ជាមួយនឹងឈ្មោះ **ខ.** នៅ លីវ ដែលកើតនៅថ្ងៃទី .... ខែ ... ឆ្នាំ .... ដោយមានសំបុត្រកំណើតលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ...។ អ្នកដាក់ពាក្យសុំឈ្មោះ **ខ.** មានអាយុតិចជាងអ្នកដាក់ពាក្យសុំឈ្មោះ **ក.** ហើយក៏មិនមែនជាបុព្វញាតិរបស់អ្នកដាក់ពាក្យសុំឈ្មោះ **ក.** ដែរ។

២. អ្នកដាក់ពាក្យសុំឈ្មោះ **ក.** និង អ្នកដាក់ពាក្យសុំឈ្មោះ **ខ.** មានឆន្ទៈពិតប្រាកដក្នុងការបង្កើតទំនាក់ទំនងជាម្ដាយ និងកូន។

៣. អ្នកដាក់ពាក្យសុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីបង្កើតសុំកូនធម៌តាបាន តាមមាត្រា ១០២០ នៃក្រមរដ្ឋប្បវេណី។

៤. យោងតាមមាត្រា ២២ នៃច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង ប្រាក់ប្រដាប់ក្ដីគឺជាបន្ទុករបស់អ្នកដាក់ពាក្យសុំ។

## សេចក្ដីសម្រេចបញ្ចប់

១. បង្កើតសុំកូនធម៌តា រវាងឈ្មោះ ក. ភេទ ... កើតថ្ងៃទី.... ខែ ..... ឆ្នាំ ........ ដែលមានឋានៈជាម្ដាយចិញ្ចឹម និង ឈ្មោះ ខ. ភេទ ... កើតថ្ងៃទី........ ខែ ........ ឆ្នាំ .......... ដែលមានឋានៈជាកូនសុំ។

២. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់អ្នកដាក់ពាក្យសុំ។

**ចៅក្រម**

# ច្បាប់
# ស្តីពី
# នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង



# ព្រះរាជក្រម

នស/រកម/០៧១០/០១៣

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៧ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

អ្នកតំណាងដោយផ្អែកលើការអនុញ្ញាតរបស់តុលាការដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ១៩ (លក្ខណសម្បត្តិនៃអ្នកតំណាងដោយអាណត្តិ) ខាងលើនេះ ។

**មាត្រា ២១.- ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីសិទ្ធិតំណាងដោយអាណត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី**

បញ្ញត្តិនៃមាត្រា ៥៥ (ករណីដែលសិទ្ធិតំណាងដោយអាណត្តិមិនរលត់) មាត្រា ៥៦ (ហេតុនៃការរលត់នូវសិទ្ធិតំណាងដោយអាណត្តិ) និង មាត្រា ៥៧ (វិធានការក្នុងករណីនៃការខ្វះសិទ្ធិតំណាង) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកតំណាងដោយអាណត្តិ ។

## ជំពូកទី ៤
## ប្រាក់ប្រដាប់ក្តី

**មាត្រា ២២.- បន្ទុកនៃប្រាក់ប្រដាប់ក្តី**

១- ដើម្បីដាក់ពាក្យសុំតាមនីតិវិធីនៃរឿងក្តីដែលកំណត់ក្នុងច្បាប់នេះ ត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀល ។

២- បញ្ញត្តិនៃមាត្រា ៦២ (ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ) និង មាត្រា ៦៣ (ប្រាក់ប្រដាប់ក្តីកាតី) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះប្រាក់ប្រដាប់ក្តីក្រៅពីពន្ធដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ។

៣- ប្រាក់ប្រដាប់ក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ
គឺជាបន្ទុករបស់អ្នកដាក់ពាក្យសុំ
លើកលែងតែក្នុងករណីដែលមានកំណត់ពិសេសអំពីអ្នកទទួលបន្ទុកនោះក្នុងច្បាប់នេះ ។

៤- ចំពោះរឿងក្តីដែលតំណាងអយ្យការបានដាក់ពាក្យសុំ ឬ រឿងក្តីដែលតុលាការបានចាប់ផ្តើមដោយឆន្ទានុសិទ្ធិរបស់ខ្លួន ប្រាក់ប្រដាប់ក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើនេះ ជាបន្ទុករបស់រដ្ឋ ។

៥- បញ្ញត្តិនៃកថាខណ្ឌទី ៣ មាត្រា ៦៤ (ភាគដែលត្រូវទទួលបន្ទុក និង ការសងវិញនូវប្រាក់ប្រដាប់ក្តីដែលបានបង់រួចហើយ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមានជនច្រើននាក់ដែលត្រូវទទួលបន្ទុកប្រាក់ប្រដាប់ក្តីដោយរួមគ្នា ។



៦- ក្នុងករណីដែលអ្នកដាក់ពាក្យសុំ ត្រូវបង់ពន្ធដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើអ្នកដាក់ពាក្យសុំមិនបានបង់ពន្ធនោះទេ តុលាការត្រូវកំណត់អំឡុងពេលសមរម្យ និង បង្គាប់ឱ្យបង់ពន្ធនោះ។ ក្នុងករណីនេះ ប្រសិនបើអ្នកដាក់ពាក្យសុំមិនបានបង់ពន្ធនោះទេ តុលាការត្រូវលើកលិខិតពាក្យសុំចោលដោយដីកាសម្រេច ។

៧- ចំពោះដីកាសម្រេចលើកចោលលិខិតពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ៦ ខាងលើនេះ អាចប្តឹងជំទាស់បាន ។

៨- ដើម្បីប្តឹងជំទាស់ ដោយយោងតាមបញ្ញត្តិនៃមាត្រា ៣៩ (បណ្តឹងជំទាស់) នៃច្បាប់នេះ ត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀល ។ បញ្ញត្តិនៃកថាខណ្ឌទី ៦ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នកដាក់ពាក្យបណ្តឹងជំទាស់មិនបានបង់ពន្ធនោះ ។

## មាត្រា ២៣.- ដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តី

១- ប្រសិនបើយល់ឃើញថាចាំបាច់សម្រេចអំពីអ្នកទទួលបន្ទុក ឬ ចំនួនទឹកប្រាក់នៃប្រាក់ប្រដាប់ក្តីដែលកំណត់ក្នុងមាត្រា ២២ (បន្ទុកនៃប្រាក់ប្រដាប់ក្តី) ខាងលើនេះ តុលាការត្រូវកំណត់ចំនួនទឹកប្រាក់នៃប្រាក់ប្រដាប់ក្តីនោះ និង ត្រូវចេញដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តីនោះ ព្រមជាមួយគ្នានឹងដីកាសម្រេចអំពីរឿងក្តីនោះ ។

២- ក្នុងករណីដែលមានស្ថានភាពពិសេស តុលាការអាចបង្គាប់ឱ្យជនពាក់ព័ន្ធដែលមិនមែនជាជនដែលត្រូវទទួលបន្ទុកនូវប្រាក់ប្រដាប់ក្តីតាមបញ្ញត្តិនៃច្បាប់នេះ ទទួលបន្ទុកនូវប្រាក់ប្រដាប់ក្តីទាំងស្រុង ឬ មួយភាគបាន ។

៣- ចំពោះដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តី មានតែជនដែលត្រូវបានបង្គាប់ឱ្យទទួលបន្ទុកប្រាក់ប្រដាប់ក្តីនេះទេ ដែលអាចប្តឹងជំទាស់បាន ប៉ុន្តែមិនអាចប្តឹងជំទាស់ដោយឯករាជ្យបានឡើយ ។

## មាត្រា ២៤.- ការអនុវត្តដោយបង្ខំអំពីប្រាក់ប្រដាប់ក្តី

១- ម្ចាស់បំណុលលើប្រាក់ប្រដាប់ក្តី អាចអនុវត្តដោយបង្ខំ ដោយផ្អែកលើដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តីបាន ។

២- បញ្ញត្តិនៃគន្ថីទី ៦ (ការអនុវត្តដោយបង្ខំ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការអនុវត្តដោយបង្ខំដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប៉ុន្តែមិនចាំបាច់ធ្វើការបញ្ជូនដីកាសម្រេចមុនពេលអនុវត្តទេ ។

៣- បញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៣០៥ (ការផ្អាកអានុភាពនៃដីកាសម្រេចដើម) នៃក្រមនីតិវិធីរដ្ឋប្បវេណីត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមានបណ្តឹងជំទាស់ ចំពោះដីកាសម្រេចអំពីប្រាក់ប្រដាប់ក្តី ។

### មាត្រា ២៥.– ការបង់ប្រាក់ប្រដាប់ក្តីជំនួសជាមុន

ចំពោះប្រាក់ប្រដាប់ក្តីសម្រាប់ការពិនិត្យភស្តុតាង ការកោះហៅ ការជូនដំណឹង និង ការចាត់ចែងចាំបាច់ផ្សេងទៀត ដែលធ្វើឡើងដោយឆន្ទានុសិទ្ធិរបស់តុលាការ រដ្ឋត្រូវបង់ជំនួសជាមុន ប៉ុន្តែចំពោះសកម្មភាពដែលត្រូវការប្រាក់ប្រដាប់ក្តី តុលាការអាចបង្គាប់ឲ្យជនពាក់ព័ន្ធបង់ប្រាក់ប្រដាប់ក្តីនោះជាមុនបាន ។

## ជំពូកទី ៥
## ការវិនិច្ឆ័យ

### មាត្រា ២៦.– របៀបដាក់ពាក្យសុំ និងចំណុចដែលត្រូវសរសេរក្នុងពាក្យសុំ

១- ពាក្យសុំអាចធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់បាន លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់នេះ ឬ ច្បាប់ផ្សេងទៀត ។

២- នៅក្នុងលិខិតនៃពាក្យសុំត្រូវសរសេរបញ្ជាក់នូវចំណុចខាងក្រោមនេះ ៖

ក- ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ ហើយនិងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ- ខ្លឹមសារនៃដីកាសម្រេច ឬ សកម្មភាពផ្សេងទៀតរបស់តុលាការដែលអ្នកដាក់ពាក្យសុំទាមទារ និងអង្គហេតុដែលជាមូលហេតុនៃការទាមទារនោះ ។

៣- ដើម្បីដាក់ពាក្យសុំដោយផ្ទាល់មាត់ អ្នកដាក់ពាក្យសុំត្រូវធ្វើសេចក្តីថ្លែងការណ៍នូវចំណុចនីមួយៗ ដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ នៅចំពោះមុខក្រឡាបញ្ជី ។ ក្នុងករណីនេះ ក្រឡាបញ្ជីត្រូវធ្វើកំណត់ហេតុ និង ចុះហត្ថលេខា ។ កំណត់ហេតុនោះត្រូវបានចាត់ទុកជាលិខិតពាក្យសុំ ។

៤- ក្នុងករណីដែលមានឯកសារជាភស្តុតាង អ្នកដាក់ពាក្យសុំត្រូវភ្ជាប់នូវឯកសារដើម ឬ ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ជាមួយនឹងលិខិតនៃពាក្យសុំ ឬ ត្រូវដាក់ជូនឯកសារទាំងនោះទៅតុលាការនៅពេលដាក់ពាក្យសុំ ។

## មាត្រា ២៧.- ការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ និង ការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ

១- តុលាការអាចយកអង្គហេតុដែលមិនបានអះអាងដោយអ្នកដាក់ពាក្យសុំ ឬ ដោយភាគីម្ខាងទៀតមកធ្វើជាមូលដ្ឋាននៃដីកាសម្រេចបាន ។

២- ប្រសិនបើយល់ឃើញថាចាំបាច់ តុលាការត្រូវធ្វើការស្រាវជ្រាវអង្គហេតុ និង ធ្វើការពិនិត្យភស្តុតាងដោយឆន្ទានុសិទ្ធិ ។

## មាត្រា ២៨.- ការទាញហេតុផលដោយផ្ទាល់មាត់ និងការសួរដោយឆន្ទានុសិទ្ធិ

១- ដើម្បីចេញដីកាសម្រេចអំពីរឿងក្តីដែលកំណត់ក្នុងកថាខណ្ឌទី ១ នៃមាត្រា ៣ (វិសាលភាពនៃច្បាប់នេះ) នៃច្បាប់នេះ តុលាការពុំចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ឡើយ ។

២- ក្នុងករណីដែលមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាចសួរអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬ ជនផ្សេងទៀតដែលតុលាការយល់ឃើញថាចាំបាច់បាន ។ ក្នុងករណីនេះ តុលាការអាចអនុញ្ញាតឲ្យអ្នកដែលតុលាការយល់ថាសមរម្យ ចូលស្តាប់ជាអ្នកសង្កេតការណ៍បាន ។

## មាត្រា ២៩.-ករណីយកិច្ចបង្ហាញខ្លួនរបស់សាមីខ្លួន

១- តុលាការអាចកោះហៅអ្នកដាក់ពាក្យសុំ ភាគីម្ខាងទៀត ឬ ជនផ្សេងទៀត ដែលតុលាការយល់ឃើញថាចាំបាច់បាន ដោយកំណត់កាលបរិច្ឆេទ ។

២-ក្នុងករណីជនដែលត្រូវបានកោះហៅដោយតុលាការ ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនបានបង្ហាញខ្លួនមកតុលាការដោយគ្មានមូលហេតុត្រឹមត្រូវទេ តុលាការអាចពិន័យជាប្រាក់ចំនួនមិនលើសពី ១.០០០.០០០ (មួយលាន) រៀល បាន ។

## មាត្រា ៣០.- ការចូលរួមរបស់តំណាងអយ្យការ និង ការជូនដំណឹង

១- ប្រសិនបើយល់ឃើញថាចាំបាច់ត្រូវការពារផលប្រយោជន៍សាធារណៈ តុលាការត្រូវជូនដំណឹងទៅតំណាងអយ្យការអំពីរឿងក្តី និង កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ ក្នុងកាលបរិច្ឆេទនៃការសួរ ។

២- ប្រសិនបើយល់ឃើញថាចាំបាច់ការពារផលប្រយោជន៍សាធារណៈ តំណាងអយ្យការអាចបញ្ចេញមតិចំពោះរឿងក្តី និង ចូលរួមក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ ក្នុងកាលបរិច្ឆេទនៃការសួរបាន ។

៣- ក្នុងករណីដែលបានដឹងតាមមុខនាទីរបស់ខ្លួនថា ករណីដែលតំណាងអយ្យការអាចដាក់ពាក្យសុំ ឬ ទាមទារបានកើតឡើង តុលាការ ស្ថាប័នរដ្ឋផ្សេងទៀត និង មន្ត្រីស្ថាប័នទាំងនោះ និង តំណាងអយ្យការ ត្រូវជូនដំណឹងអំពីករណីនោះទៅតំណាងអយ្យការអមតុលាការដែលមានសមត្ថកិច្ច ។

## មាត្រា ៣១.- ការចូលរួមក្នុងនីតិវិធីរបស់ជនពាក់ព័ន្ធនឹងផលប្រយោជន៍

១- ប្រសិនបើយល់ឃើញថាសមរម្យ តុលាការអាចឲ្យជនក្រៅពីអ្នកដាក់ពាក្យសុំ ឬ ភាគីម្ខាងទៀត ក្នុងចំណោមជនពាក់ព័ន្ធដែលកំណត់ក្នុងមាត្រា ១៥ (ជនពាក់ព័ន្ធ) នៃច្បាប់នេះ ចូលរួមក្នុងនីតិវិធីបាន ។

២- ជនដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចចូលរួមក្នុងនីតិវិធីបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

## មាត្រា ៣២.- ការទទួលបន្តនូវនីតិវិធី

១- ក្នុងករណីដែលអ្នកដាក់ពាក្យសុំ ឬ ភាគីម្ខាងទៀត មិនអាចបន្តនីតិវិធីដោយសារមរណភាព ការបាត់បង់លក្ខណសម្បត្តិ ឬមូលហេតុផ្សេងទៀត ជនដែលមានលក្ខណសម្បត្តិក្នុងការដាក់ពាក្យសុំឲ្យដំណើរការនីតិវិធីនោះ តាមច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត អាចដាក់ពាក្យសុំទទួលបន្តនូវនីតិវិធីនោះបាន ។

២- ក្នុងករណីដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើយល់ឃើញថាចាំបាច់ តុលាការអាចបង្គាប់ឲ្យជនដែលមានលក្ខណសម្បត្តិក្នុងការដាក់ពាក្យសុំឲ្យដំណើរការនីតិវិធីនោះតាមច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ទទួលបន្តនូវនីតិវិធីនោះបាន ។

## មាត្រា ៣៣.- ការមើលសំណុំរឿង ជាអាទិ៍

១- ប្រសិនបើយល់ឃើញថាសមរម្យ តុលាការអាចអនុញ្ញាតឲ្យមើល ឬឲ្យថតចម្លងសំណុំរឿង ឬ អាចបង្គាប់ឲ្យក្រឡាបញ្ជីប្រគល់ឯកសារចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឯកសារដកស្រង់នៃសំណុំរឿង ឬ លិខិតបញ្ជាក់អំពីចំណុចទាក់ទងនឹងរឿងក្តីបាន តាមពាក្យសុំរបស់ជនពាក់ព័ន្ធនឹងរឿងក្តីនោះ ដោយឲ្យបង់សោហ៊ុយ ។

ROYAUME DU CAMBODGE MINISTÈRE DU PALAIS ROYAL

| ផ្នែក | ចំណុចដែលត្រូវសម្រេចសេចក្តី | តុលាការដែលមានសមត្ថកិច្ច |
|---|---|---|
| ៤ | ៨ ការទាមទារឱ្យបង្ហាញនូវសំណុំរឿងអំពីសុំកូនពេញលេញ ដោយយោងតាមបញ្ញត្តិនៃមាត្រា១០១៩ (សិទ្ធិដឹងអំពីកំណើតខ្លួនរបស់កូនសុំពេញលេញ) | តុលាការដែលរក្សាទុកនូវសំណុំរឿងអំពីសុំកូនពេញលេញ |
| | ៩ ពាក្យសុំឱ្យបង្កើតសុំកូនធម្មតា ដោយយោងតាមបញ្ញត្តិនៃមាត្រា១០២០ (ពាក្យសុំនៃសុំកូនធម្មតា) | តុលាការនៃលំនៅឋានរបស់អ្នកដែលនឹងក្លាយទៅជាកូនសុំ |
| | ១០ ពាក្យសុំឱ្យកាត់កាល់សុំកូនដោយការព្រមព្រៀង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១០២៨ (ពាក្យសុំឱ្យកាត់កាល់សុំកូនធម្មតា) | តុលាការនៃលំនៅឋានរបស់កូន |
| | ១១ ការកំណត់អ្នកមានអំណាចមេបា ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី៣ មាត្រា១០៣៨ (ទំនាក់ទំនងរវាងការទទួលស្គាល់ និងអំណាចមេបា) | តុលាការនៃលំនៅឋានរបស់កូន |
| | ១២ ការផ្លាស់ប្តូរអ្នកដែលមានអំណាចមេបា ដោយយោងតាមបញ្ញត្តិនៃមាត្រា១០៣៩ (ការផ្លាស់ប្តូរអ្នកដែលមានអំណាចមេបា) | តុលាការនៃលំនៅឋានរបស់កូន |
| | ១៣ ការសម្រេចសេចក្តីអំពីរបៀបចូលជួបនិងប្រាស្រ័យទាក់ទង និងចំណែកបន្ទុកនៃសោហ៊ុយចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី៤ និងកថាខណ្ឌទី៥ មាត្រា១០៤០ (សិទ្ធិ និងករណីយកិច្ចរបស់ឪពុកម្តាយដែលមិនរស់នៅជាមួយកូន) | តុលាការនៃលំនៅឋានរបស់កូន |
| | ១៤ ការសម្រេចសេចក្តីជំនួសការពិភាក្សា ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា១០៤១ (សិទ្ធិទាមទារឱ្យរាយការណ៍អំពីស្ថានភាពរបស់កូន) | តុលាការនៃលំនៅឋានរបស់អ្នកមានអំណាចមេបា |
| | ១៥ ការប្រកាសការព្យួរ ឬការដកហូតអំណាចមេបា ដោយយោងតាមបញ្ញត្តិនៃមាត្រា១០៤៨ (ការប្រកាសការព្យួរ ឬការដកហូតអំណាចមេបា) | តុលាការនៃលំនៅឋានរបស់អ្នកមានអំណាចមេបា |
| | ១៦ ការលុបចោលនូវការប្រកាសការព្យួរ ឬការដកហូតអំណាចមេបា ដោយយោងតាមបញ្ញត្តិនៃមាត្រា១០៤៩ (ការលុបចោលនូវការប្រកាសការព្យួរ ឬការដកហូតអំណាចមេបា) | តុលាការនៃលំនៅឋានរបស់អ្នកដែលបានទទួលការប្រកាសការព្យួរ ឬការដកហូតអំណាចមេបា |
| | ១៧ ការអនុញ្ញាតឱ្យលាឈប់ពីអ្នកមានអំណាចមេបា ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ មាត្រា១០៥០ (ការលាឈប់ និងបដិទានរបស់អ្នកមានអំណាចមេបា) | តុលាការនៃលំនៅឋានរបស់អ្នកដាក់ពាក្យសុំការអនុញ្ញាតឱ្យលាឈប់ពីអ្នកមានអំណាចមេបា |
| | ១៨ ការអនុញ្ញាតឱ្យទទួលបដិទាននូវអំណាចមេបា ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី២ មាត្រា១០៥០ (ការលាឈប់ និងបដិទានរបស់អ្នកមានអំណាចមេបា) | តុលាការនៃលំនៅឋានរបស់អ្នកដាក់ពាក្យសុំការអនុញ្ញាតឱ្យទទួលបដិទាននូវអំណាចមេបា |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# នីតិវិធីបណ្តឹងទាក់ទង
# នឹងឋានៈបុគ្គល

# ព្រះរាជក្រម

នស/រកម/០៦១០/០០៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

លេខ ...៣៧២០...
ថ្ងៃទី...០៧/០៦ ឆ្នាំ២០១០ ម៉ោង...
បញ្ជូនទៅ...

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៧ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

ROYAUME DU CAMBODGE
LE MINISTERE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–** គោលដៅនៃច្បាប់នេះ៖

ច្បាប់នេះ មានគោលដៅបញ្ញត្តនូវករណីពិសេសនៃក្រមនីតិវិធីរដ្ឋប្បវេណី ចំពោះនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ។

**មាត្រា ២.–** គោលបំណងនៃច្បាប់នេះ៖

ច្បាប់នេះ មានគោលបំណងធានាការអនុវត្តឱ្យបានត្រឹមត្រូវនូវនីតិវិធីក្នុងការដោះស្រាយបណ្តឹងទាក់ទងនឹងឋានៈបុគ្គល។

**មាត្រា ៣.–** វិសាលភាពនៃច្បាប់នេះ៖

ច្បាប់នេះ មានវិសាលភាពអនុវត្តលើបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលរួមមានបណ្តឹងដូចខាងក្រោមនេះ ៖

ក- បណ្តឹងទាមទារឱ្យបញ្ជាក់អំពីមោឃភាពនៃអាពាហ៍ពិពាហ៍ តាមបញ្ញត្តិនៃមាត្រា ៩៥៨ (មោឃភាពនៃអាពាហ៍ពិពាហ៍) នៃក្រមរដ្ឋប្បវេណី ។

ខ- បណ្តឹងទាមទារលុបចោលអាពាហ៍ពិពាហ៍ តាមបញ្ញត្តិចាប់ពីមាត្រា ៩៥៩ (ការលុបចោលអាពាហ៍ពិពាហ៍) ដល់មាត្រា ៩៦៣ (ការលុបចោលអាពាហ៍ពិពាហ៍ ដោយការឆបោក ឬ ការគំរាម) នៃក្រមរដ្ឋប្បវេណី ។

គ- បណ្តឹងទាមទារលែងលះគ្នា តាមបញ្ញត្តិនៃមាត្រា ៩៧៨ (មូលហេតុនៃការលែងលះគ្នា) នៃក្រមរដ្ឋប្បវេណី ។

ឃ- បណ្តឹងបដិសេធបិតុភាព តាមបញ្ញត្តិនៃមាត្រា ៩៩០ (បណ្តឹងបដិសេធបិតុភាពពីជនដែលត្រូវបានសន្មតថាជាឪពុក) និងមាត្រា៩៩១ (បណ្តឹងបដិសេធបិតុភាពពីកូន) នៃក្រមរដ្ឋប្បវេណី ។

ង-បណ្តឹងទាមទារឱ្យទទួលស្គាល់ តាមបញ្ញត្តិនៃមាត្រា ១០០១ (បណ្តឹងទាមទារឱ្យទទួលស្គាល់) នៃក្រមរដ្ឋប្បវេណី ។

ច- បណ្តឹងដែលមានគោលបំណងបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព តាមបញ្ញត្តិនៃមាត្រា ១០០២ (បណ្តឹងទាមទារឱ្យបញ្ជាក់អំពីនត្ថិភាពនៃបុត្តភាព) នៃក្រមរដ្ឋប្បវេណី ។

ឆ- បណ្តឹងដែលមានគោលបំណងបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព តាមបញ្ញត្តិនៃមាត្រា ១០០៤ (បណ្តឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាពនៃមាតុភាពពីកូន) និង មាត្រា ១០០៥ (បណ្តឹងទាមទារឱ្យបញ្ជាក់

ROYAUME DU CAMBODGE * LE CABINET DU PALAIS ROYAL

អំពីអត្ថិភាពនៃមាតុភាពពីម្តាយ ) នៃក្រមរដ្ឋប្បវេណី ។

ជ- បណ្តឹងទាមទារកាត់កាល់ តាមបញ្ញត្តិនៃមាត្រា១០១៦ (ការកាត់កាល់នៃសុំកូនពេញលេញ) នៃក្រមរដ្ឋប្បវេណី ។

ឈ- បណ្តឹងទាមទារកាត់កាល់ តាមបញ្ញត្តិនៃមាត្រា ១០៣១ (មូលហេតុនៃការកាត់កាល់) នៃក្រមរដ្ឋប្បវេណី។

ញ- បណ្តឹងផ្សេងទៀតដែលមានគោលបំណងបង្កើត បញ្ជាក់អត្ថិភាព ឬ នត្ថិភាពនៃទំនាក់ទំនងនឹងឋានៈបុគ្គល។

## ជំពូកទី ២
## ការចូលរួមរបស់តំណាងអយ្យការ

**មាត្រា ៤._** ការអះអាងអង្គហេតុដោយតំណាងអយ្យការ ជាអាទិ៍

ចំពោះបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ក្នុងករណីដែលតំណាងអយ្យការបានចូលរួមក្នុងនីតិវិធីតាមបញ្ញត្តិនៃកថាខណ្ឌទី ២ មាត្រា ៦ (ការចូលរួមរបស់តំណាងអយ្យការ) នៃក្រមនីតិវិធីរដ្ឋប្បវេណី តំណាងអយ្យការនោះ អាចធ្វើការអះអាងអង្គហេតុ ឬ អាចស្នើសុំឱ្យពិនិត្យភស្តុតាងបាន ។

## ជំពូកទី ៣
## តុលាការ

**មាត្រា ៥._** សមត្ថកិច្ច

១- បណ្តឹងទាក់ទងនឹងឋានៈបុគ្គលត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់សាលាដំបូងដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់ភាគីនៃទំនាក់ទំនងនឹងឋានៈបុគ្គលពាក់ព័ន្ធនឹងបណ្តឹងនោះ ឬ លំនៅឋាននៅពេលដែលភាគីនោះទទួលមរណភាព ។

២- បើលំនៅឋានដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ពុំស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ លំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាមិនពិតប្រាកដទេ សមត្ថកិច្ចសាលាជម្រះក្តីត្រូវកំណត់តាមទីសំណាក់ ។ បើពុំមានទីសំណាក់ ឬ ទីសំណាក់មិនពិតប្រាកដទេ សមត្ថកិច្ចនោះ ត្រូវកំណត់តាមលំនៅឋានចុងក្រោយ ។

៣- ក្នុងករណីមិនអាចកំណត់តុលាការមានសមត្ថកិច្ច តាមបញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ បណ្តឹងទាក់ទងនឹងឋានៈបុគ្គលត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់សាលាដំបូងរាជធានីភ្នំពេញ ។

**មាត្រា ៦._** ការផ្ទេរបណ្តឹងដើម្បីចៀសវាងការយឺតយ៉ាវ

ទោះបីបណ្តឹងទាក់ទងនឹងឋានៈបុគ្គលណាមួយស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួនក៏ដោយ ប្រសិនបើតុលាការយល់ឃើញថាចាំបាច់ដើម្បីចៀសវាងការយឺតយ៉ាវហួសហេតុនៃនីតិវិធី ឬ ដើម្បីធ្វើឱ្យមានសមធម៌រវាងគូភាគី ដោយពិចារណាអំពីលំនៅឋានរបស់ភាគី និង សាក្សីដែលត្រូវសាកសួរ និង កាលៈទេសៈផ្សេងៗ តុលាការនោះអាចផ្ទេរបណ្តឹងទាក់ទងនឹងឋានៈបុគ្គលទាំងមូល ឬ ផ្នែកណាមួយ ទៅតុលាការផ្សេងទៀតដែលមានសមត្ថកិច្ចបានតាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

## ជំពូកទី ៤
## ភាគី

**មាត្រា ៧._** ចុងចម្លើយ

១- ក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលបានធ្វើឡើងដោយភាគីម្ខាងនៃទំនាក់ទំនងឋានៈបុគ្គលពាក់ព័ន្ធនឹងបណ្តឹងនោះ ភាគីម្ខាងទៀតត្រូវក្លាយជាចុងចម្លើយ លើកលែងតែមានបញ្ញត្តិពិសេស ។

២- ក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលបានធ្វើឡើងដោយជនដែលមិនមែនជាភាគីនៃទំនាក់ទំនងឋានៈបុគ្គលពាក់ព័ន្ធនឹងបណ្តឹងនេះ ភាគីទាំងសងខាងនៃទំនាក់ទំនងឋានៈបុគ្គលនេះ ត្រូវក្លាយជាចុងចម្លើយ ហើយនៅក្រោយពេលដែលភាគីណាមួយបានទទួលមរណភាព ភាគីម្ខាងទៀតត្រូវក្លាយជាចុងចម្លើយ លើកលែងតែមានបញ្ញត្តិពិសេស ។

៣- ក្នុងករណីដែលជនដែលត្រូវក្លាយជាចុងចម្លើយនៃបណ្តឹង តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ ខាងលើនេះ ទទួលមរណភាព ហើយគ្មានជនណាត្រូវក្លាយជាចុងចម្លើយទេនោះ តំណាងអយ្យការត្រូវក្លាយជាចុងចម្លើយ ។

**មាត្រា ៨._** សមត្ថភាពក្នុងការធ្វើបណ្តឹង ក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ជាអាទិ៍

១- ចំពោះសកម្មភាពបណ្តឹងក្នុងនីតិវិធីបណ្តឹងនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល បញ្ញត្តិនៃមាត្រា ១៨ ( សិទ្ធិលុបចោលសកម្មភាព ) មាត្រា ២៦ ( សិទ្ធិលុបចោលសកម្មភាព ) និង មាត្រា ៣០ ( សិទ្ធិលុបចោលសកម្មភាព ) នៃក្រមរដ្ឋប្បវេណី និង កថាខណ្ឌទី ៣ នៃមាត្រា ៣២ ( សមត្ថភាពភាគី សមត្ថភាពក្នុងការធ្វើបណ្តឹង ការតំណាងដែលច្បាប់បានកំណត់សម្រាប់ជនដែលគ្មានសមត្ថភាពក្នុងការធ្វើបណ្តឹង ) និង មាត្រា ៣៣ ( បញ្ញត្តិពិសេសស្តីពីសកម្មភាពបណ្តឹងរបស់ជននៅក្រោមហិតូបត្ថម្ភ និង អ្នកតំណាងដែលច្បាប់បានកំណត់ ) នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តឡើយ ។

២- ក្នុងករណីជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្តឹង មានបំណងធ្វើសកម្មភាពបណ្តឹងដែលកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើយល់ឃើញថាចាំបាច់ ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចជ្រើសតាំងមេធាវីឱ្យធ្វើជាអ្នកតំណាងតាមពាក្យសុំបាន ។

Kh

៣- ទោះបីជាជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្ដឹង មិនដាក់ពាក្យសុំដែលកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះក៏ដោយ ក៏ប្រធានក្រុមប្រឹក្សាជំនុំជម្រះអាចបង្គាប់ឱ្យជ្រើសតាំងមេធាវីជាអ្នកតំណាង ឬ អាចជ្រើសតាំងមេធាវីជាអ្នកតំណាងដោយឆន្ទានុសិទ្ធិបាន ។

៤- ចំនួនទឹកប្រាក់នៃកម្រៃដែលជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្ដឹង ត្រូវបង់ឱ្យមេធាវីដែលប្រធានក្រុមប្រឹក្សាជំនុំជម្រះបានជ្រើសតាំងជាអ្នកតំណាង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ឬ កថាខណ្ឌទី ៣ ខាងលើនេះ ត្រូវជាចំនួនទឹកប្រាក់ដែលតុលាការយល់ឃើញថាសមរម្យ ។

៥- ក្នុងចំណោមកម្រៃនិងសោហ៊ុយដែលបានបង់ឱ្យទៅមេធាវី ដែលប្រធានក្រុមប្រឹក្សាជំនុំជម្រះបានជ្រើសតាំង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ឬ កថាខណ្ឌទី៣ខាងលើនេះ ឬ បង់ឱ្យទៅមេធាវីដែលជនត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្ដឹងបានជ្រើសតាំង ក្នុងករណីដែលប្រធានក្រុមប្រឹក្សាជំនុំជម្រះបង្គាប់ឱ្យជ្រើសតាំង ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ៣ ខាងលើនេះ ចំនួនទឹកប្រាក់ដែលតុលាការយល់ឃើញថាសមរម្យ ត្រូវក្លាយជាប្រាក់ប្រដាប់ក្ដី ។

**មាត្រា ៩.–** សិទ្ធិអំណាចរបស់ជននៅក្រោមអាណាព្យាបាលទូទៅ ជាអាទិ៍

១- ប្រសិនបើជនដែលត្រូវក្លាយជាដើមចោទ ឬ ចុងចម្លើយនៃបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ជាជននៅក្រោមអាណាព្យាបាលទូទៅ អ្នកអាណាព្យាបាលទូទៅសម្រាប់ជននោះអាចប្ដឹង ឬ អាចត្រូវបានប្ដឹងដោយតំណាងឱ្យជននៅក្រោមអាណាព្យាបាលទូទៅនោះបាន ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកអាណាព្យាបាលទូទៅនោះ ជាភាគីម្ខាងទៀតនៃបណ្ដឹងនោះ ។

២- ក្នុងករណីដែលកំណត់ក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ខាងលើនេះ អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលទូទៅអាចប្ដឹង ឬ អាចត្រូវបានប្ដឹងដោយតំណាងឱ្យជននៅក្រោមអាណាព្យាបាលទូទៅបាន ។

## ជំពូកទី ៥
## ប្រាក់ប្រដាប់ក្ដី

**មាត្រា ១០.–** ប្រាក់ប្រដាប់ក្ដី

ក្នុងបណ្ដឹងទាក់ទងនឹងឋានៈបុគ្គល ដែលមានតំណាងអយ្យការជាភាគី ប្រាក់ប្រដាប់ក្ដីដែលតំណាងអយ្យការ ត្រូវទទួលបន្ទុកដោយយោងតាមបញ្ញត្តិពីកថាខណ្ឌទី ១ ដល់កថាខណ្ឌទី ៣ មាត្រា ៦៤ (ភាគដែលត្រូវទទួលបន្ទុក និង ការសងវិញនូវប្រាក់ប្រដាប់ក្ដីដែលបានបង់រួចហើយ) នៃក្រមនីតិវិធីរដ្ឋប្បវេណី គឺជាបន្ទុករបស់រដ្ឋ ។

Ksl

# ជំពូកទី ៦
# នីតិវិធីនៃបណ្តឹង

**មាត្រា ១១.–** ការរួមបញ្ចូលការទាមទារដែលពាក់ព័ន្ធ

ការទាមទារពាក់ព័ន្ធនឹងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល និង ការទាមទារពាក់ព័ន្ធនឹងសំណងការខូចខាតដែលកើតមានឡើងដោយអង្គហេតុដែលជាមូលហេតុនៃការទាមទារ ពាក់ព័ន្ធនឹងបណ្តឹងទាក់ទងនឹងឋានៈបុគ្គលនោះ អាចធ្វើដោយបណ្តឹងតែមួយបាន ទោះបីមានបញ្ញត្តិមាត្រា ៧៧ ( ការបញ្ចូលការទាមទារច្រើនចំណុចទៅក្នុងបណ្តឹងតែមួយ ) នៃក្រមនីតិវិធីរដ្ឋប្បវេណីក៏ដោយ ។

**មាត្រា ១២.–** ការបន្ថែម ឬ ការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង និង បណ្តឹងតប

ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ៤ នៃមាត្រា ៨៤ ( ការបន្ថែម ឬ ការផ្លាស់ប្តូរនូវកម្មវត្ថុនៃបណ្តឹង ) កថាខណ្ឌទី ១ នៃមាត្រា ៨៦ ( បណ្តឹងតប ) និង មាត្រា ២៧៦ ( ការដាក់ពាក្យបណ្តឹងតប ) នៃក្រមនីតិវិធីរដ្ឋប្បវេណីក៏ដោយ នៅក្នុងនីតិវិធីពាក់ព័ន្ធនឹងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដើមចោទអាចបន្ថែម ឬ ផ្លាស់ប្តូរនូវការទាមទារ ឬ មូលហេតុនៃការទាមទារបាន ហើយចុងចម្លើយអាចប្តឹងតបបានរហូតដល់ពេលចប់ ការទាញហេតុផលដោយផ្ទាល់មាត់នៃការជម្រះក្តីលើកទី ១ ឬ ការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ ។

**មាត្រា ១៣.–** បញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីដែលមិនត្រូវយកមកអនុវត្ត

១- មាត្រា ៩៤ ( ការលើកចោលមធ្យោបាយតទល់ ឬ ការពារខ្លួនដែលបានដាក់យឺតយ៉ាវមិនត្រូវនឹងពេលសមរម្យ ) កថាខណ្ឌទី ១នៃមាត្រា ៩៦ ( ការចាត់ទុកថាបានសារភាព ) កថាខណ្ឌទី ២ នៃមាត្រា ១៤០ ( ការសាកសួរសាមីភាគី ) មាត្រា ១៥៣ ( អានុភាពនៅក្នុងករណីដែលភាគីមិនអនុវត្តតាមដីកាសម្រេចបង្គាប់ឱ្យផ្តល់ឯកសារ ជាអាទិ៍ ) កថាខណ្ឌទី ៤ នៃមាត្រា ១៥៦ ( ការបញ្ជាក់ដោយប្រៀបធៀបអក្សរដែលសរសេរដោយដៃ ) មាត្រា ២០០ ( សាលក្រមកំបាំងមុខដើមចោទ ) កថាខណ្ឌទី ២ នៃមាត្រា ២០១ ( សាលក្រមកំបាំងមុខចុងចម្លើយ ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ព្រមទាំងផ្នែកទាក់ទងនឹងអង្គហេតុដែលភាគីបានសារភាពចំពោះមុខតុលាការ នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ១២៣ ( គោលការណ៍សម្រេចសេចក្តីដោយកស្តុតាង ) នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តឡើយ ចំពោះនីតិវិធីបណ្តឹងនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ។

២- បញ្ញត្តិពីមាត្រា ២២០ ( ការផ្សះផ្សាលើបណ្តឹង ) ដល់មាត្រា ២២២ ( អានុភាពនៃកំណត់ហេតុស្តីពីការសះជា ជាអាទិ៍ ) នៃក្រមនីតិវិធីរដ្ឋប្បវេណី មិនត្រូវយកមកអនុវត្តឡើយ ចំពោះកម្មវត្ថុនៃបណ្តឹង នៅក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ។

**មាត្រា ១៤.-** ការស្រាវជ្រាវដោយឆន្ទានុសិទ្ធិ

នៅក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល តុលាការអាចយកអង្គហេតុដែលមិនបានអះអាងដោយភាគី មកធ្វើជាមូលដ្ឋាននៃសាលក្រមបាន ។ ក្នុងករណីនេះ តុលាការត្រូវសួរមតិពីភាគីអំពីអង្គហេតុនោះ ។

**មាត្រា ១៥.-** ការបង្គាប់ឱ្យសាមីភាគីមកបង្ហាញខ្លួន ជាអាទិ៍

១- នៅក្នុងបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ក្នុងករណីដែលសាកសួរសាមីភាគី តុលាការអាចបង្គាប់ឱ្យភាគីនោះមកបង្ហាញខ្លួនតាមកាលបរិច្ឆេទបាន ។

២- បញ្ញត្តិពីកថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៤ នៃមាត្រា ១៣២ (ករណីយកិច្ចរបស់សាក្សី) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលភាគីដែលត្រូវបានបង្គាប់ឱ្យមកបង្ហាញខ្លួន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនបានបង្ហាញខ្លួនដោយគ្មានមូលហេតុត្រឹមត្រូវ ។

**មាត្រា១៦.-** ការមិនធ្វើជាសាធារណៈនៃការទាញហេតុផលដោយផ្ទាល់មាត់

១- ការទាញហេតុផលដោយផ្ទាល់មាត់នៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល មិនត្រូវធ្វើជាសាធារណៈឡើយ ។

២- ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏តុលាការអាចធ្វើការទាញហេតុផលដោយផ្ទាល់មាត់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ដោយធ្វើជាសាធារណៈ ឬ អាចអនុញ្ញាតឱ្យជនណាដែលតុលាការយល់ឃើញថាសមរម្យ ចូលស្តាប់ជាអ្នកសង្កេតការណ៍បានដែរ ។

**មាត្រា ១៧.-** វិសាលភាពនៃបុគ្គលដែលទទួលនូវអានុភាពនៃសាលក្រម ឬ សាលដីកាស្ថាពរ

១- ទោះបីជាមានបញ្ញត្តិនៃមាត្រា ១៩៨ (វិសាលភាពបុគ្គលដែលត្រូវទទួលអានុភាពរបស់សាលក្រមស្ថាពរ) នៃក្រមនីតិវិធីរដ្ឋប្បវេណីក៏ដោយ ក៏សាលក្រម ឬ សាលដីកាស្ថាពរនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គលមានអានុភាពចំពោះតតិយជនដែរ ។

២-ក្នុងករណីដែលមានការទាមទារឱ្យលុបចោលនូវអាពាហ៍ពិពាហ៍ដោយយកមូលហេតុផ្អែកលើបញ្ញត្តិនៃមាត្រា ៩៤៩ (ការហាមឃាត់មិនឱ្យមានទ្វេពន្ធភាព) នៃក្រមរដ្ឋប្បវេណី ហើយបើការទាមទារនេះត្រូវបានច្រានចោល ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏សាលក្រម ឬ សាលដីកាស្ថាពរដែលច្រានចោលការទាមទារនោះ មានអានុភាពចំពោះសហព័ទ្ធនៃអាពាហ៍ពិពាហ៍មុន លុះត្រាតែសហព័ទ្ធនៃអាពាហ៍ពិពាហ៍មុននោះ បានចូលរួមអន្តរាគមន៍ក្នុងបណ្តឹងដែលពាក់ព័ន្ធនឹងការទាមទារនោះ ដោយយោងតាមបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ROYAUME DU CAMBODGE
LE MINISTÈRE DU PALAIS ROYAL

Kol

**មាត្រា ១៨.–** ការហាមមិនឱ្យដាក់ពាក្យបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលក្រោយពេលសាលក្រម ឬ សាលដីកាចូលជាស្ថាពរ

១- ក្រោយពេលសាលក្រម ឬ សាលដីកានៃបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលបានចូលជាស្ថាពរ ដើមចោទមិនអាចដាក់ពាក្យបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលស្ដីពីទំនាក់ទំនងឋានៈបុគ្គលដដែល ដោយផ្អែកលើអង្គហេតុដែលខ្លួនអាចអះអាងបាន ដោយការបន្ថែម ឬ ការផ្លាស់ប្ដូរនូវការទាមទារ ឬ មូលហេតុនៃការទាមទារ ក្នុងបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលនោះបានឡើយ ។

២- ក្រោយពេលសាលក្រម ឬ សាលដីកានៃបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលបានចូលជាស្ថាពរ ចុងចម្លើយមិនអាចដាក់ពាក្យបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលស្ដីពីទំនាក់ទំនងឋានៈបុគ្គលដដែលដោយផ្អែកលើអង្គហេតុដែលខ្លួនអាចអះអាងបាន ដោយការដាក់ពាក្យបណ្ដឹងតបក្នុងបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលនោះបានឡើយ ។

៣- បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះសាលក្រម ឬ សាលដីកាដែលបានលើកបណ្ដឹងចោលដោយហេតុថាបណ្ដឹងនោះមានលក្ខណៈផ្ទុយនឹងច្បាប់ ។

**មាត្រា ១៩.–** មរណភាពរបស់ដើមចោទ

ក្នុងករណីដែលដើមចោទនៃបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលទទួលមរណភាព នៅពេលដែលបណ្ដឹងនោះកំពុងត្រូវបានចាត់ការ នោះបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលនោះត្រូវចប់ដោយស្វ័យប្រវត្តិ លើកលែងតែករណីដែលមានបញ្ញត្តិពិសេស ។

**មាត្រា ២០.–** មរណភាពរបស់ចុងចម្លើយ

១- ក្នុងករណីដែលភាគីទាំងសងខាងនៃទំនាក់ទំនងឋានៈបុគ្គល ត្រូវក្លាយជាចុងចម្លើយ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៧ (ចុងចម្លើយ) នៃច្បាប់នេះ ហើយប្រសិនបើភាគីណាមួយទទួលមរណភាព បណ្ដឹងនេះត្រូវបន្តនីតិវិធី ដោយយកភាគីម្នាក់ទៀតនោះមកធ្វើជាចុងចម្លើយ ។ ក្នុងករណីនេះ បញ្ញត្តិនៃចំណុច ក កថាខណ្ឌទី ១ នៃមាត្រា ១៧៣ (ការផ្អាក និង ការទទួលបន្តនូវនីតិវិធីនៃបណ្ដឹង) នៃក្រមនីតិវិធីរដ្ឋប្បវេណីមិនត្រូវយកមកអនុវត្តឡើយ ។

២- ក្នុងករណីដែលកំណត់ក្នុងកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ នៃមាត្រា ៧ (ចុងចម្លើយ) នៃច្បាប់នេះ ហើយប្រសិនបើចុងចម្លើយទាំងអស់ទទួលមរណភាព បណ្ដឹងនេះត្រូវបន្តនីតិវិធី ដោយយកតំណាងអយ្យការមកធ្វើជាចុងចម្លើយ ។

៣- ក្នុងករណីដែលចុងចម្លើយនៃបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលដែលមានគោលបំណងលែងលះគ្នា ឬ កាត់កាល់ ទទួលមរណភាព នៅពេលដែលបណ្ដឹងនេះកំពុងត្រូវបានចាត់ការបណ្ដឹងទាក់ទងនឹងឋានៈបុគ្គលនេះត្រូវចប់ដោយស្វ័យប្រវត្តិ ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះក៏ដោយ ។